# វេយ្យាករណ៍ខ្មែរទំនើប

# LA GRAMMAIRE KHMERE MODERNE



បោះពុម្ពលើកទី ២

CA14

# វេយ្យាករណ៍ខ្មែរ
## ទំនើប

# LA GRAMMAIRE KHMERE MODERNE

សម្រាប់គ្រប់ថ្នាក់

បាត់សាងដោយ

សៀង-វ័ណ្ឌី

លេខាធិការក្រសួងសាធារណការ ភ្នំពេញ

បោះពុម្ពលើកទី ២

ការផ្សាយរបស់

គីម-ហ៊ុន

លេខ៤១៩កមហា
វិថីព្រះបាទមុនីវង្ស
ខាងត្បូងពេទ្យចិន
ភ្នំពេញ

ព.ស. ២៥០០ គ.ស. ១៩៥៧

ឧកសិទ្ធិ

ព្រះរាជអាណាចក្រ

កម្ពុជា

លេខ ១៣៥ SPU

ភ្នំពេញ, ថ្ងៃទី ២០ ខែតុលា គ.ស. ១៩៥៥

សម្ដេចព្រះនរោត្ដម-សីហនុ ឧបយុវរាជ

មកលោក សៀន-វ័នឌី លេខាធិការនៅនិគមការស៊ីវិល ក្រសួងសាធារណការ ក្រុងភ្នំពេញ ។

ខ្ញុំបានទទួលសៀវភៅវេយ្យាករណ៍ខ្មែរទំនើបដែលបានផ្ញើទៅហើយ បានឲ្យពិនិត្យមើលសព្វគ្រប់ទៅឃើញថា សៀវភៅវេយ្យាករណ៍ខ្មែរទំនើបរបស់លោកនេះ ល្មមទុកជាក្បួនច្បាប់មួយសម្រាប់ធ្វើជាបែបផែនខាងអក្ខរវិធីខ្មែរយើងបានសមគួរហើយ ។

ខ្ញុំមានសេចក្ដីសោមនស្សណាស់ នៅវេលាដែលបានឃើញក្បួននេះ ហើយសូមសម្ដែងសេចក្ដីសរសើរ

ចំពោះការព្យាយាមរបស់លោកដែលមានឧត្តមគតិបានបង្កើតវេយ្យាករណ៍នេះឡើង ជាប្រយោជន៍ដល់ជាតិ ។

ខ្ញុំជឿច្បាស់ថា សៀវភៅវេយ្យាករណ៍ខ្មែរទំនើបនេះ អាចនាំសេចក្តីចំរើន ទីងជាប្រយោជន៍ដល់អ្នកត្រូវការដោយអក្សរសាស្ត្រខ្មែរយើង ដែលកំពុងត្រូវការដោយខានពុំបានជាប្រាកដ ។

សម្តេចព្រះឧបាយព្រះមហាសង្ឃលេខា
ន.សីហនុ

# សេចក្ដីយល់ឃើញ

ដោយគ្រាន់តែបានបើកមើលទ្រួសៗឥតបានជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួលសោះទេ ព្រោះកំពុងមានករណីយកិច្ចផ្ទាល់ខ្លួនច្រើនពេក ពុំមានឱកាស ។

យល់ឃើញថា ធម្មតាការងារជាស្នាដៃដំបូងបង្អស់តែងតែមានភ្លាត់ខុសឆ្គងខ្លះ បើមិនច្រើនក៏បន្តិចបន្តួចពុំខាន, ប៉ុន្តែ បើទុកជាដូច្នោះក៏ដោយ, សៀវភៅនេះឲ្យសម្រេចប្រយោជន៍ ដល់កុលបុត្រកុលធីតាអ្នកសិក្សាអក្សរសាស្ត្រខ្មែរពុំមែនជាមោឃៈឡើយ, ប្រសើរជាជាងគ្មានសោះ ។

ថ្ងៃទី ២២ វិច្ឆិកា ២៤៩៧ / ១៩៥៤

សម្ដេចព្រះមហាសុមេធាធិបតី ជ.ណា

ព្រះរាជាណាចក្រ
កម្ពុជា
ទីស្ដីការនាយករដ្ឋមន្ត្រី
លេខ ៦២៤ ន.គ រ.លជ

ភ្នំពេញ, ថ្ងៃទី ៣១ ឧសភា គ.ស. ១៩៥៦

អ្នកឧកញ៉ា នាយករដ្ឋមន្ត្រី

មកលោក សៀន-ទ័នឌី លេខាធិការគណនេយ្យ នៅនិគមមហាគារស៊ីវិល ក្រសួងសាធារណការ ក្រុងភ្នំពេញ ។

តបពាក្យលោក ចុះថ្ងៃទី ២៩ ៥ ៥៦ អំពីលោកមានគំនិតឈ្លាសវៃ បានព្យាយាមដ៏មុតមាំបានរៀបរៀងសៀវភៅ “ វេយ្យាករណ៍ខ្មែរទំនើប ” និង “ អនុវេទសទិសសព្ទ ” ដើម្បីជួយជាកម្លាំងដល់ការប្រើអក្សរសាស្ត្រជាតិជាផ្លូវការ ។

ខ្ញុំមានសេចក្ដីសោមនស្ស រីករាយយ៉ាងក្រៃលែង ចំពោះគំនិតដ៏ជ្រាលជ្រៅរបស់លោក និងសៀវភៅទាំង ២ ក្បាលដែលលោកជូនចំពោះខ្ញុំ ដើម្បីទុកជាអនុស្សាវរីយ៍ ។

សុំលោកទទួលនូវសេចក្ដីរាប់អានអំពីខ្ញុំ,

ឃឹម-ទិត

## លោក សៀន-ខ័នឌី

ខ្ញុំបានទទួលសៀវភៅ " វេយ្យាករណ៍ខ្មែរទំនើប " របស់លោកហើយ នៅពេលនោះ ខ្ញុំឈឺផង អាការរោគខ្ញុំមិនអាចឲ្យខ្ញុំមើលច្រើនបានឡើយ ប៉ុន្តែដោយខ្ញុំមានចេតនាចំពោះតែនឹងអក្សរជាតិ ខ្ញុំក៏ប្រឹងក្រដរ មើលមួយថ្ងៃបន្តិច ៗ ដល់តែចប់ ហើយខ្ញុំមានចិត្តរីករាយឥតឧបមាព្រោះឃើញថា វេយ្យាករណ៍ខ្មែរទំនើបនេះ មានសារៈសំខាន់ មានរបៀបសិក្សាគប់គ្រាន់នឹង "កម្មវិធីផ្លូវការ" នៃថ្នាក់ប្រថមភូមិបំពេញវិជ្ជា ដែលសព្វថ្ងៃនៅខ្សត់ខ្សោយសៀវភៅបែបនេះនៅឡើយ ។

ខ្ញុំសូមថ្លែងអំណរ និងសរសើរចំពោះមនោសញ្ចេតនារបស់លោក ដែលមានព្យាយាមរៀបរៀងសៀវភៅនេះឲ្យកើតមានឡើង ដោយត្រឹមត្រូវ ជាការជួយលើកដំកើង

ភាសានិងអក្សរសាស្ត្រជាតិយើង ។

ភ្នំពេញ, ថ្ងៃ ១២ វិច្ឆិកា គ.ស ១៩៥៥

អ៊ុំ - ឈុំ

ចាងហ្វាងសាលារៀនព្រះអង្គអេង

ជំរាបលោក

ខ្ញុំមានបីតិសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលសៀវភៅវេយ្យាករណ៍ខ្មែរទំនើប សៀវភៅនេះមានខ្លឹមសារសំខាន់ណាស់ ខ្ញុំសូមសរសើរដល់គំរិះនិងសេចក្តីព្យាយាមរបស់លោក សូមលោកទទួលនូវអំណរគុណដ៏លើសលប់អំពីខ្ញុំ ។

អ្នកស្រី ម៉ាត់-ប៉ុស

ចាងហ្វាង សាលាកុមារី សត្វាស

កម្ពុជា ភ្នំពេញ

## យោបល់

# លើសៀវភៅវេយ្យាករណ៍ខ្មែរទំនើប

ជាដំបូងបំផុត, ខ្ញុំព្រមទាំងភរិយាខ្ញុំ, មានសេចក្តីអរគុណចំពោះមិត្ត ជាអ្នកព្យាយាមនិពន្ធក្បួនខ្នាតខាងអក្សរសាស្ត្រជាតិ ដែលបានធ្វើសំណោយនូវវេយ្យាករណ៍ខ្មែរធំមើយ ១ ដើម្បីឲ្យយើងខ្ញុំពិនិត្យឲ្យយោបល់តាមការសង្កេតក្នុងផ្លូវគេរ-កោសល្យនឹងផ្លូវខុសទៅតាមផ្ទៃចិត្តរបស់យើងខ្ញុំ ។

– ចំពោះយោបល់មួយ យើងខ្ញុំយល់ថាក្បួនវេយ្យា-ករណ៍ខ្មែរទំនើបនេះជាសៀវភៅមួយប្លែក, ទំនើប, ទាន់សម័យពិត, ព្រោះថា ក្នុងផ្នែកនៃមេរៀននិងសេចក្តីអធិប្បាយ, ន័យពន្យល់គឺពិតជាប្លែកហើយហ្មត់ចត់ព្រមទាំងគ្រប់ជាងក្បួនខ្នាតចាស់ៗពីមុនមកមានក្បួនលោក "ពូ-ស៊ុម,, លោក "គឹម-សែត,, និងក្នុងទស្សនាវដ្តីគ្រូ... ។ សោតឯ ឧទាហរណ៍ក៏គួរល្មមនឹងយល់បានដល់ការស្មាធ្យាយន៍ ៗ ដែលខ្វះបន្តិច

នោះ គឺខ្វះត្រង់ការហាត់ដែលមិត្តបំភ្លេចចោល ឬក៏មិត្តមិនបាន បញ្ចូលមកដោយខ្លាចកម្រាស់សៀវភៅធំពេក ហើយដែល អាចឲ្យមេរៀនដូចជាស្ងួតពេករកជីជាតិ ឬរកអន្លក់ផ្លាប់ជាមួយ គ្មាន ។ ម្យ៉ាងទៀត បើមិត្តអាចបញ្ចូលនូវការចោទសួរជាប្រ - ស្នាដោយបញ្ញានិងការត្រិះរិះចំពោះមេរៀននីមួយ ៗ ទៀត , នោះក៏ជាការប្រសើរណាស់ចំពោះក្បួនសិក្សា ព្រោះថាមេ- រៀនឥតពាក្យចោទជាមេរៀនគ្រាន់តែឲ្យចាំគ្មានយល់ ឬគ្មាន ជឹងអត្ថរសគួរឡើយ ។ ។

- យោបល់ទី ២ ដែលជាគំនិតផ្ទុះចេញពីហឫទ័យយើង ខ្ញុំមក , គឺជាសេចក្តីកោតសរសើរដល់ថ្វីដៃមិត្តដែលនៅក្នុង ជាងអ្នកប្រាជ្ញចំណានជំពូកខ្លះ ដែលគ្រាន់តែមានបញ្ញាជ្រៅ , មានគំនិតផ្ទុះផ្កាយ, មានវោហារក្បោះក្បាយតែខ្វះឧត្តមគតិនិង ការអង់អាចហ៊ានពុះពាររៀបក្បួនខ្នាតឲ្យសមរម្យតាមចំណោះ , ការបេះដូងរបស់ខ្លួនដែលខ្លួនចាំតែយកមកកទិទៀន , មាត់វែង

ខ្ញុំខ្សឹបនាយខ្សឹបកាយពោលថាគេពុំកើត , គេពុំដល់អញ បើអញធ្វើគ្រាន់បើជាង ... យ៉ាងនេះ ៗ សៀវភៅ " វេយ្យាករណ៍ខ្មែរទំនើប " ពិតជាស្នាដៃឯករបស់ខ្មែរសតវត្សរ៍ថ្មីនេះមែន ព្រោះថានៅពេលដែលប្រទេសកំពុងត្រូវការហើយខ្វះក្បួនជាអក្សរសាស្ត្រជាតិ , សៀវភៅនេះបានលេចធុះចេញមក ដូចជាភ្លៀងមួយមេធ្លាក់មកលើសំណាប កំពុងក្រៀមឲ្យមានជីវិតសង្ឃឹមទៅទៀត យ៉ាងនោះ ៗ

ជាបញ្ចប់ ពិតហើយថាខ្ញុំនិងភរិយាខ្ញុំ មិនមែនជាអ្នកប្រាជ្ញ ហើយគ្រាន់តែចេះធ្វើក្បួនខ្នាតតូច ៗ មិនដល់បណ្ឌិតឯទៀត ហើយមិនមានសមត្ថភាពអ្វីសោះនោះ , យើងខ្ញុំសូមសរសើរមិត្តដោយសុទ្ធចិត្ត និងសូមឲ្យមិត្តខំព្យាយាមពុះពារនូវឧបសគ្គទាំងឡាយ ក្នុងការនិពន្ធក្បួនខ្នាតសិក្សាទៅទៀត, គប្បីកុំស្តាប់នូវពាក្យលាមក ឬ ចិត្តមើលងាយ ថាក្មេង ! ថាអន់ ! ថាមិនចេះ ! នោះឡើយ !

ពិតហើយថា “អ្នកដែលធ្វើមែនខុស ហើយអ្នកដេកស្ងៀម បេះតែត្រូវ” ក៏ខ្ញុំនិងមិត្តយើងខ្ញុំទាំងពីរសន្និដ្ឋានមុនគេថា ពោះខុសដូចម្ដេចក៏មិត្តមិនសាបសូន្យនូវកិត្តិយស និងកិត្តិនាមដូចអ្នកដែលប្រាជ្ញព្រោកទាំងនោះកើតមកមានកញ្ញ, បេះសំរាប់តែជូនផែនដីនោះឡើយ !!!

សូមមិត្តទទួលនូវសេចក្ដីរាប់អាននិងមេត្រីភាព ពីយើងខ្ញុំទាំងពីរ ។

ថ្ងៃទី ៣០ – ១០ – ១៩៥៥

លាង-ហាប់-អាន និងភរិយា

(គ្រូបង្រៀនថ្នាក់បំពេញវិជ្ជា)

ភ្នំពេញថ្ងៃទី ២៥ ខែតុលា គ.ស. ១៩៥៦

ខ្ញុំបានទទួលនូវអំណោយសៀវភៅ " វេយ្យាករណ៍ខ្មែរទំនើប „ របស់មិត្តហើយ ពិតមែនតែខ្ញុំពុំទាន់បានបញ្ចេញស្នាដៃអ្វីមួយ ប៉ុន្តែក្នុងនាមផ្ទាល់របស់ខ្ញុំ និងក្នុងនាមនៃមិត្តដែលបានទទួលអំណោយរបស់មិត្ត ខ្ញុំហ៊ានសម្ដែងនិងបញ្ចេញយោបល់យល់ឃើញថាសៀវភៅវេយ្យាករណ៍ខ្មែរទំនើបនេះជាសៀវភៅមួយ ដែលអាចជួយចំរើននូវអក្សរសាស្ត្រជាតិហើយនិងបាត់នូវការប្រមាថមើលងាយ របស់អ្នកសិក្សាអក្សរបរទេស, ដែលគេតែងថាអក្សរខ្មែរគ្មានល័ក្ខណ៍គោលដូចអក្សរបរទេសឡើយ, គេមិនដែលប្រើក្នុងការចុះសន្និសញ្ញាអ្វីជាពិតប្រាកដបានទេ, បច្ចុប្បន្ននេះស្ដែងឲ្យឃើញច្បាស់នូវដម្លៃនៃអក្សរជាតិដោយមានសៀវភៅវេយ្យាករណ៍ខ្មែរទំនើបនេះ ដែលជាក្បួនខ្នាតមានល័ក្ខណ៍គោលរបៀបអក្សរសាស្ត្រមិនអន់ថយជាងអក្សរបរទេសឡើយ ។

ខ្ញុំសូមសរសើរដល់ចំណេះវិជ្ជានិងការព្យាយាមរបស់មិត្ត,

សូមមិត្តទទួលនូវសេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ស៊ឹម-សុវណ្ណា អនុរក្សនៅនិគមអាគារស៊ីវិល

ក្រុងភ្នំពេញ ។

ROYAUME DU CAMBODGE

LYCÉE PREAH SIHANOUK
KOMPONG-CHAM

Kompong-Cham, le 8 Octobre 1955
N°- 500 /S.

Le proviseur du Lycée preah Sihanouk
A Monsieur SIEN KHANDY,
Secrétaire
DES TRAVAUX PUBLICS
à PHNOM-PENH.-

Monsieur,

J'ai l'honneur de vous accuser réception de votre lettre du 2 - 10 - 55 ainsi que de votre livre de Grammaire khmère.

Très touché de votre envoi, je vous en remer. cie cordialement et vous adresse mes sincères félicitations pour le travail que vous avez fait pour l'Enseignement.

Je vais soumettre votre livre à l'examen des professeurs compétents et, au cas où il conviendrait aux classes du Lycée, je proposerais au Ministère de l'Education Nationale d'en passer commande pour mon Etablissement.

Veuillez agréer, Monsieur, l'expression de ma considération distinguée.

L.LACOTTE
Professeur Licencié

ROYAUME DU CAMBOGE
COLLÉGE
PRÉAH SORYOVONG

N° 392

Svay-Rieng, le 29 Septemdre 1955

*Le Directeur*
*du Collège Préah Soryovong*

à Monsieur. SIEN KHANDY, Secrétaire des Travaux neufs en service à l'Arrondissement des Bâtiments Civils TRAVAUX PUBLICS
à PHNOM-PENH

Monsieur,

J'ai l'honneur de vous accuser réception du spécimen "La Grammaire Khmère Moderne,, que vous avez bien voulu m'offrir. Je vous en remercie bien sincèrement.

Après avis du Conseil des professeurs, je ne manquerai pas de Conseiller ce livre aux élèves du Collège.

Veuillez agréer, Monsieur mes salutations distinguées.

André Bizien

# បុព្វយោគ

សៀវភៅនេះ ម្ចាស់កម្មសិទ្ធិចង់កែប្រែផែនទៅតាមសេចក្ដីត្រូវការរបស់លោកគ្រូ-អ្នកគ្រូ និងអ្នកសិក្សាណាស់ ក៏ប៉ុន្តែមិនអាចនឹងធ្វើទៅបាន តាមចំណង់ចិត្តរបស់មិត្តនោះឡើយ ដោយហេតុថា " ខ្លាចក្រែងសៀវភៅនេះចេះតែបញ្ចូនទំព័រមកកាន់តែក្រាស់ឡើង ៗ ជាហេតុនាំឲ្យថ្លៃនោះកាន់តែកើនឡើង ៗ ដែរ " ។ បើប្រសិនជាមានអត្ថបទ ១ ស្របនឹងការរៀបចំ មុនសេចក្ដីពន្យល់នៃមេរៀន រួចមកមេរៀនសង្ខេប ការហាត់នឹងអនុវាក្យ នោះប្រហែលជាសៀវ-ភៅកាន់តែហុចអត្ថប្រយោជន៍និងសារៈសំខាន់ កាន់តែច្បាស់ឡើង ៗ, នេះជាការប្រសើរវិសេសណាស់ទៅហើយ ក៏ប៉ុន្តែមានមិត្តខ្លះថា " ចុះបើយើងសង្ខេបសេចក្ដីពន្យល់នៃមេរៀននោះឲ្យទៅជាមេរៀនតែម្ដងទៅ ហើយបញ្ចូលគន្លឹះទាំងប៉ុន្មាននោះឲ្យសមរម្យឡើង នេះប្រហែលជាគ្រាន់បើជាងការបោះ-

ពុម្ពនៅលើកទី ១ „ ។ យោបល់ទាំងពីរបែបនេះប្រសើរពិត
មែនហើយ ហើយការពិត គួរតែខ្ញុំត្រូវតែកែប្រែជាដាច់ខាត តែ
ខ្ញុំយល់ថា បែបរៀននេះសំរាប់គ្រប់ថ្នាក់ ហើយ១ទៀត
ដើម្បីនឹងកុំឲ្យផ្ទុយខ្លាំងពេកពីយោបល់របស់មិត្ត នៅលើក
ក្រោយខ្ញុំនឹងខំសែបន្ថែមការ ហាត់នឹងអក្ខរាវិរុទ្ធក្នុងមេរៀនខ្លះ
ថែមទៀតៗ ការដែលខ្វះចន្លុះក្នុងសៀវភៅនេះ គង់នៅមានខ្លះ
ដូចសៀវភៅដទៃទៀតដែរ ព្រោះអ្នកធ្វើដែលប្រើវេលាមិន
តិចនោះយល់ដោយយ៉ាង ហើយអ្នកយកទៅបង្រៀន ឬ
រៀនយល់ដោយយ៉ាង ។

ខ្ញុំមានសង្ឃឹមថា ក្នុងការបោះពុម្ពលើកនេះ គង់ជូនប្រ·
យោជន៍ថ្មីលើសមុន ហើយបើកាលៈទេសៈបេះតែហុចឱកាស
ឲ្យខ្ញុំ ខ្ញុំនឹងរៀបចំទៅតាមថ្នាក់ដែលត្រូវការតទៅ ។

សូមកុសលនៃសៀវភៅដែលផ្សាយជាលើកទី ២ នេះ
ដំកល់ថ្វាយព្រះករុណាទាំងពីរព្រះអង្គ និងសម្តេចព្រះឧបយុវ·

ពជ ន. សីហនុកំពូលមហាអគ្គបុរសរ័តន៍ និងជូនដល់គុណលោកគ្រូទាំងឡាយដែលបានបង្ហាត់បង្រៀនខ្ញុំ ឲ្យចេះឲ្យដឹង ឲ្យស្រឡាញ់ និងឲ្យខំថែអក្សរសាស្ត្រជាតិ ។

ភ្នំពេញនៅថ្ងៃទី ៣១ សីហា គ.ស. ១៩៥៦

ស. ១. ឌ.

# មនោរម្មណ៍មុនការផ្ដើម

ប្រទេសឯករាជ្យ តែងតែពឹងផ្អែកទៅលើអក្សរសាស្ត្រជាតិយ៉ាងលើសលប់ គឺយើងត្រូវការក្បួនខាតផ្សេងៗ ជាភាសាជាតិ ហើយសូម្បីតែក្នុងក្រសួងនានាក្ដី ក៏ត្រូវការប្រើប្រាស់ជាដាច់ខាត នូវអក្សរសាស្ត្រជាតិដែរ ។

អក្សរសាស្ត្រឯករាជ្យ ឬ អក្សរសាស្ត្រជាតិខ្មែរដែលនឹងថ្ថៃរថ្កុំថ្កើងរុងរឿងឡើងបាន ឬ អក្សរសាស្ត្រខ្មែរដែលនឹងឈានជើងទៅកាន់អារ្យធម៌ ដូចប្រទេសគេនានាបាន អាស្រ័យគោលសំខាន់ពីរយ៉ាងគឺ ៖

១ – សម្បូណ៌ក្បួនវេយ្យាករណ៍ និងសៀវភៅសិក្សានានាជាភាសាជាតិ ដើម្បីច្បាប់ប្រាប់ឲ្យជនានុជនសរសេរឲ្យបានត្រឹមត្រូវហ្មត់ចត់ប្រាកដប្រជា ;

២ – ដោយយើងលើកអក្សរសាស្ត្រយើងជាត្រីមុខ ក្នុងផ្លូវការផងទាំងពួងសព្វសារពើ គឺដោយកម្ពុជកុលបុត្រ កុលធីតា នាំគ្នានិយមប្រើនូវទៅក្នុងព្រះរាជាណាចក្រ ;

គោលសំខាន់ទាំងពីរយ៉ាងនេះហើយ ដែលជាមូលហេតុនាំឲ្យខ្ញុំពិចារណាដល់ការស្ដើងស្ដួចនៃក្បួនខ្នាតផ្សេងៗជាភាសាជាតិយើង ពិសេសបំផុត គឺយើងគ្មានក្បួនវេយ្យាករណ៍ឲ្យបានទៀងទាត់ជ្រៅជ្រះសោះ ដែលជាការចាំបាច់មួយក្នុងការសិក្សាអក្សរសាស្ត្រជាតិ ។

ព្រោះហេតុនេះ ទើបខ្ញុំខំស្រាវជ្រាវក្បួនខ្នាតផ្សេង ៗ មានវចនានុក្រមខ្មែរ, សៀវភៅ "វេយ្យាករណ៍„ របស់លោកពូរ-ឝុំ, សៀវភៅ "ភាសាខ្មែរ„ របស់លោក អៀវ-កើស, សៀវភៅ "អក្ខរាវិរុទ្ធវិធាន„ របស់ព្រះបាឡាត់ពោធិពង្ស-ជា-ទន់...ជាដើម មកពិនិត្យមើល ហើយបាត់បែនជាសៀវភៅ "វេយ្យាករណ៍ខ្មែរទំនើប„ នេះឡើង ។

សៀវភៅ "វេយ្យាករណ៍ខ្មែរទំនើប„ នេះ ខ្ញុំបានរៀបរៀងតាមលំដាប់មេរៀនមុនក្រោយ តម្រូវតាមកម្មវិធីសិក្សាសម្រាប់ខែត្រប់ថ្នាក់ ខ្ញុំមានសេចក្ដីស្ដាយជាពន់ពេកណាស់ ដោយព្រែងដល់ទំព័រសៀវភៅនេះក្រាស់ហួសប្រមាណពេក ព្រោះ

ហេតុដូច្នេះហើយ បានជាខ្ញុំពុំបានដាក់ការហាត់ ឬអត្ថបទសម្រាប់រៀនមើល និងអនុពាក្យភ្ជាប់ជាមួយផង ៗ សៀវភៅ "វេយ្យាករណ៍ខ្មែរទំនើប" នេះ គ្រាន់តែជាគ្រឿងបំភ្លឺខ្លះប៉ុណ្ណោះទេ ដោយខ្ញុំមានសង្ឃឹមថាគង់មានវេយ្យាករណ៍-បណ្ឌិតផងឯកណាមួយ ធ្វើឡើងកាន់តែវិសេសជាងនេះទៅទៀត ៗ

នាទីបំផុតនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកនិពន្ធ "-លី-ធាមតេង" ដែលបានជួយឧបត្ថម្ភទាល់តែសៀវភៅ "វេយ្យាករណ៍ខ្មែរទំនើប" ដែលសរសេរដោយដៃរបស់ខ្ញុំក្លាយទៅជាអក្សរពុម្ពនាទំព័រទាំងនេះ និងសូមជូនសៀវភៅនេះចំពោះវិញ្ញាណក្ខន្ធវីរបុរសខ្មែរទាំងសាកល ៗ

ភ្នំពេញនៅថ្ងៃទី១ វិច្ឆិកា គ.ស. ១៩៥៤

កម្មសិទ្ធិរបស់

សៀន - ច័នឌី

លេខាធិការក្រសួងសាធារណការក្រុងភ្នំពេញ

# អក្ខរសម្ភព



អក្សរហ្វេនិស៊ៀន
អក្សរព្រាហ្មី
អក្សរអឺរុប
អក្សរឥណ្ឌៀក្រោម
អក្សរឥណ្ឌៀលើ
អក្សរខ្មែរបុរាណ
អក្សរមនបុរាណ
អក្សរខ្មែរ
អក្សរព្រៀងខ្មែរ
អក្សរថៃដើម
អក្សរភូមា
អក្សរថៃសុខោទ័យ
អក្សរអាហ៊ុម
អក្សរខ្មែរ បែបផ្សេងៗ
អក្សរស្យាម
អក្សរលាវ លានឆាង
អក្សរថៃ តាំងកៀ
អក្សរលឺនិងលាវ លានណាថៃ
អក្សរងៀវ

# ជំហានអក្សរសាស្ត្រ

## គោលសេចក្ដី

១ – អក្សរខ្មែរមានកំណើតពីកាលណាមក ?

២ – បើយើងបោះបង់ចោលអក្សរសាស្ត្ររបស់ជាតិ តើនឹងមានការខូចខាតដូចម្ដេចខ្លះឬទេ ?

៣ – កុលបុត្រ កុលធីតា ទាំងឡាយ ត្រូវប្រតិបត្តិក្នុងរឿងអក្សរសាស្ត្ររបស់ជាតិដូចម្ដេចខ្លះឬទេ ?

## សេចក្ដីថ្លែង

១) កាលមានមនុស្សជាតិកើតឡើងហើយ ក៏មានភាសានិយាយកើតឡើងព្រមជាមួយគ្នាដែរ តែក្នុងជំនាន់ដើមឯណោះពុំទាន់មានអក្សរសម្រាប់ប្រើកត់ត្រាពាក្យពេចន៍នៅឡើយទេ, លុះចំណេរជាច្រើនម៉ឺនឆ្នាំមក ពពួកមនុស្សគ្រាន់តែមានសេចក្ដីចេះ

ដឹងចំរើនឡើងបន្តិចម្តងៗ, ក្នុងទីបំផុតក៏មានប្រាជ្ញាជាយ៉ាងក្រៃលែង ដោយបង់ឡើងរៀងពីក្នុងភាសាជាតិ មានប្រវត្តិ-សាស្ត្រជាដើម ស្ថិតជាប់នៅអស់កាលជាអង្វែងទៅ ដើម្បីឲ្យអនុជនទាំងក្រោយបានដឹងឃើញផង ; តាំងអំពីនោះមកក៏មានអ្នកប្រាជ្ញបានផ្តួចផ្តើមគំនិតធ្វើតួអក្សរឡើង តែគង់រះរករិះធ្វើជាច្រើនបែបជាច្រើនយ៉ាង ហើយអស់វេលាជាយូរឆ្នាំ ទើបបានសម្រេចកើតជារូបអក្សរមែនៗឡើង ។

## ជនជាតិណោ ជាអ្នកផ្តើមគំនិតបង្កើតតួអក្សរជាដើមដំបូងបង្អស់ ?

តាមដែលអ្នកប្រាជ្ញបុរាណគិត និងអ្នកប្រាជ្ញប្រវត្តិសាស្ត្របានស្រាវជ្រាវមកហើយ ប្រាកដថា៖ ជនជាតិហ្វេនីស៊ៀននៅប្រទេស ហ្វេនីស៊ី សឹងមានភូមិភាគតាំងនៅឆ្នេរសមុទ្រមេឌីទែរ៉ាណេប៉ែកខាងកើត ជាអ្នកបានបាត់សាងតួអក្សរ

សម្រេចឡើងជាដំបូងបង្អស់ គឺធ្វើជាតួអក្សរមែនៗ មិនមែនយករូបសត្វ-វត្ថុផ្សេងៗមកសន្មតប្រើជាសំគាល់ដូចយ៉ាងដែលពួកគេហ្ស៊ីប នឹងចិនធ្លាប់ប្រើមកហើយនោះទេ ។

អក្សរហ្វេនីស្យ៉េងនេះ បានចាប់កំណើតឡើងក្នុងលោកជាដំបូង ហើយបានទៅជាដើមត្រកូលរបស់អក្សរនៃជាតិផ្សេងៗក្នុងលោកមក គឺអក្សរក្រិក អក្សរឡាតាំង អក្សរអេរ៉ុប នឹងអក្សរព្រាហ្មីនៅជម្ពូទ្វីប (ឥណ្ឌា) ដោយជាតិទាំងអម្បាលនេះបានបម្លងផ្ទេរបែបផែនយកទៅប្រើគេៗរៀងគ្នា ។

អក្សរព្រាហ្មីនោះ គេបានប្រទះឃើញសិលាចារឹករបស់ព្រះបាទអសោកមហារាជនៃប្រទេសមគធៈ នៅក្នុងចំណោមឥណ្ឌា ដែលទ្រង់ឲ្យចារឹកទុកក្នុងរវាងពុទ្ធសករាជ ៣០០ ជាដំបូង ។ អក្សរព្រាហ្មីដែលពោលនេះ គឺពួកព្រាហ្មណ៍ប្រាជ្ញនៅឥណ្ឌា បានផ្តើមស្ថាបនាឡើង ដោយប្រឌិតយកយកតាមបែបអក្សរហ្វេនីស្យ៉េងនោះឯង ។

អក្សរបែបនោះ លុះត្រូវផ្សាយទៅក្នុងនានាប្រទេស , ដែលនៅឆ្ងាយពីគ្នាហើយកន្លងយូរមក វិធីសរសេរក៏សន្សឹមៗ ល្អៀងចេញពីគ្នា ទាល់តែប្រាកដទៅជាបែបផ្សេងៗ គ្នាៗ សេចក្ដីពិតអក្សរតម្បាលនោះ ចេញពីអក្សរហ្វេនីស្យែនទាំងអស់គ្នាៗ តាមដែលសង្កេតឃើញមកហើយ អក្សរព្រាហ្មី ដែលផ្សាយនៅដែនឥណ្ឌាភាគខាងជើង មានរូបលក្ខណៈជាជ្រុងៗ ទំនងប្រហែលអក្សរខមរបស់យើងក្នុងបច្ចុប្បន្ន អក្សរបែបនេះគេហៅថា ណាគរី ឬ ទេវណាគរី ។ អក្សរព្រាហ្មី ដែលផ្សាយទៅក្នុងដែនឥណ្ឌាភាគខាងត្បូងមានរូបលក្ខណៈ ទ្រង់មូលៗ ប្រហែលនឹងអក្សរមូលរបស់យើង អក្សរបែបនេះ គេហៅថាគ្ឫន្ថៈ (គ្រន្ថៈ) ។ អក្សរខ្មែរនឹងអក្សរមន ជាអំបូរ អក្សរគ្ឫន្ថៈនេះ ។

តាមប្រវត្តិសាស្ត្រ និងតាមភស្តុតាងដែលមាននៅក្នុង បច្ចុប្បន្ននេះ ប្រាកដជាតិខ្មែរជាជាតិ១ដែលមានអារ្យធម៌ខ្ពង់-

ខ្ពស់ ជាងជាតិទាំងឡាយបណ្ដាប្រទេសក្នុងដែនសុវណ្ណ - ភូមិ ។ ជាតិទាំងឡាយដែលនៅក្រោមឥទ្ធិពលខ្មែរ ឬនៅជិតខាងប្រទេសខ្មែរ សុទ្ធតែបានទទួលរស្មីអក្សរធម៌ខ្មែរស្ទើរតែទាំងអស់ ដោយហេតុនេះ ជាតិខ្មែរទើបមានគតិកេតនាមជាកិត្តិយសប្រាកដនៅក្នុងប្រវត្តិសាស្ត្រថាជា “ឥណ្ឌាទី២នៅក្នុងដែនសុវណ្ណភូមិ ” គឺជាដែនកណ្ដាលនៃការផ្សាយអក្សរធម៌ពីឥណ្ឌាមក ហើយបញ្ជូនទៅឲ្យប្រទេសជិតខាងទៀត, ពោលដោយចំពោះជាតិថៃ(សៀម) និងជាតិលាវសុទ្ធតែបានទទួលអក្សរធម៌មានបែបអក្សរ និងទំនៀមទម្លាប់ជាដើមទៅអំពីខ្មែរ ទៅជាសម្បត្តិរបស់ខ្លួនទំនងដូចជានិរូម ជាដែនកណ្ដាលនៃការផ្សាយអក្សរធម៌ក្រិកដែរ ។ ក្នុងសៀវភៅ “ដំ-ណាលអក្សរថៃ „ ថាពួកថៃស្យាមនិងលាវលានឆាងធ្លាប់ប្រើភាសានិងអក្សរខ្មែរ ក្នុងផ្ទីការរួចមកហើយ ។

២ ) អក្សរមិនមែនគ្រាន់តែជាគ្រឿងកត់ត្រារឿងរ៉ាវផ្សេង ៗ

ដូចដែលពោលមកខាងលើនោះទេ រមែងមានគុណានុភាព ជាគ្រឿងសំគាល់ជាតិដ៏សំខាន់ ១ យ៉ាងទៀតផង ។ ពិតដូច្នេះ គង់លោកនេះនឹងស្គាល់ថា ជាជាតិនេះ ជាជាតិនោះបាន ក៏ដោយសារតែលក្ខណៈអក្សរនិងភាសា គឺយ៉ាងដូចជនបទណាគេប្រើអក្សរអ្វី និយាយភាសាអ្វី គេក៏សំគាល់ថា មនុស្សនៅក្នុងជនបទនោះ ជាជាតិនេះ ជាជាតិនោះ ដូចយ៉ាងខ្មែរនៅកម្ពុជក្រោមសព្វថ្ងៃ ដែលនៅប្រើអក្សរខ្មែរនិយាយភាសាខ្មែរនៅឡើយ នានាជាតិគេរមែងស្គាល់បានថាជាខ្មែរ ដោយមិនមានងឿងឆ្ងល់អ្វី ។ ចុះបើខ្មែរបោះបង់ចោលអក្សរខ្លួន ភាសារបស់ខ្លួនហើយ តើគេនឹងស្គាល់ជាជាតិខ្មែរបានដោយកលអ្វី? ព្រោះដូច្នេះ ទើបមានគតិភាសិតក្រើនទុកថា អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលចារិករបស់ជាតិ កាលអក្សរសាស្ត្រលិចហើយ ជាតិក៏រលាយដែរ ។

៣ – ខ្ញុំជាកុលបុត្រ កុលធីតារបស់ជាតិមានករណីយ៍

ត្រូវតែស្នេហាអក្សរ ភាសារបស់ជាតិ, ខ្ញុំសូមសារភាពថា នឹងខំព្យាយាមសិក្សាអប់រំឲ្យមានសេចក្ដីចេះដឹងអក្សរ ភាសារបស់ជាតិ យ៉ាងហោចត្រឹមប្រើការបាន ហើយនឹងប្រឹងប្រែងប្រើអក្សរភាសារបស់ជាតិឲ្យបានរុងរឿងស្មើមុខនឹងគេជានិច្ច ។

## សុភាសិតអក្សរសាស្ត្រនិយម

១)- អក្សរសាស្ត្រខ្មែរត្រូវខ្មែរនិយម ខ្មែរត្រូវខំសិក្សាឲ្យហ្មត់ចត់ ជាគាំទ្រវេយ្យាករណ៍នូវបែបបទ សព្វសន្តតដោយជំនាន់ទាន់សម័យ ។

២) ជាតិខ្មែរដែលនឹងថ្កើងថ្កានបាន ព្រោះតែមានខ្មែរដែលស៊ីវិល័យ និយមអក្សរជាតិជាប្រពៃ ជានិស្ស័យជាប់នៅគ្រប់សន្តាន ។

៣)- ជាតិខ្មែរដែលនឹងបែរជាសាបសូន្យ ព្រោះតែកូនខ្មែរប្រែវិញ្ញាណ ពុំសួយភាសាជាតិឲ្យថ្កើងថ្កាន ងប់គ្រប់ប្រាណនិយមប្រែបជាតិដទៃ ។

៤) – ពិត។ អក្សរជាតិជាជីវិតជាតិ ត្រូវខ្នះខ្នែង សិក្សាឲ្យថ្នាថ្ងៃ ក្រោយនោះទើបត្រូវសិក្សាសាស្រ្តដទៃ ជាបច្ច័យនូវវិជ្ជាសព្វសាកល ។

ស្រង់ចេញពីអត្ថបទ ឧកញ៉ាទេពពិទូឈឹម-ក្រសេម

ឧង - ឈុំ

# យ៉ាងណាដែលហៅថាភាសាខ្មែរ ?

( កែសម្រួលសេចក្តីរបស់លោក អៀវ-កើស )

## ១ - ភាសា (Langage)

អ្វីដែលហៅថាភាសា ? តាមសេចក្តីធ្លាយទូលាយរបស់ពាក្យ ភាសាគឺការបញ្ចេញសម្ដែងមកក្រៅដែលជាផលនៃគំនិតរបស់ចិត្ត គឺសម្ដែងរបស់ចិត្តនោះឯង ។ មនុស្សគ ឬមនុស្សដែលមានភាសាផ្សេងគ្នា ស្តាប់គ្នាពុំបាន យកដៃទះពោះហើយបន្តុលមាត់ ដើម្បីសំដែងសេចក្តីស្រេកឃ្លាន ឬលាតបាតដៃដាក់ឯបនែបទៅនឹងត្រចៀក ហើយផ្អៀងក្បាលទៅលើដៃនោះ ដើម្បីសំដែងសេចក្តីថាដេក ឬក៏ធ្វើសញ្ញាដោយមេដៃមួយ បញ្ឈរថាជាចៅហ្វាយ ឬមេជុំក៏ដាក់បន្តុល

ដៃទាំងពីរឯបភ្ជាប់គ្នា មានន័យថាមានគូស្រករហើយ ។ ទាំងនេះក៏ជាភាសាមួយយ៉ាងដែរ ៖ គេហៅថា ភាសាគ (Langage muet ou langage d'action)

មាន់ឈ្មោលកាលបើរកពយសប្បាយចិត្ត រងាវ, មាន់ញីកាលរកឃើញពងរកាត, ដល់ពងរួច រក្កត ; ឆ្កែបក់កន្ទុយដើម្បីសំដែងសេចក្តីគោរព ; ចក់ៗ នៅជ្រុងជញ្ជាំង គឺជីងចក់, ក្រេតៗនៅគុម្ពោតក្នុងសួនច្បារមុខផ្ទះខ្ញុំ គឺចង្រិត, អ៊ូៗ ឬ ថ្ងែងៗ កែក្រៀកលើងនេះគឺមូស ទាំងនេះក៏ជាភាសាមួយដែរ ៖ គេហៅថា ភាសាសត្វ (Langage d'animaux) ។

រួមសេចក្តីទៅ ភាសាគឺត្រឹមតែការសំដែងចិត្តគំនិតគ្រប់យ៉ាងដោយការសរសេរ ឬ ដោយពាក្យសំដី (par l'écriture ou par la parole)

ដូចនេះ ភាសាខ្មែរ គឺជាវិធីធ្វើដោយឡែក (procédé particulier) ដែលប្រជាជនខ្មែរបញ្ចេញ ឬ យល់ចិត្តគំនិត

(idées) គ្នាទៅវិញមកតាមសំដី ឬតាមការសរសេរ ។

ភាសាខ្មែរ តាមដែលនិយាយក្នុងដំបន់ផ្សេង ៗ មិនដូចគ្នាទាំងអស់ទេ ល្អៀងពីគ្នាទៅដោយសម្លេង ឬដោយពាក្យដែលមានប្រើនៅទីនេះ ហើយមិនប្រើនៅទីនោះ ឬល្អៀងគ្នាដោយសេចក្ដីរបស់ពាក្យដែលមានន័យដូចនេះ នៅទីនេះ ហើយមានន័យផ្សេងទៀតនៅទីនោះ (ឧ. ដាក់ត្រពោក អន្ទុយ) ។

អ្នកសៀមរាប, អ្នកសុរិន្ទ, អ្នកភ្នំពេញ, អ្នកតាកែវ, អ្នកក្រចេះ, អ្នកបាសាក់ព្រះត្រពាំង និយាយមិនដូចគ្នាទាំងអស់ទេ ខ្លះជើន ៗ ចង់កាត់តាមខ្យល់សៀម, ខ្លះនិយាយញាប់ ខ្លះទៀតម្យ៉ាយ ៗ តាមខ្យល់យួន ៗ បែបនិយាយដែលឃ្លៀងឃ្លាតពីគ្នាទៅតាមដំបន់នេះ បណ្ឌិតហៅថា " គ្រាម·ភាសា ,, (គឺភាសាទៅតាមប្រជុំភូមិ, ស្រុក dialecte) ។ គ្រាម·ភាសាទាំងនេះមិនមែនខុសគ្នាដល់ទៅស្ដាប់គ្នាមិនបាន គេន

រកភាសាបរិវត្តកៈ (លៀមឬអ្នកបកប្រែភាសា Interprète) នោះទេ, សុទ្ធសឹងតែជាគ្រាមភាសាខ្មែរទាំងអស់ ។

អ្នកទាំងអស់នេះ សុទ្ធតែប្រកាន់ថា គ្រាមភាសារបស់ខ្លួន ជាភាសាដើមរបស់ខ្មែរពិត ៗ តាមពិត គ្រាមភាសារបស់ទីក្រុងធំ រមែងចំជាភាសារបស់ជាតិជាងគ្រាមភាសាឯទៀត ដ្បិតគ្រាមភាសាទីក្រុងរមែងពង្រីកផ្សាយបញ្ចេញទៅព្រមទាំងអំណាចរាជការទូទៅក្នុងព្រះរាជាណាចក្រ តែមិនមែនជាភាសាខ្មែរដោយចំពេញទីនោះទេ ។

ដូចជាសម្លេងព្យញ្ជនៈ "រ" នឹងសម្លេងស្រៈ ‘‘អ៊ា,, អ្នកភ្នំពេញច្រើនថាមិនត្រូវ ឯអ្នកជាយដែនច្រើនថាត្រូវ ។ ត្រង់ស្រៈ ‘‘អ៊ា,, នេះតាមសម្លេងអ្នកបាត់ដំបងឬអ្នកកំពង់ចាម មិនគាបច្រឡំស្រៈ ‘‘អៀ,, បានដូចតាមសម្លេងអ្នកទីក្រុងឬអ្នកនៅភាគកណ្ដាលឡើយ ។ ប៉ុន្តែអ្នកបាត់ដំបងថាសម្លេង ‘‘អ៊ី, អ៊ែ,, មិនត្រូវ ។ បណ្ដាជនភាគច្រើន គានពាក្យគ្រប់នឹងគ្រប់

នំនឹងនំ , មែននឹងម៉ែន ធ្វើសម្រេចឲ្យខុសគ្នាពុំបានឡើយ ។ សំពង់ខ្យល់ “ រ ,, អ្នកខេត្តតាកែវថាត្រូវជាងគេ គ្រាមភាសាខ្លះទៀតច្រើនតែលេបប្តូរបៀមខ្យល់ “ រ ,, នេះ ។ សំពង់ខ្យល់ដទៃទៀតមាន “ ក ,, ជាដើម ខ្មែរក្នុងកណាបក្រកម្ពុជា ថាមិនត្រូវចំ ឧ. កាក់, បាក់ , ប្រាក់ ច្រើនតែថា “ កៈ , បៈ , ប្រៈ មាននៅខ្មែរស្រុកក្រោមទៅដែលគានត្រូវចំខ្យល់ ប៉ុន្តែដូចជាសង្កត់វែងហួសបន្តិច ។

គ្រាមភាសានេះ មិនមែនមានតែនៅប្រទេសយើងនេះទេ ប្រទេសគេដ៏ទៃក៏តែសម្បូណ៌គ្រាមភាសានេះទៅទៀត ។

ភាសាខ្មែរ ជាភាសារបស់ជនជាតិខ្មែរទាំងអស់គ្នា ។ អ្នកក៏និយាយខ្មែរ ខ្ញុំក៏និយាយខ្មែរ យើងស្ដាប់គ្នាបានដោយពេញទី ។ ប៉ុន្តែបើតាមសង្កេត បែបនិយាយរបស់អ្នក គង់ខុសពីបែបនិយាយរបស់ខ្ញុំខ្លះជាពុំខាន ។ ក្នុងសម័យក្រោយនិយាយមិនដូចជីតារបស់វាទេ ។ ភាសាគ្រឹហាវាស ល្បឿន

ពីភាសាបញ្ជិត នឹងភាសាក្សត្រិយ៍ ។ ឯភាសាការក្សអ្នកតា ផ្សេងពីនេះទៅទៀត ដូចជាពាក្យ តាការសាហារ (ស្រា) ពន់ចាប (អ្នកដែលខ្មោចរក្សា) កន្ទុំបាក់ក (បេក) ១ កំប៉ាង (១ រៀល) .. ជាដើម ។

សេចក្ដីសន្និដ្ឋាន. — ភាសាខ្មែរ គឺភាសាកណ្ដាលសំរាប់ជនជាតិខ្មែរទាំងពួង ដោយឥតគិតដល់ទីជំលនឹងឋានៈនៃអ្នកប្រើភាសានោះឡើយ ។

ភាសាកណ្ដាលបើពោលឲ្យចំទៅ មិនមែនជាភាសាយើងនិយាយទេ គឺជាភាសាសរសេរ ។ សូមមើលកន្លែងមេរៀន " ធាតុនៃភាសា ,, ។

## ២ ធាតុនៃភាសា (Racine du langage)

មុននឹងអធិប្បាយកន្លែងមេរៀននេះ ខ្ញុំជឿជាក់ថាអ្នកមុខជាប្រឡំថា "ធាតុនៃភាសា,, (racine du langage) ក៏ដូចគ្នានឹង "ប្រវត្តិនៃភាសា (ឬហៅអំបូរនៃភាសាក៏បាន),, L'his-

toire du langage ) នោះដែរ ។

សេចក្ដីពិត ពុំមែនដូចនោះទេ " ធាតុនៃភាសា „ ផ្សេងគ្នាដោយស្រឡះពី " ប្រវត្តិនៃភាសា " ។

ប្រវត្តិនៃភាសា ឬកំប៉ូរនៃភាសា គឺគេអធិប្បាយតាំងពីដើមកំណើតនៃភាសា គឺតាំងពីយុគថ្ម(âge de pierre) ។ យុគថ្មជាសម័យមួយក្នុងភូមិវិទ្យា (géologie) ។ គឺកាលពីដើម មានតែភាសាមួយ ។ បំណោរកាលតមកក៏បែកចេញជាមែកច្រើនទៅៗ ហូតមកដល់មានគ្រប់ប្រទេស ។ ដោយយល់ឃើញថា មិនជាមានសារប្រយោជន៍ប៉ុន្មាន ខ្ញុំមិនលើកយកមកអធិប្បាយទេ ។ ខ្ញុំលើកយកមកសំដែងតែអំពី ធាតុនៃភាសា ។

មនុស្សដែលប្រើភាសាជាមួយគ្នា និយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក ក៏ប្រើភាសាដែរ ; ភាសានេះ គេហៅថាភាសានិយាយ ឬសំដី( langage parlé ) ។ កាលបើ

មនុស្សទាំងនេះនៅឆ្ងាយពីគ្នា ហើយត្រូវការសំដែងចិត្តគំនិតប្រាប់គ្នា គេសរសេរភាសានៅលើក្រដាសផ្ញើទៅវិញទៅមក ភាសាលើក្រដាសនេះ គេហៅថាភាសាសរសេរ ( langage écrit ).

ភាសានិយាយ នឹងភាសាសរសេរ មិនមានដំណើរដូចគ្នាទេ ភាសានិយាយមានដំណើរលឿនជាងភាសាសរសេរជាដរាប ។ ពាក្យខ្លះគេនិយាយ តែគេមិនសរសេរ ៖ ឧ. អញ្ចឹងហើយ, អញ្ចឹង ៗ មិនឲ្យដេរស្អិតណាបាន ! មុំង ៗ បានជាអញ្ចឹង... ។ ពាក្យខ្លះគេសរសេរ ប៉ុន្តែគេមិននិយាយ ឧ. ដ៏ណោះ, ដ៏ឡុង... ។

ភាសាដែលគេលែងប្រើទៅហើយគ្មានគេនិយាយ ហៅថាភាសាស្លាប់( langues mortes )ដូចភាសាសំស្ក្រឹត, បាលី ឡាតាំង, ក្រិក... ។ ភាសាស្លាប់ទាំងនេះដែលគេរៀបចំទុករួចមកហើយ នៅនឹងដដែលឥតប្រែប្រួល ព្រោះឥតជីវិត ។

ភាសាដែលគេនៅប្រើក្នុងការនិយាយ ហៅថាភាសារស់ (langues vivantes) ។ ឯភាសារស់នេះតែងប្រែប្រួលគតមានឈប់ឈរ ។ ដូចជាសព្វថ្ងៃនេះ គណៈកម្មការវប្បធម៌កំពុងតែជ្រើសរើសពាក្យថ្មី ដើម្បីបង្កើតពាក្យឲ្យបានសម្បូណ៌ឲ្យទាន់ការវប្បធម៌ ។

មិត្តខ្លះសួរមកខ្ញុំវិញថា – បើកាលណាយើងយល់ថារូបពាក្យឬអក្ខរាវិរុទ្ធ (orthographe) ដែលមាននៅក្នុងវចនានុក្រមនោះខុសស្រឡះសោះ តើយើងនៅតែត្រូវសរសេរតាមដែរឬអ្វី? ខ្ញុំយល់ថា ត្រូវតែសរសេរតាមជាដរាប ដើម្បីគោរពដល់វិន័យ (discipline) ។ វិន័យត្រង់នេះមានសារៈសំខាន់ដល់ជាតិជាច្រើន ព្រោះថាបើយើងនៅតែសរសេររូបពាក្យតាមទំនើងចិត្តរៀងខ្លួន ភាសាយើងនឹងរាប់ថាជាភាសាជាតិពុំបាន ព្រោះគ្មានគោលចារឹក ហើយជាតិយើងនឹងរាប់ថាជាប្រជាជាតិ (Nation) មួយពុំសម ។

ម្យ៉ាងទៀត ខ្ញុំមានសង្ស័យថា គណៈកម្មការវប្បធម៌ដែល

មានសម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន-ណាត ជាប្រធាន មុខនឹងជាការតែងបង្កើតពាក្យឲ្យសម្បូណ៌មានគ្រប់គ្រាន់នឹងប្រើ ដូចជាខាងវិទ្យាសាស្ត្រ (Sciences) ខាងអក្សរលេខសាស្ត្រ (algébre) ខាងរេខាគណិត-សាស្ត្រ (géométrie) ខាងពេទ្យវិទ្យា (médecine) ខាងភូមិវិទ្យា (géologie) ជាដើម ៗ ហើយទៅអនាគតកាល យើងកាន់តែសម្បូណ៌ក្នុងនិពន្ធអក្សរ-សាស្ត្រ បបួលគ្នាបង្កើតពាក្យដែលគណៈកម្មការវប្បធម៌ជ្រើសរើសមក ហើយបញ្ចូលទៅក្នុងវចនានុក្រមបង្កើតបានជាសព្វវចនាធិប្បាយ (dictionnaire encycl-opédique) ហើយយូរទៅនឹងមានទីប្រជុំអ្នកប្រាជ្ញខាងអក្សរសាស្ត្រ ឬបណ្ឌិតសភា (académie) មួយសំរាប់ពិចារណាការកាត់អំពីរឿងអក្សរសាស្ត្រ ឬ តម្រូវឲ្យកែប្រែក្បួនច្បាប់ឲ្យមានបរិបូណ៌តាមវឌ្ឍនធម៌ ៗ ប្រជានិករខ្មែរក៏នឹងបានចំរើនវិទ្យា-ឋានៈ (niveau d'éducation ou degré d'instruction)

ខ្ពស់ទៀតដូចក្នុងប្រទេសថៃ ។

## លក្ខណៈនៃភាសា
## (Caractères individuels du langage)

ពាក្យទាំងឡាយក្នុងភាសានីមួយ ៗ យើងអាចយកមកពិនិត្យទៅតាមផ្លូវ ៣ គឺ៖

១ – សូរសាស្ត្រ, (phonétique) គឺពិនិត្យខាងសម្លេងនិងវិធីអាន

២ – រូបសាស្ត្រ (morphologie) គឺពិនិត្យខាងរូបរបស់ពាក្យដែលប្រែប្រួលទៅតាមលិង្គ, វចនៈ, បុរសៈ, កាល និងមុខងាររបស់ពាក្យក្នុងប្រយោគ ។ ការប្រែប្រួលបែបនេះមាន

ច្រើនសម្បូណ៌ក្នុងភាសា ឥណ្ឌូ·អឺរ៉ុប ដូចជាសំស្ក្រឹត, បាលី និង ភាសាក្នុងទ្វីបអឺរ៉ុប ។ ក្នុងភាសាយើងមិនសូវមានទេ ។

៣ - និយណ្ឌសាស្ត្រ (អានថា និយាន់·ដះសាស) (Sémantique)គឺពិនិត្យខាងអត្ថរបស់ពាក្យ ព្រមទាំងប្រវត្តិរបស់ពាក្យ ។

របស់ទាំង៣ យ៉ាងនេះជាបុគ្គលិកលក្ខណៈ នៃភាសានីមួយ ៗ ។

# វិធីអានអក្សរខ្មែរ

គ្រប់ភាសា ការហាត់អានជាការចាំបាច់នឹងខានពុំបានឡើយ ។ ខ្មែរយើងក្នុងសម័យបុរាណ លោកមិនបណ្ដោយឲ្យអានតាមទំនើងចិត្តនោះទេ ។

---

ដូចនេះ របៀបអានជាវិធីមួយ ដែលអ្នកសិក្សាគប្បីសង្កេតឲ្យច្បាស់អានឲ្យត្រូវ ព្រោះថាបើអានខុសនឹងខូចសេចក្ដីស្ដាប់ពុំបាន ហើយនាំឲ្យអផ្សុកត្រចៀកអ្នកស្ដាប់ផង ។

ដើម្បីអានឲ្យត្រឹមត្រូវ តាមសម្ពស្សព្យញ្ជនៈ ឬតាមលំនាំភាសាខ្មែរ អ្នកអានត្រូវចេះនូវលក្ខណៈបីយ៉ាង គឺ ៖

១ – ត្រូវដឹងកំណើតព្យញ្ជនៈ

២ – ត្រូវស្គាល់ព្យញ្ជនៈ ឃោសៈ – អឃោសៈ

៣ – ត្រូវចេះភាសានិយម

លក្ខណៈទី ១ ខាងលើនេះ មានចែងក្នុងវេយ្យាករណ៍

ស្រាប់ ខ្ញុំសូមលើកយកខទី ២ និងខទី ៣ មកនិយាយតែម្តង

## ១ – ព្យញ្ជនៈ ឃោសៈ អឃោសៈ

ព្យញ្ជនៈទាំង ៣៣ តួនោះ ចែកចេញជា ២ ពួកគឺ៖

១ – ព្យញ្ជនៈ ដែលមានសម្លេងមិនគឹកកង ហៅថា

អឃោសៈមាន ១១ តួគឺ៖ កខ, ចឆ, ដឋ, តថ, បផ, ស

២ – ព្យញ្ជនៈ ដែលមានសម្លេងគឹកកង ហៅថា ឃោ

សៈ មាន ២១ តួគឺ៖ គឃង, ជឈញ, ឌឍណ, ទធន

ពភម, យរលវហឡ, អ ជាឃោសាឃោសវិមុត្ត (១)

(១)- នេះតាមលទ្ធិខាងភាសាសំស្ក្រឹត រាប់បញ្ចូលក្នុងពួកឃោសៈ ល
ខាងភាសាបាលីចាត់ជាឃោសាឃោសវិមុត្តិ គឺផុតអំពីឃោសៈ,និងអឃោសៈ

# លំនាំអាន

ព្យញ្ជនៈដែលជាទ្វេព្យាង្គដូច „សាលា វិហារ គ្រឹហា„ ជាដើម បើព្យញ្ជនៈខាងដើមជាឃោសៈ ឬអឃោសៈ ព្យញ្ជនៈខាងចុងជាវគ្គន្តៈ (ទីបំផុតនៃវគ្គ) ៥ តួគឺៈ ង, ញ, ណ, ន, ម, និងសេសវគ្គ ៦ តួគឺៈ យ, រ, ល, វ, ហ, ឡ, ត្រូវគានផលតាមព្យញ្ជនៈខាងដើម ដូចពាក្យថា ៖

ង - ប្រងាង (ប្រងាអឃោសៈ, ងាង ជាឃោសៈ) អានថា ប្រង៉ាង;
ញ - កញ្ចម (កំ „ ញម „) „ កញ៉ម;
ណ - ពាណិជ (ពា „ ; ណិជ „) „ ពានិច,
ន - សំនឹក (សំ „ ; នឹក „) „សំណឹក;
ម - ប្រមុះ (ប្រ „ ; មុះ „) „ ប្រម៉ុះ;
យ - ស្រយាល (ស្រ „ ; យាល „) „ ស្រយ៉ាល;
រ - ដរាប (ដ „ ; រាប „) „ ដរ៉ាប;
ល - សន្លឹក (សន់ „ ; លឹក „) „សនឡឹក;

រ- គ្រាក់ (ក្រ " : រាក់ " ) " គ្រាក់ ;

ហ- ដំហាន (ដំ " , ហាន " ) " ដំហាន ;

ឡ. គុឡិកា (គុ " ; ឡិ " ) " គុលិកា;

... ដូចនេះជាដើម ។

វៀរលែងតែព្យញ្ជនៈជាវគ្គ១៦តួគឺៈ កខគឃ, ចឆជឈ, ដឋឌឍ, តថទធ, និងសេសវគ្គ ១ តួគឺ៖ "ស" ដែលមានសម្ព័ន្ធ ផ្លស់ទៅតាមព្យញ្ជនៈខាងដើមពុំបាន ហើយមិនត្រូវផ្លស់ផង ដូចពាក្យថា៖

| | | | |
|---|---|---|---|
| ក- និកាយ | ផ្លស់ទៅជា | និគាយ | ពុំបាន |
| ខ- ទក្ខិណា | " | ទគឃិណា | " |
| គ- សង្គម | " | សង់កំ | " |
| ឃ សង្ឃឹម | " | សង់ខឹម | " |
| ច. វិចិត្រ | " | វិជិត | " |
| ឆ- គូឆាយ | " | គូឈាយ | " |

ជ- បញ្ញា ខ្លួលទៅជា បញ្ញា ពុំបាន

ឈ- បញ្ជរ " បញ្ជរ "

ឋ- ពោធារ " ពោធា "

ឋា- តាឋា " តាណា "

ឌ- ប្រឌិត " ប្រដិត "

ឍ- អឌ្ឍមាស " អឌ្ឍមាស "

ត- ជាតស្រះ " ជាទៈស្រះ "

ថ- ពុំថៅ " ពុំធៅ "

ទ- បន្ទាយ " បន្ទាយ "

ធ- បធរ " បន្ធូ "

ស- ពិសា " ពិសា "

... ដូចនេះជាដើម សូមពិនិត្យតាមលំនាំនេះជាដពច ។

## ២ - ភាសានិយម

ភាសាខ្មែរ ប្រើនជាប់តាក់ទងនឹងដោយភាសាបាលី និង

សំស្ក្រឹត ; ដែលជាបាលីនិងសំស្ក្រឹតនោះ ជួនកាលមានតាមលំនាំភាសានោះៗ ក៏មាន , ជួនកាលតាមលំនាំភាសាខ្មែរក៏មាន , ភាសាខ្មែរនិងភាសាខ្មែរមានភ្ជាប់និងសម្លេង “ ហ ” តាមចំនួនសេចក្តីសរសេរថា ៖

| | | |
|---|---|---|
| លោកអើយ | អានថា | លោកអ្ហើយ |
| នាងអើយ | " | នាងអ្ហើយ |
| សម្លាញ់អើយ | " | សម្លាញ់អ្ហើយ |
| ព្រះអង្គអើយ | " | ព្រះអង្គអ្ហើយ |
| ទុក្ខអើយ | " | ទុក្ខអ្ហើយ |
| ព្រះពុទ្ធអើយ | " | ព្រះពុទ្ធអ្ហើយ |
| ពុទ្ធោកម្មក្រាស់អើយ | " | ពុទ្ធោកម្មក្រាស់អ្ហើយ |
| ទេវតាអើយ | " | ទេវតាអ្ហើយ |

. . . ដូចនេះជាដើម ៗ

ម្យ៉ាងទៀតមានភ្ជាប់សម្លេងគ្នាក៏មានដូចជា ៖

| | | |
|---|---|---|
| លោកអើយ | អានថា | លោកកើយ |
| បងអើយ | " | បងង៉ើយ |
| នាងអើយ | " | នាងង៉ើយ |
| យាយអើយ | " | យាយយ៉ើយ |
| ម្ចាស់អើយ | " | ម្ចាស់ស៊ើយ |
| សម្លាញ់អើយ | " | សម្លាញ់ញ៉ើយ |

- បើពាក្យប្រកបផ្សំឲ្យសំលេងមិនស្រួលស្ដាប់ ដូចជា (ព្រះអង្គអើយ, ព្រះពុទ្ធអើយ, ភិក្ខុអើយ, ទុក្ខអើយ ...) យ៉ាងនេះគេថា "ហ៊ើយ" ជាដាច់ខាត (កុំថា ព្រះអង់គើយ, ព្រះពុទធើយ, ភិកខ៊ើយ, ទុកខើយ ... ។

ម្យ៉ាងវិញទៀត បើពាក្យដែលឥតអក្សរប្រកប ដូចជា៖ តាអើយ, មាអើយ, ពូអើយ, ទេវតាអើយ, យ៉ាងនេះក៏, គេថាបានតែ "ហ៊ើយ" ដែរ (កុំថាតារ៉ើយ, មារ៉ើយ, ពូរ៉ើយ, ទេវតារ៉ើយ យ៉ាងដូចនេះឡើយ) ។

ចំណែកពាក្យ „ហោង„ នេះត្រូវមើលថា "អ្ហង„ មិនត្រូវអានឲ្យចំដូចរូបពាក្យនោះទេ ដូចជា៖ ជាសុខហោង, សម្រេចបុណ្យហោង, ចប់តែប៉ុណ្ណោះហោង ... ត្រូវអានថា ជាសុខអ្ហង, សម្រេចបុណ្យអ្ហង, ចប់តែប៉ុណ្ណោះអ្ហង... ។

មិនតែប៉ុណ្ណោះ ខ្ញុំតែងឮជាញឹកញយ ចំពោះមនុស្សដែលមិនចេះអានពាក្យ "ពិភពលោក, ប្រតិបត្តិការ, ពិភាក្សា, រដ្ឋការ, រដ្ឋាភិបាល, អតីតរដ្ឋមន្ត្រី, បណ្ណាគារ, អគ្គបញ្ជាការ, អនាគតកាល, សមាគតរដ្ឋ, រដ្ឋប្បវេណី, ប្រជាធិបតេយ្យ, សេរីភាព„... ជាដើម ។

ពាក្យទាំងនេះ មិនត្រូវអានថា "ពិភព-ព:លោក, ប្រតិប័ត-តិការ, ពិភ័ក-សា, រដ្ឋ:-ការ, រដ្ឋ:-ភិបាល, អតីត:-រដ្ឋមន្ត្រី, បណ្ណ:-គារ អគ្គ:ប័ញ្ជ:-ការ, អនាគត់-កាល, សមាគត់-រដ្ឋ, រដ្ឋប៉:-វេណី. ប្រជាធិប:-តី, សេរ:-ភាព„

នោះទេ ។

ត្រូវតាមថា "ពិភព-លោក, ប្រតិបត្តការ, ពិភាក-សា, វេជ្ជា-ករ, វេជ្ជា-ភិបាល, អធិក-វេជ្ជមន្ត្រី, ប័ណ្ណា-គារ, អគ្គ:បញ្ជា-ការ, អ: នា៉គត-ត:កាល, ស:មា៉-គត-ត:-វេជ្ជ, វេជ្ជ័-ប៉:វេទី, ប្រជាធិប:-តៃ, សេរី-ភាព", យ៉ាងនេះ ទើបត្រូវ ។

ឯរបៀបតាមភាសាបាលីឬសំស្ក្រឹត ដែលនិយមមក តាមលំនាំភាសាខ្មែរនោះមានគ្រឿងចំណាំ ៤ យ៉ាងគឺ៖

១ - និយមដោយ យុគលពិន្ទុ

២ - និយមដោយ សំយោគសញ្ញា

៣ - និយមដោយ បដិសេធ

៤ - និយមដោយ សម្រួលភាសា

## ក) និយមដោយយុគលពិន្ទុ

សញ្ញា ":" នេះហៅថាយុគលពិន្ទុសម្រាប់ប្រើសម្រួល

ពាក្យឲ្យឆ្ងាយគាន បើពាក្យនោះមានយុគលពិន្ទុនៅខាងចុង ត្រូវគានឲ្យចេញសម្លេងខាងចុងបំផុត ប៉ុន្តែកុំឲ្យអក្សរនោះមានសូរជាគ្គប្រកប, បើអក្សរខាងចុងបំផុតនោះ ជាស្រៈ "អ" ត្រូវគានឲ្យឮសូរជា "អៈ" (សម្លេងបាលីនិងសំស្រ្កិតពេញទី) ដូចពាក្យថា៖

| | | |
|---|---|---|
| លក្ខណៈ | កុំអានថា | ល័ក-ខន |
| គាៈ | " | គា |
| យុគៈ | " | យុគ |
| កាលៈ | " | កាល |
| ទេសៈ | " | ទេស |

...ជាដើម ។

មួយវិញទៀត ត្រូវប្រយ័ត្ន កុំសរសេររូបយុគលពិន្ទុ "ៈ" នេះ ឲ្យច្រឡំនឹងវិសជ្ជនីយ រង្វង់មូលពីរធំៗ "ះ" ឬនឹងចំណុចពីរ "៖" ក្នុងខណ្ឌសញ្ញានេះឡើយ ។

## ខ) និយមដោយសំយោគសញ្ញា

សញ្ញានេះ " ័ " ហៅថា សំយោគសញ្ញា សម្រាប់ដាក់លើពាក្យបាលីឬសំស្រ្កឹតពួកខ្លះ ដើម្បីបំប្លែងសម្លេង ឲ្យក្លាយល្អៀងពីសូរដើម ដូចពាក្យថា៖ អធ្យាស្រ័យ, អនាម័យ, ជ័យ, ក្ស័យ, សម័យ, អាល័យ, ពិន័យ, បច្ច័យ, វិជ័យ, វេស្ម័ន, នង្គ័ល, ភ័យ, អភ័ព្វ, និស្ស័យ, រហ័ស

. ដូចនេះជាដើម ។

ក្នុងភាសាខ្មែរគេមានប្រើខ្លះដែរដូចជា៖ ទទ័រ, ជ័រ, ញ័រ, ទទីទទ័រ, ទព័រ, ក្ឃ័រ, ស្ពានជ័រ, សូរប៉ុង, ទ័ល, ... ដូចនេះជាដើម ។

## គ) និយមដោយបដិសេធ

សញ្ញា " ៍ " នេះហៅថាបដិសេធឬទណ្ឌឃាដសម្រាប់ប្រើបំបាត់សូរព្យញ្ជនៈចោលដូចពាក្យថា៖

| | | |
|---|---|---|
| ការណ៍ | អានថា | ការ |
| ប្រយោជន៍ | " | ប្រយោច |
| ធាកយណ៍ | " | ធាក៉យ |
| ប្រសាសន៍ | " | ប្រសាស |
| ប្រវ័ញ្ចន៍ | " | ប្រវ័ញ |
| គោឃាតក៍ | " | គោឃាត |

... យ៉ាងនេះជាដើម ។

## ឃ) និយមដោយសម្រួលភាសា

ក្នុងប្រយោគខ្លះ បើមានពាក្យបាលី ឬសំស្រ្កឹត ជាសព្ទមួយ ៗ ដែលមិនមានយុគលពិន្ទុនៅខាងចុង ត្រូវតែងប្រកបនឹងព្យញ្ជនៈចុងសព្ទរបស់ខ្លួន ពាក្យខ្លះដូចអក្សរប្រកបដែលមានបន្តក់មួយពីលើក៏មានតាមទំនងសេចក្តី ដូចជា ៖

ខ្ញុំជានាយកលើអ្នកកល់គ្នា អានថា — នាយក់ —

ម្ដាយខ្ញុំចិញ្ចឹមសុនខ " — សុណក់ —

កូនខ្ញុំកែលក្អែកម្នាន ..— កែល —

ខ្ញុំកាន់ពាក្យសត្យយូរហើយ ..— ពាក្យសាត់ —

ពុទ្ធរត្នាពេញសកលឥតបន្ទោះ ..— សៈកល់

... ជាដើម ។

ម្យ៉ាងទៀត បើពាក្យនោះមានច្រើនសព្ទ តភ្ជាប់គ្នា ជាបទសមាស, សព្ទខាងដើមត្រូវអានឲ្យត្រៀបញ្ចូនៈ, សព្ទខាងចុងត្រូវអានប្រកបតាមវិធីខាងលើ ដូចពាក្យថា៖

| | | |
|---|---|---|
| ឧដ្ឋានសម័យ | អានថា | អ៊ុត-ឋានៈសៈម៉ុយ |
| អធម្មកម្ម | " | អៈធ័មមៈក័ម |
| សញ្ញាដ្ឋាន | " | ស័ញញចៈរ៉ុត-ឋាន |
| សកលលោក | " | សៈកៈល៉ៈលោក |

... យ៉ាងនេះជាដើម ។

ម្យ៉ាងវិញទៀត ពាក្យខ្លះមានច្រើនសព្ទ ជាបទសមាស ដែរ តែជាបទបំប្លែង គឺបទដែលត្រូវប្តូរយកសព្ទខាងចុងមក

ដាក់ពីខាងដើម ឲ្យដូចតាមរបៀបវេយ្យាករណ៍សំស្រ្កឹតឬបា-
លី, បែបនេះតាមទម្លាប់ ឲ្យអានបញ្ចេញសម្លេងបទកណ្ដាលផង គឺត្រង់ដំណសព្ទ ឲ្យអានសម្លេងប្រកប ដូចពាក្យថា "សាមញ្ញជន" (អានថា សាម័ញ ញ៉ៈជន់) នេះតាមរបៀបវេយ្យាករណ៍; លុះយក "ជន" ដែលជាសព្ទខាងចុងមកដាក់ខាងដើម "សាមញ្ញ" វិញជា "ជនសាមញ្ញ" (អានថាជន់សាម័ញ) មិនត្រូវអានថា (ជៈនៈសាម័ញ) ឡើយ ។

ពាក្យបែបនេះ មានច្រើនដូចតទៅនេះ៖

| បទវេយ្យាករណ៍ | បទបំប្លែង |
|---|---|
| រូបសណ្ឋាន | សណ្ឋានរូប |
| ពេទ្យមន្ទីរ | មន្ទីរពេទ្យ |
| មន្ទីរនាយក | នាយកមន្ទីរ |
| លាភកជន | ជនលាភក |
| បាបមិត្ត | មិត្តបាប |

| | |
|---|---|
| អាកាសធាតុ | ធាតុអាកាស |
| បណ្ឌិតបរិត | បរិតបណ្ឌិត |
| អកុសលកម្ម | កម្មអកុសល |
| សប្បុរសបិត្ត | បិត្តសប្បុរស |
| មិត្តសមាគម | សមាគមមិត្ត |

... ដូចនេះជាដើម ។

មានពាក្យខ្លះដែលពុំមែនជាបទបំប្លែង ក៏មានអានជាបទបំប្លែងខាងលើនេះដែរ ចុំន្តែមានតិចណាស់ដូចជា៖ "កិត្តិយសសមាជិក ជាបទវេយ្យាករណ៍ (អានថា កិត-តិយស់ ស:មាជិក) ពុំដែលជា (កិត តិ-យ:ស:ស:មាជិក) ដូចនេះទេ ជាដើម ។

ភាសានិយមនេះ លំបាកស់គាល់បន្តិច ចំពោះអ្នកដែលពុំបានរេះភាសាបាលី ឬ សំស្រ្កឹត តែបើបានពិនិត្យសង្កេតឡើជាក់ច្បាស់ តាមវិធីដែលបានពណ៌នាមកនេះហើយ អាចនឹងអានភាសាជាតិបានដោយត្រឹមត្រូវ ។

# វេយ្យាករណ៍ខ្មែរ

វេយ្យាករណ៍ខ្មែរជាក្បួនបង្រៀនអក្ខរវិធី ដើម្បីពោល, សរសេរឲ្យបានត្រឹមត្រូវតាមច្បាប់អក្សរសាស្ត្រ(litérature)ៗ

## ១ – ប្រយោគ ( Phrase )

ភាសានិយាយក្តី ភាសាសរសេរក្តី បែកចេញជាច្រើនប្រយោគ ៗ ប្រយោគមួយ ១ គឺជាពាក្យច្រើនផ្គុំគ្នាមានន័យបរិបូណ៌ ហើយចប់ទៅត្រង់វណ្ណយុត្តិខណ្ឌ ៗ ដើម្បីនឹងនិយាយឬសរសេរ គេប្រើពាក្យ ៗ

## ២) – ពាក្យ (Mots)

សព្ទឬគំនូសថា៖ ខ្ញុំ, និយាយ, សរសេរ, ,,ពាក្យ,, ៗ

ពាក្យមួយៗសំកប់បង្អុលទៅតួមួយ, ឬថ្លែងគំនិតមួយ ឬ សំដែង គុណសម្បត្តិ (qualité) ឬគុណវិបត្តិ (défaut) ណាមួយ ។

### ៣-សព្ទ និង តួអក្សរ (Son et corps de l'alphabet)

ពាក្យមួយ មានបន្លឺចេញដោយ "សព្ទមួយ" (un seul son) ឬ "សព្ទច្រើនផ្គុំគ្នា" ។

ដើម្បីនឹងសរសេរសព្ទ គេត្រូវប្រើតួអក្សរ ។

### ៤. អក្សរ ( Alphabet )

ភាសាខ្មែរមានតួអក្សរ៦៨ រួមគ្នាឡើងបានជា "អក្សរ ឬអក្ខរៈឬវណ្ណៈ" ។

### ៥-ស្រៈ និង ព្យញ្ជនៈ ( VoYelle et consonne )

អក្សរបែកចេញជាពីរពួកគឺ ពួកស្រៈនិងពួកព្យញ្ជនៈ ។

### ៦. ព្យាង្គ (SYllable)

ដែលហៅ "ព្យាង្គ", គឺសព្ទ ឬតួអក្សរពាយឬផ្គុំគ្នា ដែលមាន

ឡើងចេញសព្ទតែម្ដង ដូចពាក្យ៖ "ទៅ" មាន ១ ព្យាង្គ, "សាលា" មានពីរព្យាង្គ; "ដំបូន្មាន" មាន ៣ ព្យាង្គ ។

## អក្សរឬអក្ខរៈឬវណ្ណៈ Alphabet

ពាក្យដែលថា "អក្សរ ឬ អក្ខរៈ ឬ វណ្ណៈ" នេះអ្នកប្រាជ្ញទាំងឡាយគ្រប់ប្រទេស លោកសំដៅយកហេតុ ២ យ៉ាងមករួមឲ្យឈ្មោះគឺ៖ សូរសម្លេងដែលលាន់ឮព្រោកដឡើង ១ (សព្ទ), ស្នាមគំនូសជាតួពងដែលលូមកំណត់ចំណាំបានតាមស្រួល ១ (តួអក្សរ), ទាំងពីរយ៉ាងនេះរួមមកហៅតែពាក្យមួយមាត់ថា "អក្សរ ឬ អក្ខរៈ ឬ វណ្ណៈ" ក៏បាន ។

អក្សរសម្រាប់ប្រើក្នុងភាសាខ្មែរយើង មាន ៦៨ តួ គឺ៖

អ អា ឥ ឦ ឧ ឩ, ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ មាន ១៥ តួនេះ៖

ហៅថា "ស្រៈពេញតួ" ។ – ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ២០ តួនេះ ហៅថា ស្រៈនិស្ស័យ ។

ក ខ គ ឃ ង, ច ឆ ជ ឈ ញ, ដ ឋ ឌ ឍ ណ, ត ថ ទ ធ ន, ប ផ ព ភ ម, យ រ ល វ, ស ហ ឡ អ នេះហៅថា ព្យញ្ជនៈ ។

## របៀបសរសេរអក្សរ៖

របៀបសរសេរអក្សរមានច្រើនយ៉ាងគឺ៖ អក្សរជ្រៀង, អក្សរឈរ, អក្សរខម និងអក្សរមូល ។

– អក្សរជ្រៀង មានសណ្ឋានតួរាងទ្រេត ៗ សម្រាប់សរសេរធម្មតា គឺដូចជាអក្សរពុម្ពតួរាងបញ្ឆៀង ៗ លើទំព័រក្នុងសៀវភៅវេយ្យាករណ៍ខ្មែរទំនើបនេះជាដើម ។

– អក្សរឈរ មានសណ្ឋានតួរាងចំហៀងរមិនពេញតួ សំរាប់សរសេរឈរក្នុងការហែសូត្រ ឬការប្រកាសប្រញាប់ ។

– អក្សរខម គឺជាអក្សរមូលដែរ ប៉ុន្តែបែបភាពខុសពីអក្សរមូលធម្មតាខ្លះ ដោយមានសណ្ឋានតួរាងក្រឡេក ៗ

ធ្ងន់បន្តិច ។ អក្សរខមគេប្រើចារក្នុងសាស្ត្រាស្លឹករឹតឬសរសេរក្នុងក្រាំងតាំងពីក្បួនខ្នាតជាន់ដើម ; ឯសព្វថ្ងៃវិញគេនិយមប្រើតែសំរាប់សរសេរបាលីដូចជាគាថា ក្នុងកខ្សែងយន្តឬសរសេរចំណងជើង (Sous titre) ឬសរសេរស្លាក (étiquette), យីហោ (panneau) ការប្រកាស (Avis) ។ល។

អក្សរមូល មានសណ្ឋានប្រហែលនឹងអក្សរខមដែរ ប៉ុន្តែមានតួពងមិនសូវដេកក្រឡោតខ្លាំងពេកទេ សំរាប់សរសេរ ឬប្រើការប្រហែលគ្នានឹងអក្សរខមដែរ ។

## ស្រៈឬសរៈ (Voyelle)

ស្រៈឬសរៈប្រែថា « ទឹក » ឬថា « បំពេញសម្លេង » គឺអក្សរដែលការបញ្ចេញសំឡេងខ្លួនឯងបានផង ការនាំព្យញ្ជនៈឱ្យបញ្ចេញសំឡេងបាន មានសូរតាមរំពឹងរបស់ព្យញ្ជនៈផង ។ ក្នុងខេមរភាសា ស្រៈមានពីរយ៉ាងគឺ៖

ស្រៈពេញតួ និង ស្រៈនិស្ស័យ ។

## ក– ស្រៈពេញតួ៖

ដែលហៅថា "ស្រៈពេញតួ" នោះ គឺស្រៈប្រើជាតួអក្សរដូចជាតួព្យញ្ជនៈដែរ ដូចពាក្យថា៖ អរគុណ , ឥន្ទ្រិយ៍, ឧត្តរ , ឧស្សាហ៍ , ឯក , ឮហើយ , ព្រះឱស្ឋ , ក្រឪ , ឪឡឹក ឫកវណ្ណ . . . ។

ស្រៈពេញតួដូចបានរាប់រៀបរួចមកមាន ១៥ តួគឺ៖ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។

បំណាំ – ស្រៈពេញតួ "អ" ប្រើជាតួព្យញ្ជនៈបានគឺអាចចំបែកជា "អ អា អិ អី.... ។ ១. ត្រកអរ អារឈើ... ។ ដាក់លើព្យញ្ជនៈឯទៀតបានដូចពាក្យ "អ្នក", ដាក់ពីក្រោមព្យញ្ជនៈឯទៀតបាន ដូចពាក្យថា "ក្អម", កូនខ្ញុំក្អក, សើចក្អាកក្អាយ, សត្វក្អាត់, ស្អាតស្អំ, ស្អកស្អា, ឆ្អិនឆ្អែន, បង្អាង, បង្អែក, បង្អាន, បង្អាប់, បង្អាក់, ស្អប់ ។

ស្ពាន,... យ៉ាងនេះជាដើម ។

ស្រៈពេញតួសម្រាប់ប្រើក្នុងភាសាបាលីមាន ៨ តួ គឺ៖ "ឥ ឦ, ឧ ឩ, ឯ ឱ" ។ សម្រាប់ប្រើក្នុងភាសាសំស្ក្រឹតមាន១៣តួគឺ៖ "ឥ ឦ, ឧ ឩ, ឫ ឬ, ឭ ឮ, ឯ ឰ, ឱ ឳ"; ថែមស្រៈ "ឮ" ជាយថាក្រៃកមកទៀតជា ១៤ តួ ។ សម្រាប់ប្រើក្នុងភាសាខ្មែរ (សម័យបច្ចុប្បន្ននេះ) រាប់ស្រៈដែលផ្សំជាមួយនឹងនិគ្គហិតនឹងវិសជ្ជនីយផងមាន ២១ តួគឺ៖ "អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ អោ អៅ អុំ អំ អាំ អះ"; រាប់តាំង "ឫ ឬ, ឭ ឮ" នឹងស្រៈ "ឳ" ផងជា ២៦ តួ ។

## ១– ស្រៈនិស្ស័យ៖

ដែលហៅថា "ស្រៈនិស្ស័យ" គឺស្រៈដែលអាស្រ័យនឹងព្យញ្ជនៈទើបប្រើបាន ដូចជា៖ ទៅណា, ស៊ុបាយ, ដើរលេង ... ។

ស្រៈនិស្ស័យនេះ ពិតមែនតែបញ្ចេញសម្លេងទៅតាម

ទំនេរ៍បិត្តខ្លួនឯងបាន តែមិនអាចធ្វើសេចក្ដីឲ្យច្បាស់លាស់ ទៅជាអ្វីដោយខ្លួនឯង នោះពុំបានឡើយ ដូចជាសរសេរ ថា "ៅ ៀ ា" មិនយកសេចក្ដីជាជាអ្វីពុំបាន លុះតែ បំពេញ ឬដាក់ព្យញ្ជនៈមួយឬលជាមួយផង នោះទើបប្រាកដ សេចក្ដីថា "ទៅណា" ដូចនេះឡើងបាន ។

ស្រៈនិស្ស័យនេះអាចនាំព្យញ្ជនៈ ឲ្យចេញសម្លេងបាន មានស្វរពុតាមព្យញ្ជនៈដែលជាឃោសៈនិងអឃោសៈ, ចំណែក ស្រៈ៣តួគឺ "-ួ ឿ ៀ" នេះ នោះបើដាក់ផ្សំនឹងព្យញ្ជនៈ មានសម្លេងតិកកងក្ដី មិនតិកកងក្ដី ក៏នៅតែបញ្ចេញសម្លេង ដូចគ្នា ដូចជា អក្សរ "ក" អានថា "កួ-កឿ កៀ" និង "គ" ក៏អានថា "គួ គឿ-គៀ" ដែរ បែបនេះជាតួយ៉ាង ។

ស្រៈនិស្ស័យដូចបានរៀបរាប់មកហើយ មាន ២០ គឺ ៖

-ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។

ចំណាំ - ស្រៈនិស្ស័យ "អ" គ្មានរូបគ្មានអក្ខរទេ ។ ព្យញ្ជនៈ

ទាំងឡាយដែលមានស្រៈ "អ" នៅក្នុងខ្លួនជាដរាប ។ ដូច្នេះ ហើយបានជាអ្នកប្រាជ្ញអក្សរសាស្ត្រ លោកថា ស្រៈនិស្ស័យ មានតែ ២០តួ បើតាមសព្ទមានដល់ទៅ២១សព្ទ ។

ក) ស្រៈខ្លី ឬរស្សស្សរៈ (voyelle brève) ៖

ស្រៈដែលមានសម្លេងខ្លី ហៅតាមភាសាបាលីថា "រស្សស្សរៈ" ។

ស្រៈខ្មែរដែលកប់ថាខ្លីនោះគឺ៖ អិ អឹ អឺ អុ អៃ អៅ អុំ អំ អាំ អះ (១០ អក្ខ) ។

ខ) ស្រៈវែង ឬ ទីឃស្សរៈ ( VoYelle longue ) ៖

ស្រៈដែលមានសម្លេងវែង ហៅតាមភាសាបាលីថា "ទីឃសរៈ" ។

ស្រៈដែលមានសម្លេងវែងនោះគឺ៖ អ អា អី អូ អួ អើ អឿ អៀ អេ អែ អោ (១១អក្ខ) ។

គ) ស្រៈសុទ្ធ និង សំយុត្តស្រៈ ( VoYelle simple et diphtongue ) ៖

ក្នុងភាសាបាលី សំស្ក្រឹត បារាំង គេចែកស្រៈជាស្រៈសុទ្ធ(Voyelle simple) និងស្រៈផ្សំឬសំយុត្តស្រៈ (ភាសាសំយុក-តៈស្រៈ) (diphtongue) ។

ស្រៈសុទ្ធ គឺជាស្រៈដែលគ្មានពួសូរសព្ទលាយឡំនឹងសូរណាឡើយ ។

ស្រៈផ្សំឬសំយុត្តស្រៈ គឺជាស្រៈសុទ្ធបញ្ចូលឬផ្សំជាមួយនឹងស្រៈ ១ អន្លើទៀតដែលជាស្រៈសុទ្ធដែរ ឬ ជាអឌ្ឍ-ស្រៈ (ភាសា អាត់-ធៈស្រៈ (semi-voyelle) ។

ក្នុងភាសាខ្មែរ ការបែងចែកយ៉ាងនេះ និងធ្វើទៅឲ្យ...ក់ច្បាស់ឥតប្រែប្រួលនោះពុំងាយទេ ព្រោះភាសាយើង...ម្បូណ៌ទៅដោយស្រៈជាងភាសាដែលពោលមកហើយនោះ...ច្រើន ។

យើងបានឃើញហើយថា ស្រៈខ្មែរមានលើសពី ២០ អក្ខ ។ បើទុកជាមាន២១ឬត្រឹមតែ២០អក្ខក៏ដោយ សំឡេងស្រៈទាំងនោះ គង់ប្រែប្រួលទៅតាមព្យញ្ជនៈ សម្លេងគ្រលរ (ឃោសៈ) ឬសម្លេងគ្រលួច (អឃោសៈ) ។ កាលបើយើងបញ្ចូលស្រៈ ២០អក្ខនេះ នឹងព្យញ្ជនៈអឃោសៈ ដូចជា ក ស្រៈនោះនឹងទៅជាអឃោសៈ អ អា អិ អី ។ល។ ... កាលបើយើងបែរជាផ្សំស្រៈទាំងនោះ នឹងព្យញ្ជនៈឃោសៈ ដូចជា គ វិញ ស្រៈនោះក៏នឹងប្រែទៅជាឃោសៈ អ៊ អ៊ា អ៊ិ អ៊ី ។ល។...

ដូចនេះស្រៈ ២០ អក្ខ ដោយពិតក៏ត្រឡប់ប្រែទៅជា ៤០ អក្ខ ។

អ អា អិ អី អុ អូ .. ជាស្រៈសុទ្ធ ។

អឺ អួ អៀ អែ អៅ .. ជាសំយុត្តស្រៈ ព្រោះ៖

អឺ គឺ អិ + យ

អួ " អូ + អា

| | | |
|---|---|---|
| អៀ | គឺ | អ + អា |
| អៃ | ” | អា + យ់ |
| អៅ | ” | អា + វ់ |

## ព្យញ្ជនៈ (Consonne)

អក្សរក្រៅពីស្រៈដូចពោលមកហើយ ហៅថា "ព្យញ្ជនៈ" ប្រែថា "អក្សរធ្វើឲ្យប្រាកដ" ។

ព្យញ្ជនៈមាន ៣៣ តួគឺ៖

ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ

ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ អ ។

ព្យញ្ជនៈទាំង ៣៣ តួនេះហៅថា "និស្សិត" ប្រែថា "អក្សរណាតែអាស្រ័យនូវស្រៈផង ទើបចេញសូរសព្ទបាន" គឺថា ព្យញ្ជនៈទាំងអស់សុទ្ធតែអាស្រ័យនឹងស្រៈផង

ទើបអាចបញ្ចេញសម្លេងបាន ប៉ុន្តែមានសមត្ថភាពអាចនាំស្រៈ ដែលខ្លួនអាស្រ័យនោះ ឲ្យលាន់ឮតាមពិតរបស់ខ្លួនផងដែរ ហើយធ្វើនូវសេចក្តីឲ្យច្បាស់លាស់ប្រាកដឡើងផង ; ឯស្រៈ ពិតមែនតែបញ្ចេញសម្លេងតាមទំនើងខ្លួនឯងបាន ប៉ុន្តែមិនអាចធ្វើសេចក្តីឲ្យច្បាស់លាស់ជាជាក់ ដោយខ្លួនឯងទាំងអស់បានទេ ដូចជាពាក្យថា “ទៅណា” បើសិនជាសរសេរសុទ្ធតែស្រៈថា “ៅ ា” ដូចនេះ ឬក៏សរសេរតែព្យញ្ជនៈ ដូចជា “ទ-ណ” ដូចនេះវិញ នឹងយកសេចក្តីជាជាក់ពុំ-បាន លុះតែដាក់ព្យញ្ជនៈចូលមកជាមួយផង នោះទើបប្រាកដ “ទៅណា” ឡើងបាន ; រួបរួមសេចក្តីដោយខ្លីថា ស្រៈសុំនឹងព្យញ្ជនៈនេះ លុះណាតែអាស្រ័យនូវគ្នានឹងគ្នា ទើបយកមកប្រើការកើត ខណៈណាមួយក៏មិនបានដែរ ។

## ឋានកើតនៃព្យញ្ជនៈ

ទីតាំងដែលកើតសម្លេងនៃអក្សរ ហៅថា "ឋាន" ។ តាមកន្លែងកើត គេចែកសម្លេងដូចតទៅនេះ៖

១- កណ្ឋជៈ (gutturales) កើតនៅក គឺ៖ កខគឃង, ឋាអ, (៧តួ)

២- តាលុជៈ (palatales) កើតនៅក្រអូមមាត់ គឺ៖ ចឆជឈញ យ (៦តួ)

៣- មុទ្ធជៈ (cérébrales ou linguales) កើតនៅ ក្បាល គឺ៖ ដឋឌឍណ រឡ (៧តួ);

៤- ទន្តជៈ (dentales) កើតនៅធ្មេញគឺ៖ តថទធន លស (៧តួ);

៤. ឱដ្ឋជ: (labiales) កើតនៅបបូរមាត់ គឺ: ប ផ ព ភ ម វ (៦តួ);

មានអក្សរខ្លះហៅថា នាសិកជ: និង អឌ្ឍស្រះ ។

– នាសិកជ: កើតដោយមានៈពាល់តាមហាន់មកហើយផង និងច្រមុះផង (Nasales) គឺ ង, ញ, ណ, ន, ម, (ដែលជាវគ្គន: គឺចុងបំផុតនៃវគ្គ) និងនិគ្គហិត (ំ) ដែលបញ្ចេញសម្លេងដូចខ្យល់ម ។

អឌ្ឍស្រះ: ( Semi voyelle) ប្រែថាស្រះពាក់កណ្ដាល (ព្យញ្ជនៈពាក់កណ្ដាល) បានដល់ យ និង វ ។

## មេរៀនទី២ៈ–វគ្គ និង អវគ្គ

ព្យញ្ជនៈទាំង៣៣តួ ចែកចេញជាពីរពួកគឺ "វគ្គ"

ង "អវគ្គ" ។ ពាក្យថា "វគ្គ" ប្រែសេចក្ដីថា "ព្យញ្ជនៈ

នពួក" ឬថា "ព្យញ្ជនៈប្រព្រឹត្តទៅតាមពួក "វគ្គទាំង

សមាន៥ ហើយនីមួយៗ មានអក្សរ ៥ តួ ៗ

វគ្គទាំងនោះគឺៈ

ក ខ គ ឃ ង ជួរនេះហៅថា កវគ្គ ឬ វគ្គទី១

ច ឆ ជ ឈ ញ " ចវគ្គ ឬ វគ្គទី២

ដ ឋ ឌ ឍ ណ " ដវគ្គ ឬ វគ្គទី៣

ត ថ ទ ធ ន " តវគ្គ ឬ វគ្គទី ៤

ប ផ ព ភ ម " បវគ្គ ឬ វគ្គទី៥

ព្យញ្ជនៈ៨តួទៀតគឺៈ យ រ ល វ ស ហ ឡ អ ហៅ

ថា "អវគ្គ" ប្រែថា "ព្យញ្ជនៈឥតពួក" ឬហៅថា "សេស-

គ្គ" ក៏បាន ដែលមានន័យថា "ព្យញ្ជនៈមានពួកដ៏សេស"

សល់ក្រៅពីពួក ៗ

# មេរៀនទី៣

## ឃោសៈនិងអឃោសៈ (Sonores & Sourdes)

តាមសម្លេង គេចែកព្យញ្ជនៈទាំងឡាយ ជាពីរពួកគឺ៖

១–ព្យញ្ជនៈ ដែលមានសម្លេងតឹកកង គឺសម្លេងធំ ឬ គ្រលរ ហៅថា "ឃោសៈ" (Sonores) ។

២–ព្យញ្ជនៈ ដែលមានសម្លេងមិនតឹកកង គឺសម្លេងតូចឬសម្លេងគ្រលួច ហៅថា "អឃោសៈ" (Sourdes) ។

ព្យញ្ជនៈ ទី១ និងទី២ ក្នុងវគ្គទាំង៥ និងព្យញ្ជនៈ៤តួ ខាងចុងក្នុងអវគ្គ ហៅថា អឃោសៈ, ព្យញ្ជនៈ ទី៣, ទី៤

៦៥ ក្នុងវគ្គទាំង ៥ ទាំងព្យញ្ជនៈ ៤ តួខាងដើមក្នុងសេសវគ្គ ហៅថា ឃោសៈ ។

| ក្នុងពួក | ពួកអឃោសៈ | ពួកឃោសៈ | |
|---|---|---|---|
| ក វគ្គ | ក ខ | គ ឃ ង | ៥ តួ |
| ច វគ្គ | ច ឆ | ជ ឈ ញ | " " |
| ដ វគ្គ | ដ ឋ | ឌ ឍ ណ | " " |
| ត វគ្គ | ត ថ | ទ ធ ន | " " |
| ប វគ្គ | ប ផ | ព ភ ម | " " |
| អ វគ្គ | ស ហ ឡ ំ | យ រ ល វ | ៨ " |

បូករួមៈ ១៤ តួ + ១៩ តួ = ៣៣ តួ

ចំណាំ—( Remarque ) ១ ការចែកព្យញ្ជនៈខ្មែរជាឃោសៈ និងអឃោសៈនេះ ខុសពីក្នុងគម្ពីរបាលី សំស្ក្រឹតខ្លះ ។ ក្នុងអវគ្គខាងបាលី សំស្ក្រឹត គេយកតែ " ស ,, ១តួ មកបញ្ចូលជាអឃោសៈ ហើយព្យញ្ជនៈ៧តួទៀតគឺ យ,រ,ល,វ,ហ,ឡ, ំ

នេះបញ្ចូលជាឃោសៈ ខុសគ្នាពីខាងខ្មែរយើង ដែលប

ព្យញ្ជនៈ៤តួខាងចុង សហឡអ បញ្ចូលជាអឃោ

ហើយ ព្យញ្ជនៈ៤តួខាងដើម យរលវ ជាឃោសៈ

៤- តាមសម្លេងគាត់តួ "ណ" គួរជាអឃោសៈ

ដោយហេតុថា "ណ" នៅខាងចុងវគ្គ គេគិត "ណ

ជាឃោសៈដូចព្យញ្ជនៈឯទាំងតួដែលនៅខាងចុងវគ្គ

## មេរៀនទី៤:-សិថិល-ធនិត (inaspirée et Aspirée

បណ្ដាព្យញ្ជនៈ ទាំងអស់ ព្យញ្ជនៈ គួខ្លះមានសម្លេ

មួយ, ខ្លះទៀតមានសម្លេងផ្សំ ( គួព្យញ្ជនៈដែល

សម្លេងតែមួយ ហៅថា សិថិល ប្រែថា "ធូរ" ប្រ

ជាព្យញ្ជនៈមានសម្លេងធូរខ្សោយ បានដល់ គួព្យញ្ជនៈទី១

ទី៣ក្នុងវគ្គទាំង៥គឺ៖ កគ, ចជ, ដឌ, តទ, បព,(១០

គូដែលមានសម្លេងផ្សំហៅថា „ ឃោស „ ប្រែថា „ តឹង „ ព្រោះជាព្យញ្ជនៈមានសម្លេងតឹងខ្លាំង បានដល់ព្យញ្ជនៈទី២ នឹងទី៤ ក្នុងវគ្គទាំង៥គឺៈ គឃ, ជឈ, ឌឍ, ទធ, ពភ, (១០តួ) ។

ព្យញ្ជនៈជាសិថិល ចែកចេញជាពីរពួកគឺៈ កចដតប ៥ តួនេះហៅថា សិថិលអឃោសៈ ជាពួកមួយ គជឌទព ៥ តួនេះហៅថា សិថិលឃោសៈ ជាពួក ១ ទៀត ។ ចំណែកខាងព្យញ្ជនៈជាធនិត ក៏ចែកចេញជាពីរពួកដែរ គឺៈ ខឆឋថផ ៥ តួនេះហៅថា ធនិតអឃោសៈ, ឃឈឍធភ ៥ តួនេះហៅថា ធនិតឃោសៈ ។

ព្យញ្ជនៈទាំង ២០ តួនេះ មានសម្លេងធូរតឹងជាន់គ្នា តាមលំដាប់ដូចនេះគឺៈ

ក) សិថិលអឃោសៈ មានសម្លេងធូរខ្សោយជាងព្យញ្ជនៈទាំងអស់ ;

ខ) ធនិតអឃោសៈ មានសម្លេងតឹងខ្លាំងជាង
សិថិលអឃោសៈ;

គ) សិថិលឃោសៈ មានសម្លេងលាន់ខ្លាំងជាង
ធនិតអឃោសៈ;

ឃ) ធនិតឃោសៈ មានសម្លេងលាន់ខ្លាំងជាង
សិថិលឃោសៈ;

បើនិយាយឲ្យស្រួលស្ដាប់ងាយចំណាំនោះគឺថា៖

ក) ព្យញ្ជនៈ ទី ១ ក្នុងវគ្គមានសម្លេងធូរជាងគេទាំង-
អស់;

ខ) ព្យញ្ជនៈទី២ " " " តឹងជាងព្យញ្ជនៈទី១;

គ) ព្យញ្ជនៈទី៣ " " " លាន់ខ្លាំងជាងព្យញ្ជនៈ
ទី២;

ឃ) ព្យញ្ជនៈទី៤ " " " តឹងខ្លាំងជាងព្យញ្ជនៈ
ទី៣ ។

តាមសម្លេងធ្ងន់ "ក" ធ្ងន់នឹង "ហ" បង្កើតបានជា

"ខ", ; "គ" ផ្សំនឹង "ហ" បានជា "ឃ" ដូចនេះ រហូតដល់ "ភ", គឺថា "សិថិលអឃោសៈ", ផ្សំនឹង "ហ", កើតបានជាធនិតអឃោសៈ; សិថិលឃោសៈផ្សំនឹង "ហ" កើតបានជាធនិតឃោសៈ ។

| សិថិល | សិថិល+ហ | សម្លេងផា | ធនិត |
|---|---|---|---|
| ក | ក + ហ | ក្ហ | ខ |
| គ | គ + ហ | គ្ហ | ឃ |
| ច | ច + ហ | ច្ហ | ឆ |
| ជ | ជ + ហ | ជ្ហ | ឈ |
| ដ | ដ + ហ | ដ្ហ | ឋ |
| ឌ | ឌ + ហ | ឌ្ហ | ឍ |
| ត | ត + ហ | ត្ហ | ថ |
| ទ | ទ + ហ | ទ្ហ | ធ |
| ប | ប + ហ | ប្ហ | ផ |
| ព | ព + ហ | ព្ហ | ភ |

ដូចនេះ អក្សរ «ត» ជាគូនឹងអក្សរ «ទ» ក៏ ជាគូនឹង ឃ...។ល។... ក្រៅពីអក្សរ ២០ តួនេះ ពុំមែនជាសិថិលឬជាធនិតទេ ពីព្រោះជាអក្សរមានសម្លេងដោយឡែក ឥតកំណត់គូនឹងតាមលំដាប់ជាគូឡើយ ។

## មេរៀនទី៥ : – និគ្គហិត

ព្យញ្ជនៈ « ំ » នេះហៅថា «និគ្គហិត» ប្រែថា «ព្យញ្ជនៈសង្កត់នៅអាស្រ័យនឹងស្រៈរស្សៈ» ។ ក្នុងភាសាបាលី និគ្គហិត សង្កត់លើស្រៈរស្សៈ ៣ តួគឺ អ ិ ុ ទៀតជា អំ អិំ អុំ ; ក្នុងភាសាសំស្រ្កឹត និគ្គហិត អាចសង្កត់លើស្រៈទីឃៈ បានខ្លះដូចស្រៈ អា ទៀតជា អាំ ។

និគ្គហិតនេះ បើពោលជា «អនុស្វារ» បញ្ចេ

សម្រេចដូចមានអក្សរ «ង» ប្រកបខាងចុង បើពោលជា "មការន្ត" បញ្ចេញសម្រេចដូចមានអក្សរ "ង" ប្រកបខាងចុង ៗ ឧទាហរណ៍ យំ តំ អគ្គិំ វធុំ

តាម "អនុនាសិកន្ត" គឺជា៖ យ័ង, ត័ង, អគ្គិង, វធុង

តាម "មការន្ត" គឺជា៖ យ័ម, ត័ម, អគ្គិម, វធុម

បំណាំ- ១) ក្នុងភាសាខ្មែរ គ្មាននិគ្គហិតប្រើតែឯងទេ ខ្មែរយកនិគ្គហិតបាលី និងសំស្ក្រឹតស្ថិតលើស្រៈមកប្រើជាស្រៈនិស្ស័យ ស្រៈទាំងនោះគឺ៖

អុំ ុំ ; អំ, ំ ; អំ ំ ; អាំ ាំ;

២) មានពាក្យខ្មែរខ្លះ ដែលក្លាយមកពីពាក្យ បាលី ឬ សំស្ក្រឹត ឬ ពាក្យខ្មែរសុទ្ធខ្លះដែលត្រូវប្រកបទីង «ង» ឬ ទីង

“ម„ នោះ អាចយក និគ្គហិត មកប្រើវិញក៏ត្រូវដែរ ដូចពាក្យ៖ លោកសង្ឃ ឬ លោកសំឃ, សម្រាប់ ឬ សំរាប់, តម្រួត ឬ តំរួត, សម្ដែង ឬ សំដែង ។

ពាក្យទាំងនេះច្រើនតែពាក្យពីរព្យាង្គ ។



## មេរៀនទី៦ :- គរុ និង លហុ

អក្សរគរុនោះ គឺស្រៈណាជាទីឃអក្សរដូច៖ ា ី ឺ
ូ ួ ើ ឿ ៀ ែ ៃ ោ ៅ អស់នេះហៅថា ទីឃគរុ ។

ក្នុងវិធីបំបែកអក្សរ ក កា ដូចនេះ៖ កា កិ កី កុ កូ កើ កឿ កៀ កេ កែ កៃ កោ កៅ ...ឬ... ឡា ឡិ ឡី ឡុ ឡូ ឡើ ឡឿ ឡៀ ឡេ ឡែ ឡៃ ឡោ ឡៅ ... ហៅថា ទីឃគរុ ។

គួ និគ្គហិតគឺ កុំ កំ កាំ .. ឬ ឡុំ ឡំ ឡាំ ហៅថា និគ្គហិតគរុ ។

មួយវិញទៀតតួណាជារស្សៈអក្សរ ដែលនៅខាងដើមតួសំយោគ ដូចជា៖ អត្ត, យក្ខ, មគ្គ, វគ្គ ជាដើម យ៉ាងនេះហៅថា សំយោគគរុ ។

មួយចំណែកទៀត ពាក្យណាជាពាក្យត្រូវសង្កត់ខ្យល់ទៀតដូចក្នុងមេ កក, កង, កប, កញ, កត, កន, កប, កល, កស, កយ, ក៏ហៅថា គរុ ដូចគ្នា ។

តស្រៈសំស្ក្រឹត គឺ អា ឦ ឱ ឫ ឮ ឯ ឰ ឱ ឳ ក៏ហៅថា ទីឃគរុ ដែរ ។

ឯអក្សរ លហុ នោះគឺ តួស្រៈស្រៈដូចជា ា ិ ី ុ ះ ។ ក្នុងវិធីបំបែក អក្សរ គា គា ដូចនេះគឺ៖ ក កិ កី កុ កះ .. ឬ ឫ ឬ ឭ ឮ ឭះ ។

តួព្យញ្ជនៈតាំង៣៣តួមាន ក ជាដើម ហៅថា លហុ តាំងអស់ ។

មួយវិញទៀត ស្រៈណាជាទីឃៈ តែត្រូវជាពាក្យប្រើវិសជ្ជនីយវិញ ដូចជា៖ នេះ, នោះ, បេះ, បោះ, ព្រោះ, សង្គ្រោះ... ជាដើម យ៉ាងនេះក៏ហៅថា លហុ ដែរ ។

ស្រៈក្នុងភាសាសំស្ក្រឹត គឺ អ ឥ ឧ ឫ ឭ ហៅថា លហុ ដូចគ្នា ។

## មេរៀនទី៧ ព្យញ្ជនៈបន្ថែម

ដើម្បីនឹងប្រើការឲ្យបានគ្រប់គ្រាន់ក្នុងភាសាខ្មែរ បុរាណាចារ្យលោកបន្ថែមព្យញ្ជនៈ ដោយថែមវណ្ណយុត្ត មូសិកទន្ត និងត្រីសព្ទ លើព្យញ្ជនៈខ្លះ ឬដោយយកជើងព្យញ្ជនៈខ្លះ ទៅធ្វើនឹងព្យញ្ជនៈដទៃទៀត ។

ព្យញ្ជនៈបន្ថែមពួកទី ១ ហៅថា អក្សរសម្លាប់ និង ព្យញ្ជនៈបន្ថែមពួកទី ២ ហៅថា អក្សរជើង ។–

### ១–អក្សរសម្លាប់

អក្សរសម្លាប់គឺជាព្យញ្ជនៈ ដែលបណ្ឌិតវេយ្យាករណ៍បុរាណ លោកយកមូសិកទន្ត ឬត្រីសព្ទមកថែមពីលើដើម្បីបំប្លែងសព្ទឲ្យប្លែកពីសព្ទដើម ។

មូសិកទន្តបំប្លែងសព្ទព្យញ្ជនៈឃោសៈ ៦ អង្គ ឲ្យទៅជាអឃោសៈវិញ៖ ង, ញ, ម, យ, រ, វ, ទៅជា ង៉, ញ៉, ម៉, យ៉, រ៉, វ៉, ។ល។

មូសិកទន្តអាចបំបែរសព្ទព្យញ្ជនអឃោសៈ ១ អក្ខរ "ប" ឲ្យទៅជាមានសព្ទអឃោសៈ ១ យ៉ាងទៀត បាន គឺ "ប៉" ។

ត្រីសព្ទបំបែរសព្ទព្យញ្ជន អឃោសៈ ៤ អក្ខរឲ្យទៅជាឃោសៈវិញ៖ ប, ស, ហ, អ ទៅជា ប៊, ស៊, ហ៊, អ៊ ។

ដូចនេះអក្សរសម្រាប់ទាំងអស់មាន ១១ តួគឺ៖ ង៉, ញ៉, ប៉, ម៉, យ៉, រ៉, វ៉, ប៊, ស៊, ហ៊, អ៊ ។

ចំណាំ ឬ ក្បួន.—

ក) អក្សរសម្រាប់ទាំងឡាយ កាលបើមានស្រៈនិស្ស័យ ិ ី ឹ ឺ ើ ាំ ស្ថិតនៅលើព្យញ្ជនៈ ទាំងនោះផ្លាស់រូបមូសិកទន្តឬត្រីសព្ទឲ្យមកនៅខាងក្រោមវិញ ក្លាយទៅ (ុ) ដូចពាក្យថា៖ គាមុឺន, បុិន, សុី, អុឹម, សុើបការ, ញុាំញុើ

ខ) កាលណាមានសព្ទព្យាង្គដើមឬសព្ទតួអក្សរដើមបន្ថែមមក អក្សរសម្រាប់នៃព្យាង្គទី ២ ឬអក្សរសម្រាប់តួទី ២ មិនចាំបាច់ដាក់មូសិកទន្តឬត្រីសព្ទឡើយ ដូចពាក្យថា៖ វិហារ

សាលា, ទាហាន, ប្រមោយ, ស្រវឹង, ត្រហើន, ងឺរ ។ល។

## ២–អក្សរផ្ញើជើង

ព្យញ្ជនៈទាំងអស់ សុទ្ធតែមានជើងសម្រាប់ផ្ញើពីក្រោមព្យញ្ជនៈឯទៀត បញ្ចូលសំដីគ្នា ហាក់ដូចមានព្យញ្ជនៈតែមួយគត់ ។ ដូចនេះ ពួកផ្ញើជើងទាំងប៉ុន្មាន ក៏ត្រូវឲ្យទទួលស្រៈដូចព្យញ្ជនៈនានាដែរ ប៉ុន្តែត្រូវចាំថាមានព្យញ្ជនៈមួយពួក សំដីលំនុនបានទៅជាពីរយ៉ាង គឺពួក ង, ញ, ន, ម, យ, រ, ល, វ, បើយកទៅផ្ញើទីងព្យញ្ជនៈណាមួយ សំដីក៏ដូលទៅតាមព្យញ្ជនៈនោះ ដូចជា ន ផ្ញើក្រោម ខ បានទៅជា ខ្ន ដូច ខ្នរ, ខ្នយ, ខ្នងខ្នប ។ល។; ន ផ្ញើក្រោម គ បានទៅជា គ្ន ដូច គ្នានគ្នេរ, គ្នគ្នា, ... ជាដើម ...; ក្រៅពីពួក៨តួនេះ ជាព្យញ្ជនៈសុជាតិ នោះយកទៅផ្ញើទីងព្យញ្ជនៈណាៗក៏ដោយ តែងទាញសម្លេងគេឲ្យ

ប្រព្រឹត្តតាមអំណាចរបស់ខ្លួនជាដរាប ដូចជា ប ផ្ញើជើង ម ទៅតែសម្រួល ប ដដែល គឺ ម្ប, គ ផ្ញើជើង ឃ ទៅតែសម្រួលឃោសៈ គ ដដែល គឺ ឃ្គ ម្ត ដូច ស្គ ... ជាដើម ។

ព្យញ្ជនៈខាងក្រោមនេះ ច្រើនតែយកជើងទៅផ្ញើនឹងព្យញ្ជនៈឯទៀត

ក ) ព្យញ្ជនៈសំដីដួលទៅតាមព្យញ្ជនៈដែលយកទៅផ្ញើ គឺ៖ ង្ង ញ្ញ ន្ន ម្ម យ្យ រ្រ ល្ល វ្វ ។

ខ) ព្យញ្ជនៈសំងើងខាញ់បំឡេងគេឲ្យប្រព្រឹត្តតាមសភាពរបស់ខ្លួនគឺ ៖ ណ្ណ, ក្ក, ច្ច, ជ្ជ, ដ្ដ, ន្ន ប្ប, ត្ត, ស្ស, ហ្ហ, អ, ។

អក្សរផ្ញើជើងទាំងឡាយគឺ ៖

ក្ង ក្ច ក្ញ ក្ន ក្ប ក្ម ក្រ ក្ល ក្វ ក្យ ក្អ; ខ្ង ខ្ជ ខ្ញ ខ្ដ ខ្ញ ខ្ន ខ្ទ ខ្ម ខ្យ ខ្ល ខ្វ ខ្ស; គ្ន គ្ម គ្រ គ្វ; ឃ្ញ ឃ្ន ឃ្ម ឃ្ល ឃ្វ; ប្ន ប្ប ប្យ ប្រ; ឆ្ក ឆ្គ ឆ្ង ឆ្ដ ឆ្ន ឆ្ទ ឆ្ម ឆ្ល ឆ្វ

ឆ្អ; ជ្រ ជ្វ; ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ; ញ្ហ; ត្ង ត្ន ត្យ

ត្ម ត្រ ត្វ ត្ល ត្អ; ថ្ក ថ្គ ថ្ង ថ្ន ថ្ត ថ្ម ថ្ល ថ្វ; ទ្រ ទ្វ;

ធ្ង ធ្ន ធ្ម ធ្យ ធ្ល ធ្វ; ន្រ; ប្ដ ប្រ ប្ល ប្អ; ផ្ក ផ្គ ផ្ង ផ្ស ផ្ញ

ផ្ត(ជើងដ) ផ្ដ(ជើងត) ផ្ច ផ្ន ផ្ល ផ្ប ផ្អ; ព្ក ព្ន ព្យ ព្រ ព្វ ព្អ; ភ្ង ភ្ព

ភ្ញ ភ្ន ភ្រ ភ្ល; ម្ក ម្ខ ម៉្ង ម្ស ម្ព ម៊្ញ ម្ដ ម្ច ម្ន ម្ភ ម៉្យ ម្រ ម្ល

ម៉្ល ម្ប ម្ហ ម្អ; ល្ក ល្ខ ល្គ ល្ង ល្យ ល្ត ល្ម ល្វ ល្ហ ល្អ

ស្ក ស្គ ស្ង ស្ញ ស្ដ ស្ត្រ ស្ត ស្ដ(ជើងត) ស្ច ស្ន ស្ប ស៉្ប

ស្ត ស្ម ស្ប ស្រ ស្រិ ស្ល ស្វ ស្អ; ហ្ន ហ្ម ហ្រ ហ្ល ហ្វ។

## មុខងារនៃអក្សរ

ភាសាខ្មែរជាទីប្រជុំនៃភាសា ៣ គឺ ភាសាអ្នកស្រុក (ខ្មែរសុទ្ធ) ភាសាបាលី និងភាសាសំស្ក្រឹត ។

វេយ្យាករណ៍ខ្មែរ ចែកមុខងារព្យញ្ជនៈជាប់ស្រឡះ; អក្សរជាគ្រឿងប្រកបនូវពាក្យខ្មែរ សឹងជាអក្សរនៅដើម

វគ្គ លើកលែងតែអក្សរ ង គឺ ក ច ត ប ; អក្សរជា តួប្រកប ពាក្យបាលីដែលប្រើក្នុងភាសាខ្មែរ ឬពាក្យសំស្ក្រឹតក្ដី សឹងជាតួព្យញ្ជនៈ ទី២ ទី៣ ទី៤ ក្នុងវគ្គ និងព្យញ្ជនៈ ខាងដើមនៃ ៥ វគ្គ គឺ ខ គ ឃ ឆ ជ ឈ ឋ ឌ ឍ ថ ទ ធ ផ ព ភ ឯព្យញ្ជនៈនៅចុងវគ្គ និងពួកសេសវគ្គ គឺ ង ញ ណ ន ម យ រ ល វ ស ហ ឡ ប្រើបានជាតួប្រកបនូវពាក្យខ្មែរ ពាក្យបាលីនិងពាក្យសំស្ក្រឹតជាមួយគ្នា ៗ ន័យមួយវិញទៀត ព្យញ្ជនៈទាំងឡាយដែលចាត់ជាតួប្រកបនូវពាក្យមកពីបាលីឬសំស្ក្រឹត ព្យញ្ជនៈទាំងនោះមិនត្រូវមានសញ្ញាបន្តក់ថែមលើឡើយ ទោះពាក្យនោះមានខ្យល់ជាស្យេ-សញ្ញាក៏ដោយដូចពាក្យថា ៖ កុសល, ផល, ប្រាកដ, ពល, ជន, ធនធាន, សត្វ, ផល, សន្តត, លាមក, នរក, តារក... ជាដើម ។

## មេរៀនទី៨: អក្សរសព្ទឃោសៈនិងអឃោសៈ

ពាក្យមានព្យាង្គពីរ ដូចជា៖ ពាហាន, សាណា, កុមារ, ប្រមាថ, សន្យា, ព្រហើន.. ជាដើម ព្យាង្គខាងដើមមានសម្លេងជាឃោសៈឬអឃោសៈ ព្យាង្គខាងចុងក៏ត្រូវនសម្លេងទៅតាមព្យាង្គខាងដើមជាដរាប កាលណាសរសេរមិនត្រូវប្រើត្រីសព្ទ(˝)ឬមូសិកទន្ត(") ឡើយ ដូចពាក្យជា៖ ព្រហើន, ព្រហាម, គ្រហឹម, សញ្ញា, សីមា, ប្រយ័ត្ន ។ល។ ... ។ សូម្បីតែអក្សរផ្ញើដើងខ្លះ ក៏ត្រូវមានសូរសព្ទជាឬតូច, ធ្វូរឬតឹង តាមអក្សរខាងដើមដែរ គឺថាបើតួអក្សរខាងលើជាព្យញ្ជនៈឃោសៈ ជើងអក្សរដែលយកមកផ្ញើនោះក៏មានសម្លេងតឹកកងតាមផងដែរ, បើតួអក្សរលើជាព្យញ្ជនៈអឃោសៈ ជើងអក្សរដែលយកមកផ្ញើនោះក៏មានសម្លេងតូចគ្រលួចផងដែរ ដូច៖

ក្វ ខ្វ ថ្វ ផ្វ ស្វ; ខ្ញ ផ្ញ ស្ញ; ក្ម ខ្ម ឆ្ម ត្ម ថ្ម ផ្ម ស្ម, ក្ន ខ្ន ឆ្ន ត្ន ថ្ន ស្ន, ខ្យ ស្យ, ក្រ ប្រ ត្រ ប្រ ស្រ, ក្វ ខ្វ ឆ្វ ត្វ ថ្វ ប្វ ផ្វ ស្វ, ក្វ ខ្វ ឆ្វ ត្វ ថ្វ ស្វ ... ។ល។ សូមមើលក្នុងមេរៀន "អក្សរផ្ញើជើង"។

## មេរៀនទី៩:- ព្យញ្ជនៈ ផ្លាស់ប្តូររូប

ក្នុងពាក្យខ្មែរយើង មានប្រើពាក្យបាលី និង សំស្ក្រឹត ឆ្លាយឡំផង ៗ ពាក្យទាំងនោះ ជួនកាលជាពាក្យបាលីចំៗតែម្តង ដូចជាពាក្យ ព្រះទត្ត, ទណ្ឌ, សរ, ឥទ្ធា ឧបជ្ឈាយ៍, ភិក្ខុ, សាមណេរ, សមណៈ ... ជាដើម ។ ជួនកាលជាពាក្យបាលីក្លាយជាសំស្ក្រឹត ដូចពាក្យថា៖ ខ្ទួន ប្រាណ, អក្សរ, អស្ចារ្យ, បុស្បា, ក្សេត្រ, ក្សេម, បស្ចឹម, អាទិត្យ ... ជាដើម ព្រោះហេតុនោះទើបឃើញប្រាកដថា មានប្រើពាក្យ បាលី និង សំស្ក្រឹតឆ្លាយឡំដោយព្រេនណាស់ ដូចក្នុងប្រយោគនេះ „អនាគតរបស់ប្រទេសកម្ពុជា សង្ឃឹម

លើពលរដ្ឋខ្មែរស្នេហាជាតិ „ ។ ពាក្យថា " អនាគត, កម្ពុជា, ពលរដ្ឋ, ជាតិ, ជាពាក្យបាលីសុទ្ធ, ពាក្យថា ប្រទេស, ស្នេហា ជាពាក្យសំស្ក្រឹតក្លាយ ; ចំណែកពាក្យ របស់, សង្ឃឹម, លើ ជាពាក្យខ្មែរសុទ្ធ ។ ពាក្យថាខ្មែរនេះ ជាពាក្យក្លាយមកពីពាក្យបាលីថា "ខេមរៈ„ ដែលប្រែថា "អ្នកមានសេចក្ដីក្សេម„ ។

ការផ្លាស់ប្ដូរអក្សរក្នុងពាក្យបាលី ឲ្យទៅជាពាក្យសំស្ក្រឹត ឬសំស្ក្រឹតក្លាយដូចជាផ្លាស់អក្សរក្នុងពាក្យថា "ខេម„ ឲ្យទៅជា "ក្សេម„ យ៉ាងនេះជាដើម ហៅថា "អក្សរផ្លាស់ប្ដូររូប„

ពួកអក្សរផ្លាស់ប្ដូររូប កើតឡើងពីពាក្យបាលី ដែលក្លាយជាសំស្ក្រឹត ។ ពាក្យទាំងនោះ ខ្មែរយើងប្រើទាំងបាលី ទាំងសំស្ក្រឹត ។ ន័យរបស់ពាក្យដូចគ្នា តែសូរសព្ទនិងរូបអក្សរខុសគ្នា ។ អក្សរផ្លាស់ប្ដូររូបទាំងឡាយនឹង

សម្រេចជាក្បួនឲ្យដាច់ស្រេចថាត្រូវផ្លាស់ជាយ៉ាងនេះ ឬ យ៉ាង
នោះមួងពុំបានឡើយ ព្រោះថាមានអក្សរខ្លះ ផ្លាស់ខុស
របៀប ដែលត្រូវផ្លាស់ក៏មាន ដូចជាពាក្យថា៖ សត្ត
ផ្លាស់ជាសត្វ, សតវស្ស ផ្លាស់ជា សតវត្ស, ហត្ថ ផ្លាស
ជា ហស្ត ... ជាដើម ៗ ប៉ុន្តែដែលឃើញអក្សរផ្លាស់ប្ដូរជ
ញឹកញាប់នោះ ដូចមានតទៅនេះ៖

| ពាក្យបាលី | | ពាក្យសំស្ក្រឹត |
|---|---|---|
| អក្ខរ | ផ្លាស់ជា | អក្សរ |
| យក្ខ | " | យក្ស |
| រុក្ខ | " | ព្រឹក្ស |
| ខេម | " | ក្សេម |
| សិក្ខា | " | សិក្សា |
| កិច្ច | " | ក្រិត្យ |
| សត្ថ | " | សស្ត្រ |

| ពាក្យបាលី | | ពាក្យសំស្ក្រឹត |
|---|---|---|
| ខត្ត | ផ្លាស់ជា | ក្សត្រ |
| ខេត្ត | " | ក្សេត្រ |
| វេជ្ជ | " | វេទ្យ |
| សមោជ្ជ | " | សម្មោទ្យ |
| ឈាន | " | ធ្យាន |
| អច្ឆរិយ | " | អស្ចារ្យ |
| និច្ច | " | និត្យ |
| វត្ថ | " | វស្ត្រ |
| អាទិច្ច | " | អាទិត្យ |
| ខីរ | " | ក្សីរ |
| សមុទ្ទ | " | សមុទ្រ |
| ជេដ្ឋ | " | ជេស្ឋ |
| ខណៈ | " | ក្សណៈ |

| ពាក្យបាលី | | ពាក្យសំស្ក្រឹត |
|---|---|---|
| សមគ្គ | ផ្លាស់ជា | សមគ្រឬស័ម្គ្រ |
| បព្វត | " | បព៌ត |
| កទ្ទូបទ | " | កទ្រូបទ |
| វិនិច្ឆយ | " | ពិនិស្ច័យ |
| បច្ឆិម | " | បស្ចិម |
| វេជ្ជ | " | ពេទ្យ |
| សច្ច | " | សត្យ |
| មជ្ឈិម | " | មធ្យម |
| វិជ្ជា | " | វិទ្យា |
| អធិដ្ឋាន | " | អធិស្ឋាន |
| អច្ឆរ | " | អប្សរ |
| ឥស្សា | " | ឥស្យា |
| ទុក្ខ | " | ទុះខ |

| ពាក្យបាលី | | ពាក្យសំស្ក្រឹត |
|---|---|---|
| រដ្ឋ | ផ្លាស់ជា | រាស្ដ្រ |
| រត្តិ | " | រាត្រី |
| បុត្ត | " | បុត្រ |
| ធម្ម | " | ធម៌ |
| បក្ខ | " | បក្ស |
| បច្ចក្ខ | " | ប្រត្យក្ស |
| បរិបុណ្ណ | " | បរិបូណ៌ |
| គព្ភ | " | គភ៌ |

## វិធីសង្កេតអក្សរផ្លាស់ប្ដូររូប

| បាលី | | សំស្ក្រឹត | បាលី | | សំស្ក្រឹត |
|---|---|---|---|---|---|
| ក្ខ, ខ | ផ្លាស់ជា | ក្ស | ដ្ឋ | ផ្លាស់ជា | ស្ដ |
| ក្ក | " | ក្រ | ឋ | " | ឋ, ស្ដ, ស្ឋ |
| គ្គ | " | គ្រ, គ៌ | ណ្ណ | " | ណ៌ |

| បាលី | | សំស្ក្រឹត | បាលី | | សំស្ក្រឹត |
|---|---|---|---|---|---|
| ច្ឆ | ផ្លាស់ជា | ស្ឆ, ច្យ | ត្ត | ផ្លាស់ជា | ត្រ |
| ជ្ឈ | " | ធ្យ, ជិ | ទ្ទ | " | ទ្រ, ទិ |
| ជ្យ, ឈ | " | ធ្យ | ព្ព | " | ពិ |
| | | | ម្ម | " | មិ |

អក្សរផ្លាស់ប្ដូររូបទាំងឡាយ ច្រើនស្ទើរតែគណនារាប់ពុំបាន ។

ក្យ = ប្រើតែនៅពាក្យចេញពីសំស្ក្រឹត

ក្យ = គ្មានប្រើនៅពាក្យខ្មែរសុទ្ធទេ

ខ្យ = មានប្រើនៅពាក្យបាលី ដូចជា «សំខ្យាសព្ទ»

មានពាក្យខ្លះកើតពីអក្សរ «វ» និង «ព» ផ្លាស់ប្ដូរគ្នា ដូចជាពាក្យថា៖ វាក្យ = ពាក្យ ; វេលា = ពេលា ; វិសាខ = ពិសាខ ; វន = ពន (ឈើព្រៃ); វរៈ = ព្រះ ; វិបាក = ពិបាក ,... ។

ម្យ៉ាងទៀតអក្សរដែលផ្លាស់ប្តូររូប ទៅជាពាក្យខ្មែរច្រើន
…តផ្លាស់ប្តូរច្រើនលើកច្រើនសា ដូចជា ៖ ព្រឹក្ស < វ្ឫក្ស
(ក្នុងពាក្យសំស្ក្រឹត), < រុក្ខ (ក្នុងពាក្យបាលី ; ប្រព្រឹត្ត
< បវ្ឫត្ត (ក្នុងពាក្យសំស្ក្រឹត), < បវត្ត (ក្នុងពាក្យបាលី) ។

ស្រៈ "អ ឥ ឧ" ក្នុងភាសាបាលី ឃើញច្រើនតែ
…ាស់ទៅជា "ឫ" ក្នុងភាសាសំស្ក្រឹត ហើយផ្លាស់ជា "រ"
…ក្នុងភាសាខ្មែរ ដូចជាពាក្យថា៖

ម្រឹគ < ម្ឫគ ក្នុងពាក្យសំស្ក្រឹត. < មិគ ក្នុងភាសាបាលី,

ព្រឹក្ស < វ្ឫក្ស " , < រុក្ខ " ;

ប្រព្រឹត្ត < បវ្ឫត្ត " , < បវិត្ត " :

ដូច្នេះការពិនិត្យរកឫសគល់នៃពាក្យមួយម៉ាត់ៗ នាំឲ្យ
…យើងបេះពាក្យនោះថាជាបាលី, សំស្ក្រឹតឬខ្មែរ [?]
…បាកដទៀងទៀត ។

ពាក្យជាច្រើនដែលកើតចេញពីអក្សរ "ឋ ដ្ឋ ស្ឋ ស្ថ" ។ អក្សរ "ឍ ឌ្ឍ" សំរាប់តែពាក្យបាលីដែលប្រើជាភាសាខ្មែរ ។ អក្សរ "ស្ធ ស្ដ ស្ថ" សំរាប់តែពាក្យជាសំស្រ្កឹត ។ អក្សរ "ឋ" ប្រើជាពាក្យក្លាយពីបាលី ឬ សំស្រ្កឹត ឬ ជាភាសាខ្មែរសុទ្ធ ។

ដូចជាពាក្យថា ៖ – បឋម, ឋាន (ជាភាសាបាលី) ។

– ប្រឋម·ស្ថាន (ជាភាសាសំស្រ្កឹត) ។

– បឋម, ឋាន (... ក្លាយ) ។

## មេរៀនទី ១០ ៖ – គូនៃអក្សរ

យើងបានរៀនពីសិថិលនិងធនិតរួចមកហើយ តែក្នុងវគ្គនីមួយ ៗ សឹងមានអក្សរជាគូគ្នា ដូចនេះ ៖

# សម្ពន្ធ-អក្ខរាវិរុទ្ធ

វគ្គទី ១.– អក្សរ ក ជាគូនឹង ខ; គ ជាគូនឹង ឃ ។

វគ្គទី ២.– " ច " ឆ; ជ " ឈ ។

វគ្គទី ៣.– " ដ " ឋ; ឌ " ឍ ។

វគ្គទី ៤.– " ត " ថ; ទ " ធ ។

វគ្គទី ៥.– " ប " ផ; ព " ភ ។

ឯគូរបស់ពាក្យ គឺពាក្យមានសំឡេងជិតគេ កើតឡើងពីពាក្យមួយទៀតសម្ងួនសិថិល ដូចមានឧទាហរណ៍ក្នុងវគ្គនីមួយៗ ខាងក្រោមនេះ៖

## ពាក្យក្នុងវគ្គ

| ក គូនឹង ខ | គ គូនឹង ឃ |
|---|---|
| កើយ (កិ)- ខ្នើយ (ន) | គាប (កិ)- ឃ្នាប (ន) |
| កោស (កិ)- ខ្នោស (ន) | គង (កិ)- ឃ្នង (ន) |
| កោះ (កិ)- ខ្នោះ (ន) | គួស (កិ)- ឃ្នួស (ន) |
| កំហាក (ន)- ខាក (កិ) | គោះ (កិ)- ឃ្នោះ (ន) |
| កង្ការ (ន)- ខ្ការ (កិ) | គង្វាល (ន)- ឃ្វាល (កិ) |
| កញ្ចប់ (ន)- ខ្ចប់ (កិ) | |

## ពាក្យក្នុងបវគ្គ

| ប គូនឹង ផ | ជ គូនឹង ឈ |
|---|---|
| បុក (កិ) – ផ្តុក (ន) | ជួល (កិ) · ឈ្នួល (ន) |
| បាំ (កិ) – ផ្ទាំ (ន) | ជូត (កិ) – ឈ្នូត (ន) |
| បម្លាក់ (ន) – ផ្លាក់ (កិ) | ជម្លោះ (ន) – ឈ្លោះ (កិ) |
| បម្លូន (កិ) – ផ្លូន (កិ) | ជួញ (កិ) – ឈ្នួញ (ន) |

## ពាក្យក្នុងដវគ្គ និង តវគ្គ

| ដ គូនឹង ថ | ទ គូនឹង ធ |
|---|---|
| ដក់ (កិ) – ថ្នក់ (ន) | ទាក់ (កិ) – ធ្នាក់ (ន) |
| ដន (កិ) – ថ្នន (ន) | ទំលាយ (កិ) – ធ្លាយ (គុ) |
| ដោល (កិ) – ថ្នោល (ន) | ទម្លាក់ (កិ) – ធ្លាក់ (គុ) |
| ដង្ករ (ន) – ថ្ករ (កិ) | ទម្លុះ (កិ) – ធ្លុះ (គុ) |
| ដង្កៀប (ន) – ថ្កៀប (កិ) | |
| ដង្វាយ (ន) – ថ្វាយ (កិ) | |

## ពាក្យក្លាយបវគ្គ

| | |
|---|---|
| ប ប្ដូរនឹង ផ | ព ប្ដូរនឹង ភ |
| បួស (កិ) – ផ្នួស (ន) | ពែន (កិ) – ភ្នែន (ន) |
| បួង (កិ) – ផ្នួង (ន) | ពេន (កិ) – ភ្នេន (ន) |
| បណ្ដាំ (ន) – ផ្ដាំ (កិ) | ពន្លឺ (ន) – ភ្លឺ (គុ) |
| បន្លាស់ (ន) – ផ្លាស់ (កិ) | |
| បណ្ដាច់ (ន) – ផ្ដាច់ (កិ) | |
| បន្ទុះ (ន) – ផ្ទុះ (កិ) | |

បំណាំ ពាក្យគូដែលបានឃើញហើយនេះ មិនសុទ្ធតែកើតជាកិរិយាសព្ទមុន ទើបកើតជានាមសព្ទក្រោយនោះក៏ទេដែរ៖

ក= ១– មានកាលកើតកិរិយាសព្ទមុន ទើបកើតនាមសព្ទជាក្រោយ ដូចពាក្យ៖ កើយ(កិ)ទៅជាខ្នើយ (ន) ។

២– មានកាលកើតកិរិយាសព្ទមុន ទើបកើតមាន

កិរិយាសព្ទមួយទៀត ដូចពាក្យ៖

– បណ្ដាច់ (កិ) ទៅជា ផ្ដាច់ (កិ) ។

៣ – មានកាលកើតកិរិយាសព្ទមុន ទើបកើតគុណនាមក្រោយ ដូចពាក្យ៖-ទំលាយ (កិ) ទៅជា ធ្លាយ (គុ) ។

៤ – មានកាលកើតនាមសព្ទមុន ទើបកើតកិរិយាសព្ទក្រោយ ដូចពាក្យ៖ – បន្ទាស់(ន)ទៅជា ផ្ទាស់ (កិ) ។

៥ - មានកាលកើតនាមសព្ទមួយហើយ ទើបកើតនាមសព្ទមួយទៀត ដូចពាក្យថា៖

– ជំនួញ(ន)ទៅជា ឈ្នួញ (ន) ។

៦ – មានកាលកើតនាមសព្ទមុន ទើបកើតគុណនាមក្រោយ ដូចពាក្យ៖ - ពន្ធី (ន) ទៅជាក្ធី (គុ) ។

១ - ពាក្យតាំងឡាយដែលកើតពីឬសជ: មានខ្លះគាបប្រើ

បានជាទន្តជៈក៏បាន ( សូមមើលខាងដើម ត្រង់ទំព័រដាក់ចំណងជើងថា ឋានកើតនៃព្យញ្ជនៈ ) ដូចពាក្យៈ

ជង្ករ ឬ គង្ករ ; ជង្កៀប ឬ គង្កៀប ... ។ល។

យ៉ាងនេះ ធ្វើឲ្យឃើញថាក្នុងវគ្គ ‘‘ឋ តួទី ២’’ ‘‘ឍ តួទី ៤’’ ទាំងពីរតួនេះឥតមានកំណើតកើតបានជាពាក្យ ១ ម៉ាត់សោះឡើយក្នុងភាសាខ្មែរ តែក្នុងភាសាបាលីវិញ គេមានយកមកផ្សំប្រកបនឹងព្យញ្ជនៈឯទៀត ដូចពាក្យៈ

អដ្ឋ (ប្រាំបី); វឌ្ឍ (ដែន); អឌ្ឍ (កន្លះ ឬ ពាក់កណ្ដាល) អឌ្ឍរាត្រី (ពាក់កណ្ដាលយប់) . . . ។

ឯអក្សរខាងសេសវគ្គជាតួសិថិលទាំងអស់ ឥតមានគូឡើយ អក្ខរៈជាវគ្គន្តៈ (ទីបំផុតវគ្គ) ទាំង៥តួក៏ជាសិថិល មិនមានគូដូចគ្នាដែរ ។ អក្សរកំព្រា ឬ ឥតគូ ឬ ពោលទាំងនោះ គឺៈ

ង, ញ, ណ, ន, ម, យ, រ, ល, វ, ស, ហ, ឡ, អ ។

## មេរៀនទី ១១ :- វណ្ណយុត្តិ

(Les signes acritiques)

សញ្ញាតាំងឡាយដែលគេបន្ថែមលើតួអក្សរ ដើម្បីលំអៀងសូរសព្ទពីលំនាំដើម ឬ ធ្វើលក្ខណៈសេចក្ដីឲ្យមានសង្កាត់ច្បាស់លាស់ ហៅថា "វណ្ណយុត្តិ" ។

វណ្ណយុត្តិចែកចេញជាពីរពួក ៖

១- ពួកវណ្ណយុត្តិដែលប្រើលើតួអក្សរ ដើម្បីលំអៀងសព្ទ ហៅថា "វណ្ណយុត្តិធម្មតា" (Les accents) ។

២- ពួកវណ្ណយុត្តិដែលប្រើខណ្ឌសេចក្ដីជាសង្កាត់ ហៅថា "ខណ្ឌសញ្ញា" (Les ponctuations) ។

ក- វណ្ណយុត្តិសម្រាប់ប្រើក្នុងភាសាខ្មែរមាន ១១ យ៉ាង គឺ ៖

១- សៀសញ្ញា ឬ បន្តក់ ( ់)

២-មូសិកទន្ត ឬធ្មេញកណ្ដុរ ( ៉ )

៣-ត្រីសព្ទ ( ៊ )

៤-សំយោគសញ្ញា ( ័ )

៥-របាទ ឬរេផៈ ( ៌ )

៦-ទណ្ឌឃាត ឬបដិសេធ ( ៍ )

៧-លេខទោ ឬអាមេណ្ឌិតសញ្ញា ( ៗ )

៨-លេខអស្ដា ( ៏ )

៩-វិសជ្ជនីយ ឬរះមុខ ( ះ )

១០-កាកបាទ ឬជើងក្អែក ( ៎ )

១១-យុគលពិន្ទុ ( ៈ ) វណ្ណយុត្តិទើបនឹងបង្កើតថ្មី សម្រាប់ប្រើ ចុចសម្រួលពាក្យឲ្យងាយថា)

ខ= ខណ្ឌសញ្ញាទាំងអស់មាន ៖

១-កក្កដនេត្រ ឬភ្នែកក្ដាម ( ៙ )

២-ល្បះ ឬខណ្ឌ ( ។ )

៣ – ល្បះបច់, ល្បះបរិយោសាន ឬ បរិយោសាន (។)

៤ – គោមូត្រ (៚)

៥ – កក់ ឬ តាប ឬ ឃ្នាប ({)

៦ – ផ្សញ្ញា (-)

៧ – យតិភង្គ (-)

៨ – មុច្ឆនសញ្ញា ឬ ពងត្រី ឬ ចំណុចកាយ (...)

៩ – បេយ្យាល (។បេ។) ឬ (។ល។)

ដោយហេតុមិនគ្រប់គ្រាន់ផង និងដើម្បីឲ្យទាន់ការប្រធម៌ ផង យើងយកខណ្ឌសញ្ញាខ្លះមកប្រើជាសម្បត្តិរបស់យើង ដូចតទៅនេះ ៖

១០ – ចំណុច (.)

១១ – ចុលភាគ ឬ ក្បៀស (,)

១២ – ចំណុចពីរ (៖) ឬ (:)

១៣ – មហាកាគ ឬ ចំណុចក្បៀស (;)

១៤ – បុច្ឆនសញ្ញា (?)

១៥ – អច្ឆរិយសញ្ញា, វិម្ហសញ្ញា, សំវេគសញ្ញា (!)

១៦ – អាគតសញ្ញា (<)

១៧ – គតសញ្ញា (>)

១៨ – វិឡាសសញ្ញាបើក បិទ-ឬអត្តន្តរៈឬអញ្ញប្រកាស (" „)

១៩ – នខសញ្ញា ឬ វង់ក្រចក ( )

២០ – សហសញ្ញា (-) (Trait d'union)

## វិធីប្រើវណ្ណយុត្តិ

១- វស្សសញ្ញា – (គ្រឿងសំគាល់ឲ្យដឹងថាមានសម្លេងខ្លី) ពាក្យនេះ វេយ្យាករណបណ្ឌិតខ្មែរ សន្មតជាឈ្មោះវណ្ណយុត្តិមួយយ៉ាង មានសណ្ឋានកំពុតខ្លី (ˈ) នេះសម្រាប់ប្រើញ៉ាំងស្រៈទីឃៈ "អ„ នឹង "អា„ ដែលប្រកប

នឹងខ្យល់ឲ្យជារស្សៈ គឺសម្រាប់ប្រើបំបែរសម្លេងវែងឲ្យខ្លីកំបុត
ជួន ប្រើដាក់បានចំពោះតែតួអក្សរប្រកបរបស់ពាក្យខ្មែរ
ប៉ុណ្ណោះ ដូចជា៖ កង់, បង់, ដំរង់, អត់, កត់, ចប់, ដល់,
កាប់, បាច់, ចំបាច់, កាន់, ស្គាល់, សំគាល់ ... ។

តែចំពោះស្រៈ "អា" ប្រកបនឹងខ្យល់ «ង» ដែល
ប្រើបំបែរសម្លេងវែង ឲ្យជាសម្លេងខ្លីនោះ មិនត្រូវប្រើរស្ស-
សញ្ញាទេ ត្រូវប្រើនិគ្គហិត (ំ) ពីលើស្រៈ "អា" ជា
ជំនួសវិញ ដូចពាក្យថា៖

តាំង, ពាំង, ចំណាំង, ចំបាំង, បង្ហាំង, បាំង. រាំង,
ទាំង, រនាំង, គ្រាំង, ក្បាំង, រគាំង, ឃ្លាំង, របាំង, ខាំង,
ផ្ទាំង, បាយក្តាំង, ប្រាំង, ថាំង, ញាំង, ស្រាំង ... ។

ឯអក្សរជាតួប្រកបរបស់ពាក្យ ហើយមានសមត្ថភាព
នឹងទទួលសញ្ញាបន្តក់នេះបាន មានតែអក្សរ ក, ង, ច,
ញ, ត, ន, ប, ល, ស, ប៉ុណ្ណោះទេ ។ អក្សរ

ក្រៅពីនេះ ពោះគាត់សំឡេងវែងជាទីគិដោយ ក៏មិនគាច ទទួលវណ្ណយុត្តិបន្តក( ់ )ដែរ ដូចជា៖ បទ, បបិ, សព, ភព ..ជាដើម ។ ត្តូប្រកបដែលមិនទទួលវណ្ណយុត្តិបន្តក( ់ ) ទាំងនោះគឺ៖

ខគឃ, ឆជឈ, ឋឋឍណ, ថទធ, ផពភ, យរវឡ

មួយវិញទៀត គ្ននិពាក្យដែលមកពីបាលី ឬសំស្រ្កឹត ដែលខ្មែរយើងយកមកប្រើ ក៏ពុំត្រូវដាក់បន្តក់នេះដែរ ដូចពាក្យ៖ ផល, កុសល, សាកល, ធនធាន, ជន, លាមក, ទុគិត ទុពិល, សត្វ, ខត្ត, ក្សត្រ, សម្បត្តិ...ជាដើម ។

២– មូសិកទន្ត ឬ ធ្មេញកណ្ដុរ ៈ– ខ្មែរយើងប្រើ វណ្ណយុត្តិមួយ យ៉ាងមានរូបជាគូសក្បៀសពីរ សណ្ឋាន ស្រដៀងនឹងធ្មេញកណ្ដុរ( ៉ )សំរាប់ប្រើបំប្លែងសម្លេងព្យញ្ជនៈ ៧ តួគឺ: ង ញ, ប, ម, យ, រ, វ, ឲ្យមានសម្លេង

ជា ង៉, ញ៉, ប៉, ម៉, យ៉, រ៉, វ៉ ឬសម្រាប់ថែម លើអក្សរនៅខាងដើមព្យាង្គពាក្យ កាលណាពាក្យនោះគ្មានសព្ទព្យាង្គឯទៀតបន្ថែមមកឬព្យាង្គនោះទោល គឺជាប់តែឯង ដូចជា៖ ប៉ន្តែ, ប៉ុន្មាន, ប៉ុណ្ណោះ, ញ៉ើះញ៉ោះ, ម៉ៃ ម៉ដ្ត ឬ ម៉ដ្ឋ, ម៉ត់ចត់, ម៉ោង, ប៉ុណ្យង៉ាន, រៀងរ៉ាវ, រ៉ាន់ ស៊ុយ... ជាដើម ។ បើកាលណាតួអក្សរដើមព្យាង្គបន្ថែមមក មិនត្រូវដាក់មូសិកទន្តទេ ដូចពាក្យថា៖

ប្រមោយ ប្រមាទ, ស្រវឹង, បម្លុក, សង្វាត, អង្វរ... ជាដើម ។

ចំពោះអក្សរ "ប" មិនគាប់ទៅជា "ប៉" បានគួរលំនៅរបស់ខ្លួននៃពាក្យនីមួយៗទេ គឺថាមិនផ្លល់ដោយងាយទៅតាមព្យាង្គខាងដើមជាអឃោសៈនោះទេ បើចង់ឲ្យមានសម្លេងជាអឃោសៈដូចព្យាង្គខាងដើម ពាល់តែដាក់មូសិកទន្តជាដាច់ខាត។ បើពុំនោះសោតពាក្យ "សំបា - តំបាញ - ដម្បាញ

បំបាប់ , បំប៉ាំង ,, ទឹងគានថា សំប៉ា , បំប៉ាប់ , តំប៉ាញ , បំ-ប៉ាំង នោះមិនត្រូវឡើយ ។ ឯ "បម្ប៉ា , បំប៉ី ,, ត្រូវសរសេរដាក់មូសិកទន្ត បើមិនដាក់ទឹងឲ្យគានថាជា "បំ ប៉ា, បំ-ប៉ី ,, មិនបានឡើយ ។

វណ្ណយុត្តនេះ កាលណាបើមានស្រៈនិស្ស័យ ៥ តួ គឺ ិ ី ឹ ឺ ទឹង ើ នៅពីខាងលើត្រូវផ្លាស់រូប " ៉ ,, ជា " ុ ,, វិញ ដូចឧទាហរណ៍តទៅនេះ ៖ ងុិកង៉ក់ , ញុិកញ៉ក់ , ញុាំញុើ , មុឹង , រុី , ប៊ិនប៉ៅ , តុឹង , រុឹង , ប៊ុឹង , យ៉ាប់យុឹន ... ជាដើម វណ្ណយុត្តនេះសម្រាប់ប្រើដាក់លើស្រៈ ិ ឲ្យទៅជា ុិ ក៏បានៗ

## ៣–ត្រីសព្ទ ( ៊ ) –( សូរសម្លេង ៣ យ៉ាង ) ខ្មែរ

យើងប្រើជាឈ្មោះវណ្ណយុត្ត ( ៊ ) នេះ សម្រាប់ដាក់លើអក្សរ ៤ តួគឺ ប , ស , ហ , អ , ដែលមានសម្លេងគ្រលួច ឲ្យទៅជាព្យញ្ជនៈសម្លេងគ្រលរជា ប៊ , ស៊ , ហ៊ , អ៊ ដូចពាក្យថា ៖ ប៊ុត , សាប៊ូ , ស៊ីងស្វា , ព្រុស៊ាន , ស៊ុន ប៊ូល-ហ៊ុន , ហ៊ុនត្រចៀក , អ៊ុតសក់ , មិនហ៊ានទៅ , ដំណើរអ៊ក-

អ៊ាក ... ជាដើម ។

តែបើកាលណាមានស្រៈនិស្ស័យ៩តួគឺ ិ ី ឹ ឺ ើ និង ើ នៅកាស្រ័យពីខាងលើត្រូវផ្លាស់រូប "៊" ជា "ុ" ដូចមូសិកទន្តដែរ ដូចជាពាក្យថា៖ សុីឃាយ , ទៅមើលហុី , កុំដើរលេងហុឺហាពេក , សើុបការ ... ជាដើម ។

ចំពោះស្រៈនិស្ស័យ ១ តួគឺ "ុំ" (អុំ) កាលបើមានព្យញ្ជនៈកាស្រ័យហើយ ត្រូវផ្លាស់និគ្គហិត "ំ" នេះជា "ម" វិញជាដកបដូចពាក្យថា៖ ស៊ុមទ្រុម , រំហ៊ុម , ជាហ៊ុម , ធ្វើស៊ុម... ។ ឯស្រៈអាំ ( អាំ ) ត្រូវផ្លាស់ត្រីសព្ទជា ( ុ ) វិញ ដូចជា សុាំក្អែក... ។

៤ – សំយោគសញ្ញា ( ៑ ).- (គ្រឿងសំគាល់អក្សរគម្រូត) យើងប្រើជាឈ្មោះវណ្ណយុត្តមួយសណ្ឋានដូចបុះ ( ៑ ) ជាជំនួសអក្សរសំយោគសម្រាប់ដាក់លើពាក្យបាលី ឬសំស្រ្កឹតពួកខ្លះ ដែលប្រើបំប្លែងសម្លេងឲ្យក្លាយល្អៀងពីសូរ

ដើម កាលបើមិនដាក់សំយោគសញ្ញា (់) នេះទេ នាំឲ្យពិ-

ធាកថា ហើយត្រូវអានដូចស្រះ "អា" ប្រកបនឹងខ្យល់មាន

សេស្រ ដូចពាក្យថា ៖ ក្ស័យ, ជ័យ, វិន័យ, ជលន័យធិ,

ជលស័យ, ចិនក្ស័យ, ច័ល, ចព្ទ័ន, ភ័យ, ទេវាវិនិច័យ

ន័យ, នភាល័យ, និរភ័យ, នព្វ័តន៍, នង្គ័ល, ពនាល័យ,

ហ័ស, វេស្ម័ន, វេស្ស័ណ្ណ, អនាម័យ, អាល័យ, អាស្រ័យ,

បរិស័ទ, និស្ស័យ, បរាសម្ព័ទ, ប្រល័យ, ប្រាស្រ័យ,

ពិជ័យសង្គ្រាម, ពិសម័យ, មហាត្ម័ន, វិទ្យាល័យ, អាត្ម័ន...

នេះជាដើម ។

ពោះបីពាក្យដែលមានអក្សរសំយោគហើយ ប៉ុន្តែបើ

មិនដាក់សំយោគសញ្ញា (់) នេះផង់ដែរទេ នាំឲ្យពិធាកថា

ត្រូវប្រើសំយោគសញ្ញាថែមទៀតក៏មានខ្លះ ដូចជាពាក្យថា៖

ប័ក្កប័ន, ប្រប័ណ្ណ, ប្រយ័ត្ន, ភ័ព្វភ័ព្យ, ប្រវ័ញ្ចន៍, និល

រ័ត្ន, នារីរ័ត្ន, ភ័ក្ត្រ, ពិភ័ក្ត, ល័ក្ខណ៍, ម្រ័ក្សណ៍, លាយ

ល័ក្ខ, ស័ក្តិសិទ្ធិ, ស័ប្ត, ស័ព្វ, ស្រស័ព្វ, ស័ក្រ, អភ័ព្វ,

អាចម៍ល័ក្ខ, អធិស័ព្វ .. ជាដើម ។

ក្រៅពីពាក្យបាលីឬសំស្ក្រឹត សំយោគសញ្ញា ( ័ ) មានប្រយោជន៍សំខាន់មួយទៀត សម្រាប់ប្រើក្នុងពាក្យខ្មែរក៏មានខ្លះ ដូចជា៖ ជ័រ, ញ័រ, ទទីទ័រ, ទីទ័ង, វ័ង, ទំព័រ, ស្ពានជ័រ, ទំប័ង, ដើមសំព័រ, សង្ស័រ . . ជាដើម ។

សម្រាប់ប្រើក្នុងភាសាបរទេសក៏មានខ្លះដូចជា៖ កុងត្រូល័រ, ឌីរ៉ិកទ័រ, អាមេរិក័ង, អូស្ត្រាលីយ័ង . . . ជាដើម ។

សំយោគសញ្ញា ( ័ ) នេះមិនត្រូវដាក់តាមតែបាន តា

តែរូបពីដៃនោះទេ ត្រូវដាក់នៅលើព្យញ្ជនៈខាងដើមនៃ

ប្រកប ដូចជា «ទំព័រ» ត្រូវដាក់សំយោគសញ្ញាពីលើ "ព

មិនត្រូវដាក់ខុសពីនេះឡើយ ។

៥- របាទ( ៌ )— ជើងអក្សរ "រ" (ហៅដោយសន្ទ

មានរូបសណ្ឋានដូច្នេះ " ៌ " ។ ក្នុងសិលាចារឹកខ្មែរបុរ

ច្រើនប្រើ "រ" ពេញតួ សម្រាប់ប្រើដាក់អក្សរតួចុង ឲ្យ អក្សរតួដើមបន្ទាប់នោះមានសូរសម្លេងញ័រ ប្រើចំពោះតែពាក្យ សំស្ក្រឹតឬសំស្ក្រឹតក្លាយ ដូចជា តក៌, ទុគ៌ត, ទុព៌ល, ធម៌, បព៌ត, ពណ៌, កាថ៌ ... ជាដើម ។ តែបើមានស្រៈដែល ទើសពិបាកសរសេរ នោះត្រូវដាក់អក្សរ "រ" ពេញតួ ពី លើអក្សរខាងចុងវិញ ដូចជា៖ ទុក៌្យ, តិរ្យ, អន្យតិរ្យ, កមគេ៌ ... ជាដើម, ជួនកាលមិនមានស្រៈជាទើសទែងទេ ប៉ុន្តែគួរឲ្យច្រឡំពិបាកអានក៏ត្រូវដាក់តួ "រ" លើដើមអក្សរ ខាងចុងបានដែរ ដូចជា អស្ចា៌យ, កា៌យ ... ប្រើជា អស្ចារ្យ, ការ្យ. ជាដើម ។ តាមរបៀបនេះប្រហែលជាប្រើ សម្រួលឲ្យងាយមើល, ងាយថាប៉ុណ្ណោះទេ ។ ម្យ៉ាងទៀតជួន ណាមិនមានស្រៈជាទើសទែង ហើយមិនពិបាកអានផង ក៏នៅ តែដាក់តួ "រ" ពេញទីដែរ ដូចជា ទុគ៌ម, ទុព៌ល, ទុគ៌ត បព៌ត ... ប្រើជា ទុរគម, ទុរពល, ទុរគត, បរពត ... ក៏បាន ។

បើមានអក្សរ "រ" ជាតួប្រកបពីខាងចុង នឹងប្រើរបាទ (៌) នេះផងពុំបានទេ ដូចជា ជ័រ, ដើមសង្ស័រ, ញ័រ, ទទ័រ.... ជាដើម យ៉ាងនេះត្រឹមត្រូវហើយ កុំសរសេរជា ជ័រ៌, ដើមសង្ស័រ៌, ទទ័រ៌, ញ័រ៌, ឬជា ជារ៌, ទទារ៌, ញញារ៌, ដូច្នេះឡើយ ។

តួអក្សរដែលមិនសូវប្រើច្រើន គ្រាប់ តួតម្រួតអក្សរនោះផ្លាស់ជារបាទ (៌) ។ បើតួអក្សរណាធ្លាប់ប្រើគ្រាប់ក្នុងច្រើន តួតម្រួតអក្សរនោះផ្លាស់ជា "រ" គ្រាប់ ។

តួតម្រួតផ្លាស់ជា (៌) ដូចនេះ៖

ណ្ណ > ណ៌, ម្ម > ម៌, ត្ត > ត៌, ក្ក > ក៌៖

ដូចជា៖ វណ្ណ > ពណ៌, ធម្ម > ធម៌, បុញ្ញ > បុញ៌, តក្ក > តក៌ ។

តួតម្រួតផ្លាស់ជា "រ" គ្រាប់ដូច្នេះ

ក្ក > ក្រ, គ្គ > គ្រ, ត្ត > ត្រ, ទ្ធ > ទ្រ, ស្ស > ស្រ

ដូចជា៖ ចក្ក > ចក្រ, អគ្គ > អគ្រ, ខត្ត > ក្សត្រ, សមុទ្ទ > សមុទ្រ, អស្សម > អស្រម . . ។ ប៉ុន្តែមានអក្សរខ្លះដែលធ្លាប់ប្រើច្រើនដង គេរាត់ជាប់ដោយរេផ (៌) ខ្លះក៏មានដែរ ដូចជា កក្កដ > កក៌ដ, វិសជ្ជនីយ > វិសជ៌នីយ, មគ្គ > មាគ៌, សគ្គ > ស្វគ៌, សួគ៌. . . ជាដើម ។

៦. ទណ្ឌឃាត (៍) សម្រាប់បដិសេធតួអក្សរដែលមានលើសពីការ ដូចជា៖ រតន៍, ហេទក៍, ពេទ៍, ប្រយោជន៍, យោជន៍, ប្រព័ញ្ច៍, ស្រមណ៍, ពិសោធន៍, ក្សត្រិយ៍, វេយ្យាករណ៍, ព្យាករណ៍, ... ជាដើម ។

សញ្ញានេះ មានប្រើចំពោះតែក្នុងពាក្យណាដែលយើងមកពីភាសាដទៃ ដូចជាបាលីឬសំស្ក្រឹតជាដើមប៉ុណ្ណោះ ក្នុងពាក្យខ្មែរសុទ្ធគ្មានប្រើវណ្ណយុត្តិនេះទេ ។ ដូច្នេះអក្សរដែលប្រើទណ្ឌឃាត ពីលើគ្មានប្រយោជន៍ខាងសូរសាស្ត្រឡើយ (pas de valeur phonétique) លោកដាក់អក្សរនោះផង

គ្រាន់តែឲ្យដឹងឫសគល់របស់ពាក្យតែប៉ុណ្ណោះ ឬ បើពោលម្យ៉ាងទៀត គឺជាដើម្បីសំគាល់និរុត្តិសាស្ត្ររបស់ពាក្យ (valeur étymologique) តែប៉ុណ្ណោះ ។

៧-លេខទោ ឬ អាមេណ្ឌិតសញ្ញា (ៗ) "លេខផ្ទួន ឬ គ្រឿងសំគាល់ពាក្យផ្ទួន" ខ្មែរយើងប្រើជាឈ្មោះវណ្ណយុត្តិមួយយ៉ាង មានសណ្ឋានខាងក្បាលឬខាងលើជាលេខ២ ប៉ុន្តែខាងកន្ទុយឬខាងក្រោមទាញចុះ(ៗ)នេះ សម្រាប់សរសេរពីខាងចុងពាក្យដែលត្រូវជាផ្ទួន ដូចជាផ្សេងៗ, ទៃៗ, តូចៗ, ធំៗ, ប្រុសៗ, ស្រីៗ, ដើមមួយៗ, ម្តងៗ, ចាស់ៗ, ក្មេងៗ... ជាដើម ។

ផ្ទួនកាលលេខទោ ឬ អាមេណ្ឌិតសញ្ញា (ៗ) នេះធ្វើឲ្យមានផ្ទួនមិនត្រឹមតែពាក្យមួយម៉ាត់ខាងចុងបង្អស់ ដូចពាក្យឧទាហរណ៍ខាងលើនេះទេ ត្រូវផ្ទួនពាក្យ ២ ឬ ៣ ម៉ាត់ក៏មាន ស្រេចតែករណី (Selon le cas) មិនមានអ្វីជាចំណាំក្រៅ

សេចក្ដីរបស់រឿងដែលមាននោះឡើយ ដូចជាពាក្យថា៖ ទៅបន្តិចម្ដង ៗ (ពាក្យ ២ ម៉ាត់), ចេញពីរនាក់ម្ដង ៗ (ពាក្យ ៣ ម៉ាត់), មើលម្ដងពីរនាក់ ៗ (ពាក្យ៤ម៉ាត់) ។

លេខទោសំរាប់ធ្វើឱ្យមានផ្ទួនពីរដងជាប់គ្នា មិនមែនសំរាប់វៀរជៀសមិនសរសេរពាក្យដដែលពីរដងនោះទេ ។ ហេតុនេះពាក្យណាត្រូវអានពីរដង តែមិនមែនផ្ទួនគ្នា ត្រូវតែសរសេរពាក្យនោះពីរដង មិនត្រូវដាក់អាមេណ្ឌិតសញ្ញាឡើយដូចពាក្យថា ៖ ទីលំនៅ នៅភូមិផ្សារកាប់គោ, ស្រេកពេករត់ទៅរកទឹក ទឹកក៏អស់ពីពាង, ឈឺពោះពេកខំតែជុះ ជុះក៏មិនចេញថែមទៀត ។ ក្នុងប្រយោគទាំងនេះមិនត្រូវដាក់អាមេណ្ឌិតសញ្ញា (ៗ) ជាដាច់ខាត ព្រោះមិនមែនត្រូវអានថា លំនៅៗ, ទឹកៗ, ជុះៗ ផ្ទួនជាប់គ្នានោះទេ ។

ក្នុងពាក្យបាលីដែលយើងយកមកប្រើ ក៏មិនត្រូវដាក់អាមេណ្ឌិតសញ្ញានេះដែរ ដូចជា អាបោ អាបោ, នានា...

ត្រូវសរសេរជាពីរពាក្យយ៉ាងនេះទៅវិញ ។

៨-លេខអស្ដា (៏).- វណ្ណយុត្តិនេះសម្រាប់ដាក់លើព្យញ្ជនៈ៤តួគឺ ៖ ក (ក៏), ដ (ដ៏), ហ (ហ៏), ន (ន៏) ធ្វើសំឡេងឲ្យខ្លីទំនងដូចជាស្រៈសញ្ញា ដូចជា ៖ ក៏បាន, ក៏មាន, ក៏ដោយ, ដ៏ប្រសើរ, ដ៏មានបុណ្យ, ឮដ៏អាកាសវេហាស៍, ហ៏យកចុះ! ន៏ន៏! .... ជាដើម ។

៩-វិសជ្ជនីយ ឬ រះមុខ (ះ): តាំងអក្សរទេវនាគរី (សំរាប់សំស្ក្រឹត) ប្រើជាចំណុច១គូលើក្រោម ដូចយុគលពិន្ទុ (:) ។ ប៉ុន្តែយើងបានយុគលពិន្ទុទៅហើយ បើយើងប្រើវិសជ្ជនីយឲ្យដូចយុគលពិន្ទុដូចសំស្ក្រឹតនោះ នាំឲ្យច្រឡំជាពន់ប្រមាណណាស់ ។ ដោយហេតុនេះយើងគាំងនាំគ្នាប្រើសញ្ញាវិសជ្ជនីយនេះជាដុំមូល១ ធំ ១ មួយគូលើក្រោម (ះ) ជាបែបយ៉ាងនេះវិញ ។ វិសជ្ជនីយ មានខ្យល់ស្រដៀងនឹងខ្យល់អក្សរ "ស" ដែលជាតួប្រកប នៅក្នុងពាក្យដែលកើត

ទៀតពីស្រៈ អ, ិ, ុ, េ, ែ, ោ, ើ, (ស្រៈ ើ មិន
សូវមានប្រើវិសជនីយទេ ) ប៉ុន្តែមិនចេញសូរសម្លេងតាម
ប្រទល់ធ្មេញដូចតួព្យញ្ជនៈ «ស» ទេ ដូចជា៖ «គោ ដុះ, ពោះ»
សូរខុសគ្នានឹង «គោ ឆ្នាស់, ពស់» ។ ពាក្យសំស្ក្រឹតដែល
មានតួ «ហ» នៅខាងចុងបើផ្លាស់ «ហ» ជាវិសជនីយ
(ះ) ហើយមិនត្រូវប្រើ «ហ» ថែមទៀតទេ ដូចជា៖
…ហ, បទ្ធគ្រាហ, សំគ្រហ, អនុគ្រហ, ទៅជា៖ គ្រឹះ
…ទ្ធគ្រោះ, សង្គ្រោះ, អនុគ្រោះ, ហើយកុំប្រើជា៖ គ្រឹះហ៍
…ទ្ធគ្រោះហ៍, សង្គ្រោះហ៍, អនុគ្រោះហ៍ ឡើយ ។

## ១០- កាកបាទ ឬ ជើងក្អែក (+) សម្រាប់ដាក់លើ

ពាក្យឧទានសព្ទ ឬលើពាក្យគួរឲ្យស្រណោះនឹងពាក្យវិសេសន
សព្វនាមខ្លះ ដូចជា៖ ចា៎ះ, បងណា៎ហើយ ណា៎អូនណា៎,
ណា៎នាងណា៎, នុ៎ះ, នុ៎ះនុ៎ ។

សម្រាប់ជ្រៀតពាក្យដែលខ្វះហើយនាំយកមកសរសេរ ។

បន្ថែមជាក្រោយ ដាក់ខាងលើ ឬ ខាងក្រោមបន្ទាត់ ( ហៅថា ការដើងក្អក )

សម្រាប់សំគាល់ថា “ ទឹង ” ឬ “ ហើយទឹង ” ដូចជា៖ ក + ហ > ១ គានថា៖ ក ទឹង ហ ទៅជា “១” ឬ ក ហើយទឹង ហ ទៅជា “ ១ ” យ៉ាងនេះក៏បាន ។

សម្រាប់ជាសញ្ញាលេខបុគ្គនិវិធនពន្ធ ។

១១ – យុគលពិន្ទុ (:) ( ចំណុចមួយគូ ) ជាឈ្មោ វណ្ណយុត្តិមួយ យ៉ាងសម្រាប់ញ៉ាំងស្រៈ “ អ ” ដែលជាទីបំផុត ពាក្យបាលីទឹងសំស្ក្រឹតឲ្យបញ្ចេញសូរសំឡេងពេញមាត្រា ដើម្ ឲ្យអាយុគុណការគាំងឲ្យបានត្រឹមត្រូវហ្មតចត់ល្អ តាមបែបបា ឬសំស្ក្រឹត ដូចជាពាក្យថា៖ ឃោសៈ, ជាវៈ, ជីវៈ ទស្សនៈ, ការៈ, ធុរៈ, ទាសៈ, បការៈ, បស្សាវៈ, ប សណ្ឋារៈ, សក្ការៈ, វិរិយៈ, ភយៈ, រស្សៈ, សក្ការៈ ព្យញ្ជនៈ ភាវៈ, ភេសជ្ជៈ, មរណៈ, លក្ខណៈ, លាភ

ភាជនៈ, សក្ការៈ, សម្បជញ្ញៈ, សមណៈ, ខេមរៈ, ស្រះ, សរៈ, សិរៈ, សភាវៈ, សេនាសនៈ, អាជីវៈ, អមតៈ, អាយតនៈ, ទុក្ខៈ, ឧបការៈ, អក្ខរៈ, ... ជាដើម ។ ប៉ុន្តែពាក្យដែលជាសមាសនាមមានដើមថា៖ កម្ពុជរដ្ឋ, ខេមរដ្ឋ, ខេមរជាតិ, មរណភាព, មគធភាសា, កលបុត្រ, សក្ការ-បូជា ... យ៉ាងនេះ កុំបូកអក្សរគណ្ឋលជា៖ កម្ពុជៈរដ្ឋ, ខេមៈរដ្ឋ, ខេមរៈជាតិ, មរណៈភាព, មគធៈភាសា, កលៈបុត្រ, សក្ការៈបូជា ... ដូច្នេះឡើយ ។

មួយទៀត យុគលពិន្ទុនេះ មិនមានសម្ដែងទេចំពោះពាក្យខ្មែរសុទ្ធ តែសូមឲ្យមានពាក្យនេះគញ្ជាក់សំឡេងទៅវិញ ដូចជា៖ ទេហៈ ហឹៈ, ហោៈ, ហៃៈ ... ជាដើម ។

សញ្ញានេះ សូមកុំឲ្យយកមកនិយមប្រើជាវិសជ្ជនីយ ឬចំណុចពីរ (៖) (Deux points: ជាវណ្ណយុត្តិរបស់អឺរ៉ុប) បែបនេះឡើយ ទុកជាយើងធ្លាប់ប្រើថា យុគលពិន្ទុជាជំនួស

ចំណុចពីរតាមបែបអឺរ៉ុបនោះក៏គួរតែកែប្រែចេញ ព្រោះយើងមានចំណុចពីរ (ៈ) របៀបនេះទៅហើយ ម្យ៉ាងទៀតជាប្រយោជន៍ដើម្បីកុំឲ្យច្រឡំគ្នាផង ។

យុគលពិន្ទុនេះ ជាវណ្ណយុត្តិដែលទើបនឹងកើតថ្មីដោយសារស្នាព្រះហស្តសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត កាលនៅជាព្រះពោធិវង្សនៅឡើយ ។

## វិធីប្រើខណ្ឌសញ្ញា

១–កុក្កុដនេត្រ ឬភ្នែកមាន់ ( ៙ ) សម្រាប់ដាក់នៅដើមបទកំណាព្យឃ្លោង ៗ តាមបុរាណសម័យ លោកប្រើវណ្ណយុត្តិនេះដាក់នៅដើមលិខិត ឬរឿងរ៉ាវផ្សេងៗជាគូនឹងគោមូត្រ ( ៚ ) តែសម័យបច្ចុប្បន្ននេះមិនសូវប្រើទេ ។

២–ល្បះឬខណ្ឌ ( ។ ) សម្រាប់ប្រើកំណត់ឃ្លាឬសង្កាត់សេចក្ដីមួយៗឲ្យដាច់ស្រឡះដោយឡែក ។ ឯល្បះជគបន្ទាត់

ឬល្បះលុកបន្ទាត់ក៏មានរូបដូចគ្នាដែរ គ្រាន់តែបញ្ឈាក់ដល់អ្នកសរសេរ ឲ្យសរសេរត្រង់បន្ទាត់មួយខាងក្រោមបន្ទាប់គ្នា នោះឲ្យលុកចូលមកខាងក្នុងបន្តិច ។

ល្បះមានប្រយោជន៍សំខាន់ម្យ៉ាងទៀត ក្នុងការកត់ត្រាថ្ងៃខែតាមចន្ទគតិដូចជា ភ្នំពេញនៅថ្ងៃ᧥ ១០ ឆ្នាំមមី ឆស័ក ព.ស. ២៤៩៧ ។ លេខខាងឆ្វេងល្បះជាលេខថ្ងៃ , លេខខាងលើសំរាប់កត់ខ្នើត , បើជារនោចវិញលោកដាក់ខាងក្រោមល្បះ , លេខខាងស្ដាំជាលេខខែ ។

៣-ល្បះបប់ឬល្បះបរិយោសាន (៚) ឬយ៉ាំងនេះ ( ? ៙— ) សម្រាប់បញ្ចប់សេចក្ដីដែលអស់ត្រឹមតែប៉ុណ្ណោះ ។ ល្បះបប់ឬល្បះបរិយោសាននេះមិនមានកំណត់ឲ្យប្រើបែបណាជាថែបណាទេ តែគួរប្រើត្រឹមតែល្បះក៏បានហើយ ។

៤-គោមូត្រ „ទឹកនោមគោ„ វណ្ណយុត្តិនេះ

មានសណ្ឋានស្រដៀងនឹងកន្ទាញទឹកនោមគោ (ចុះ—
សម្រាប់ប្រើដាក់ក្នុងទីបញ្ចប់ពាក្យកាព្យឃ្លោង ជាគូនឹងភ្នែក
មាន់ដែលដាក់ខាងដើម ។

៥–រាត់ឬគាបឬឃ្នាប ( { ) វណ្ណយុត្តនេះសម្រាប

សរសេរតាមពាក្យទន្ទឹមគ្នាដូចជាថ្ងៃ៨ កើត / កេច } នឹង ១៥ កើត / កេច } ឬ
១៤កេច ; តែសម័យឥឡូវមិនសូវប្រើ ច្រើនសរសេរតយ
គ្នាវិញ ដោយប្រើវណ្ណយុត្តិអាំប (, ;) នេះជំនួសវិញ ជា៖
ថ្ងៃ៨កើត, ៨កេចនឹង១៥កើត, ១៥កេចឬ១៤កេច ដូច្នេះ
វិញ ។

៦–វង្ឃុសញ្ញា ឬ ឥយសញ្ញា (–) សម្រាប់ប្រើគូស
ខាងចុង ពាក្យដែលមានសេចក្ដីដូចគ្នានឹងខាងដើមឬសម្រាប់
គូសខាងក្រោមពាក្យដែលត្រូវទន្ទេញឲ្យចាំ ឬដែលជាសេចក្ដី

សំខាន់ គួរឲ្យពិចិតពិតប្រាកដ ។ ឧទាហរណ៍ដូចជា "វចន-ករ, – ការ, – ការក:, – ការី" ផុសញ្ញាដែលប្រើក្នុងពាក្យឧទាហរណ៍នេះ ជាជំនួសពាក្យខាងដើម គឺ "វចនៈ" ជា វចនការ, វចនការក:, វចនការី ។ ឬដូចជា "អនាគតរបស់ប្រទេសកម្ពុជា សង្ឃឹមលើ ពលរដ្ឋខ្មែរស្នេហាជាតិ" បន្ទាត់ដែលគូសពីក្រោមពាក្យ "ពលរដ្ឋខ្មែរស្នេហាជាតិ" ហៅ "ឧយសញ្ញា" ។

សម្រាប់ខណ្ឌពាក្យនិយាយឆ្លើយឆ្លងគ្នា ដូចយើងបានឃើញក្នុងសៀវភៅប្រលោមលោកផ្សេងៗ ឧទាហរណ៍ដូចជា

– អ្នកឈ្មោះអ្វី ?

– ពន្ធកបុត្រ

មានបងប្អូនប៉ុន្មាននាក់ ?

– ខ្ញុំជាបុត្រតោលនៃគ្រួសារ

សម្រាប់ប្រើដាក់ក្រោយលេខរៀង និងក្រោយចំណង

ដើងខ្វះដូចមានប្រើពាសពេញក្នុងសៀវភៅនេះស្រាប់ ៗ

៧ - យតិភង្គ (-) : ខណ្ឌសញ្ញានេះមានសណ្ឋាន ប្រហែលគ្នានឹង សហសញ្ញា (ប៉ុន្តែគប្បីយើងគូសឲ្យខ្លីជាង សហសញ្ញា) សំរាប់ប្រើក្នុងពាក្យកាព្យឃ្លោង ត្រង់ពាក្យ ពហុព្យាង្គណាដែលត្រូវបំបែកជាពីរ ដើម្បីឲ្យបានជួន(Rime) ឬឲ្យត្រូវបង្អាក់ (Rythme) ។

ឧទាហរណ៍ :

រំកោលក្នុង - ត្រីស្វាត់ខាងជា - យាព្រះមហាក្រ - សំត្រៃថ្ងៃថ្កើង - ថ្កានគេដះប - វិរត្នផ្ញុំស្រែ - មៃទឹកស្វាម ៗ

៨- មប្ពុណ្ណសញ្ញា ឬពងត្រី ឬបំណុបរាយ ( ...) សម្រាប់ប្រើបុចពាក្យណាមួយ សំដែងថាសេចក្តីនេះនៅ មានតទៅទៀត តែមិនចាំបាច់គំនប់ពេញសមេង្គុំឡើយ ដូចជាពាក្យថា ៖

ឧទាហរណ៍ : ឆ្នាំស្លូនម្នាក់បានចិញ្ចឹម គោ, ក្របី, សេះ,

ជ្រុក, មាន់, ទា ... ។

៩- បេយ្យាល (។បេ។) ឬ (។ល។): គេសរសេរកាត់ដាក់តែអក្សរដើម ។បេ។ អានថា "បេ" យ៉ាងនេះក៏បាន ឬ ដាក់តែអក្សរចុងបំផុត ។ល។ អានថា "ឡៈ" ក៏បានសម្រាប់ប្រើក្នុងសេចក្តីដែលនិយាយមិនទាន់ចប់ ហើយបញ្ឈប់សេចក្តីនៅត្រឹមនោះទៅ ឬ ពាក្យដែលគេមានខាងដើមមកហើយ មិនបាច់ដាក់ពាក្យនេះមកទៀតទេ ។

ឧទាហរណ៍: ព្រៃនេះមានសត្វច្រើនណាស់ គឺ ខ្លា, ដំរី, ទីង, ទន្សោង, រមាំង ។ល។ ។

១០- បំណុច (.): ខណ្ឌសញ្ញានេះកាលប្រើតាមគំរូ ត្រូវប្រើសម្រាប់ខណ្ឌប្រយោគនីមួយ ៗ ឲ្យដាច់ស្រឡះពីគ្នា តែខ្មែរយើងមិនប្រើសម្រាប់ខណ្ឌប្រយោគដូច្នោះទេ ព្រោះយើងមានល្បះនេះ (។) ទៅហើយ ដូចនេះបំណុច (.) មាននាទីសង្ខេបពាក្យទៅវិញដូច៖ ក. ជំនួស កិរិយា

សព្ទ. ន. ជំនួសនាម ; ។· ជំនួសឧទាហរណ៍. ជាដើម។

ឯកទីនពន្ធ ក៏ត្រូវប្រើចំណុចនេះជាគ្រឿងសម្គាល់ខ្ទង់ដែរ ដូចជា៖ ១.៥០០ ; ៣១.៤០០... ។

១១–បុល្លភាគមុក្បៀស ( , )៖ ខណ្ឌសញ្ញានេះ សម្រាប់ញែកពាក្យ ដែលនៅប្រយោគជាមួយគ្នាឲ្យជាបជាភាគ ។ តាមសមគួរដល់សេចក្ដី៖

ឧទាហរណ៍: នាយសួននេះចិញ្ចឹម គោ, ក្របី, សេះ, ពពែ ទីងជ្រូកច្រើនណាស់ ។

ក្រៅពីនេះក្បៀសនៅប្រើក្នុងលេខនព្វន្ធទៀត៖

ឧទាហរណ៍: ២, ៥០, ៧, ៥០, ៨, ៧០... ។

១២ មហាភាគ ឬ បំណុចក្បៀស ( ; ) សម្រាប់

ញែកសេចក្ដីក្នុងប្រយោគជាភាគៗធំជាងភាគដែលប្រើដោយ

ក្បៀស ឬ ដកឃ្លា ប៉ុន្តែតូចជាងភាគដែលប្រើដោយខណ្ឌ ។

ឧទាហរណ៍: ខ្លាមួយលាក់អំពាក្នុងដុបព្រៃ ; ចាំឃ្លាំមើល

ជានិច្ច ។

១៣_ បំណុចពីរ (:) ខ្មែរយើងប្រើដូចបេះវិញ (៖)

បំផែងជាទីងមានសេចក្ដីអធិប្បាយតទៅ ឬ ប្រើជាគ្រឿង .

សំគាល់ការបន្ថែមពាក្យ ឬ សេចក្ដីខាងមុខ ៖

ឧទាហរណ៍: មាតាលួងលោមបុត្រថា៖ កូនពៅម្ដាយ អ្នក

ត្រូវខិតខំរៀនសូត្រ ។

បានជាខ្មែរយើងក្រៃឲ្យចំណុចពីរ ( : ) ក្លាយទៅជា

ានសណ្ឋានមូលពីរហើយមានគំនូសមួយកណ្ដាលដូចបេះ( ៖ )

ម្បីកុំឲ្យច្រឡំនឹងយុគលពិន្ទុ ។

១៤-- បុច្ឆនសញ្ញា (?) សម្រាប់ដាក់ខាងចុងនៃពាក្យសួរ, ដណ្តឹង ឬសង្ស័យអ្វីមួយ ។

ឧទាហរណ៍: អ្នកឯងឈ្មោះអ្វី? នៅស្រុកណា?

បើសេចក្តីសួរនោះជាសេចក្តីសួរដោយផ្ទាល់ មិនត្រូវប្រើបុច្ឆនសញ្ញាឡើយ ។

ឧទាហរណ៍: ខ្ញុំចង់ដឹងថាអ្នកនិយាយពីអ្វី ក្នុងពេលអម្បាញមិញនេះ ។

១៥-អច្ឆរិយសញ្ញា, វិម្ហសញ្ញា, សំវេគសញ្ញា (!)

ក-អច្ឆរិយសញ្ញា (!) សម្រាប់ដាក់ខាងចុងពាក្យរបស់អ្នកនិយាយដែលគេកោតញញើត, ស្ញប់ស្ញែងឬអស្ចារ្យនឹងអ្វីមួយ ។

១- ឃើអើ! ខ្ញុំមិនដែលឃើញសោះទេតើ! ឃើ! អស្ចារ្យមែន!

ខ – វិម្ហយសញ្ញា (!) សម្រាប់ដាក់ខាងចុងពាក្យរបស់អ្នកនិយាយ ដែលមានសេចក្ដីសរសើរ ឬស្រឡាញ់ចូលចិត្តនឹងរបស់អ្វីមួយ ។

ឧ – ឃើ! ចំឡែកមែន! យ៉ាអើ! ល្អស្អាតម៉្លេះទេ!

គ – សំវេគសញ្ញា (!) សំរាប់ដាក់ខាងចុងនៃសេចក្ដីថ្លែងរៀបរាប់ដែលនិយាយទៅហើយ មានដំណែងគួញ ឬធុញទ្រាន់, ក្រៀមក្រំចិត្ត, លំបាកចិត្ត៖

ឧ អកុសលអ្វីខ្ញុំហ្ន៎! ឱ! ទេវតាអើយ! ឃើ! អផ្សុកណាស់!

១៦. អាគតសញ្ញា (<) សម្រាប់សម្គាល់ឲ្យដឹងថា ‘‘មកពី,,

ឧ – ទុដ្ឋ < ទុស្ឋ, ជេដ្ឋ < ជេស្ឋ, ក្សត្រ < ខត្ត ។

១៧. គតសញ្ញា (>) សម្រាប់សម្គាល់ឲ្យដឹងថា ‘‘ទៅជា,,

១-វេជ្ជ > ពេទ្យ, ស្មាតរ > ស្មារ, ទីរ > តៀរ ។

១៨-វិឡារសញ្ញាបើក-បិទ ឬ អញ្ញត្តិៈ (“ ”)

សម្រាប់ដាក់ពីមុខនិងពីក្រោយសំដីអ្នកដទៃដែលគេនាំយកមកសរសេរ ឬ សម្រាប់ដាក់បញ្ជាក់ពាក្យដែលសំខាន់ជាងគេក្នុងប្រយោគ៖

១. មុននឹងចាកចិត្តពីលោកទៅ, ឳពុកខ្ញុំបានផ្តាំថា៖

“ចូរកូនខិតខំប្រកបការងារឲ្យអស់ពីចិត្ត ដ្បិតការងារនេះឯងដែលជាកំណប់ទ្រព្យរបស់អ្នក” ។

១. ខណ្ឌសញ្ញាខាងលើនេះ សម្រាប់សម្គាល់ឲ្យដឹងថា “មកពី” ឬ “ទៅជា” ។

១៩-ឆកសញ្ញា ឬវង់ក្រចក ( ) សម្រាប់ប្រើដាក់ជ្រៀតជ្រែកសេចក្តីពន្យល់បន្ទាប់បន្សំក្នុងប្រយោគ ។

ឯសេចក្តីក្នុងឆកសញ្ញានេះ មិនមានសារៈសំខាន់អ្វីទេ

គេមិនបាច់គានបុល្លប ពាលក៏បាន ឥតមានខូចសេចក្ដីក្នុង
ប្រយោគឡើយ ; ព្រោះហេតុនេះ អ្នកសរសេរគួរប្រយ័ត្ន កុំ
ប្រើនូវសញ្ញានេះក្នុងសេចក្ដីសំខាន់ៗក្នុងប្រយោគ ដូចវិទ្យុរ-
សញ្ញាឲ្យសោះ ។

## ២០ – សហសញ្ញា (-) (trait d'union) ។ណ្វ

សញ្ញានេះ មានសណ្ឋានរូបរាងស្រដៀងគ្នានឹង "យតិភង្គ"
ប៉ុន្តែសញ្ញានេះមិនប្រើក្នុងកាព្យទេ ត្រូវប្រើក្នុងសេចក្ដីរាយ
ចយ៉ាងអ្នកសរសេរពាក្យពហុព្យាង្គមួយម៉ាត់ តែដាក់ក្នុង
បន្ទាត់ជាមួយគ្នាមិនអស់ព្រោះផុតក្រដាសនោះ ត្រូវដាក់
សហសញ្ញាមួយ រួចដកបន្ទាត់មកសរសេរបន្ទាត់ក្រោមទៀត
ក៏បាន ៖

១. ខ្ញុំជាពលរដ្ឋប្រទេសកម្ពុជា ខ្ញុំមានករណីយ-
កិច្ចនឹងបំរើមាតុភូមិខ្ញុំ ។

ពុំនោះសោតសម្រាប់ប្រើត្រង់ពាក្យណាដែលត្រូវផ្ទួនពីរ

ជន ដូចជា៖ ខ្ញុំសុំឲ្យអ្នកបានសេចក្ដីសុខ សេចក្ដីចំរើន ៗ គេអាចសរសេរបានជា៖ ខ្ញុំសុំឲ្យអ្នកបានសេចក្ដីសុខ-ចំរើនៗ

ជួនកាលគេប្រើសហសញ្ញា សម្រាប់ខណ្ឌពាក្យផ្សំគ្នា ហើយដែលជាក់ជិតគ្នា៖

១-មនុស្សម្នាប្រុស-ស្រី ធំ-តូច ជិត ឆ្ងាយ បានមកប្រមូលគ្នាក្នុងវិត្ត ៗ

ក្រៅពីនេះ មានប្រើក្នុងអសាធារណនាមផ្សេងទៀត ដើម្បីបំបែកគោត្រនាមនិងនាមឲ្យឃ្លាតដាច់ពីគ្នា៖

២-លោកអ្នក កញ្ញា សុត្តនប្រីជា-ផន, លោកនូ-គន លោក គៀវ-កើស លោកតូវ-អុំម និងលោកឈឹម-ក្រសេម សុទ្ធតែជាអ្នកព្យាយាមពង្រីកអក្សរសាស្ត្រខ្មែរឲ្យមានរស្មីត្រចះត្រចង់ ៗ

## មេរៀនទី ១២ : - នាម (Nom)

សព្វវត្ថុដែលសព្វសត្វ ជីវិតឲ្យ ឈ្មោះដូចដូចជាមនុស្ស តែលោក ទោះ មានវិញ្ញាណក្ដី ឥតវិញ្ញាណក្ដី មានរូបក្ដី ឥតរូបក្ដី ឲ្យតែ មានឈ្មោះសម្រាប់ហៅបាន ហៅថា «នាម» ទាំងអស់ ។

ឧទាហរណ៍ដូចពាក្យថា៖

មនុស្ស, សត្វ, ដី, ទឹក, ភ្លើង, ខ្យល់, អាកាស, វិញ្ញាណ, ស្មារតី, សីល... ទាំងនេះ ហៅថា «នាម» ពាក្យនេះដែលបង្កើនទៅកន្លែងភាសាគឺ «ឈ្មោះ» ។

## នាមសព្ទ

ស្ទើរសព្វដែលចេញទៅប៉ះត្រូវដល់នាមណាមួយហៅថា «នាមសព្ទ» ។ ឧទាហរណ៍ «សៀវភៅដែលគេសរសេរ» ទឹកដែលគេសរសេរ «សៀវភៅនោះគេហៅថា

“សៀវភៅសរសេរ„ – ទឹកនោះគេហៅថា “ទឹកសរសេរ„ ។
“សៀវភៅសរសេរ„ ទឹកសរសេរនេះហៅថា “នាមនាម„
គ្រប់សូរដែលលាន់ចេញថា “សៀវភៅសរសេរ – ទឹក
សរសេរ„ ទុះហៅថា “នាមសព្ទ„ គឺ “សំឡេងលាន់ចេញ
ចំពោះនាម„ ។

នាមសព្ទមាន ៣ យ៉ាងគឺៈ នាមនាម ១, គុណនាម ១
និងសព្វនាម ១ ។



## មេរៀនទី ១៣:– នាមនាម

នាមដែលជាឈ្មោះនៃអ្វីទាំងឡាយដែលគេសន្មតឈ្មោះទុកសំរាប់ហៅ ទោះមានរូបក្តី ឥតរូបក្តី ដូចជាពាក្យថា "មនុស្ស, សត្វ, ផ្ទះ, វត្ត, ស្រែ, ចំការ, ស្រុក, ភូមិ..." "សីល, ទាន..." ហៅថា "នាមនាម"។

សេចក្តីសង្កេតទី ១.– "នាមសព្ទ" ផ្សេងអំពី "នាម" ដូចមានសេចក្តីតទៅនេះ៖

គ្រប់សម្លេងឬអក្សរ ដែលគេនិយាយឬសសេរចំពោះរបស់មានឈ្មោះ ដូចគេនិយាយឬសសេរថា "សៀវភៅ–ទឹកសសេរ" ជាដើម ហៅថា "នាមសព្ទ"។

គ្រប់អ្វីៗ ទាំងឡាយក្នុងលោកដែលគេសន្មតឈ្មោះទុកសំរាប់ហៅ ហៅថា "នាម" ដូចរបស់សំរាប់មើលឬសំរាប់សសេរ គេសន្មតឈ្មោះហៅថា "សៀវភៅ–ទឹកសសេរ"។

សេចក្ដីសង្កេត ទី ២ – "នាមនាម" ផ្សេងពី "នាមសព្ទ" និ

"នាម" ដូចសេចក្ដីទៅនេះ៖

ពាក្យថា "ខ្មែរ, សៀម, លាវ, ចិន, យួន ...", រួមមកហៅថា "មនុស្ស"; ពាក្យថា "គោ, ក្របី, សេះ, ដំរី, ឆ្កែ, ឆ្មា ...", រួមមកហៅថា "សត្វ"; ពាក្យថា "ផ្ចឹក, សុក្រម, ស្រឡៅ, នាងនួន, ត្រញែង, ឈើទាល ...", រួមមកហៅថា "ឈើ"; ពាក្យថា "តុ, កៅអី, ទូ, ជើងម៉ា, បន្ទាត់, ខ្មៅដៃ ...", រួមមកហៅថា "វត្ថុ" ។

បណ្ដាពាក្យទាំងនេះ ពាក្យថា "ខ្មែរ, សៀម, លាវ, ចិន, យួន; គោ, ក្របី, សេះ, ដំរី, ឆ្កែ, ឆ្មា, ផ្ចឹក, សុក្រម, ស្រឡៅ, នាងនួន, ឈើទាល, ត្រញែង; តុ, ទូ, កៅអី, ជើងម៉ា, បន្ទាត់, ខ្មៅដៃ, រួមទាំងអស់មក ហៅថា "នាមនាម" ព្រោះជានាមពិតរបស់ មនុស្ស, សត្វ, ឈើ, វត្ថុ ។ ចំណែកពាក្យថា "មនុស្ស

សត្វ, ឈើ, វត្ថុ ‘‘ហៅថា,, ‘‘នាម,, ព្រោះជាឈ្មោះរបស់ ៗ ឯសម្ដីឬពាក្យដែលនិយាយឬសរសេរចំពោះ ‘‘នាមនាម,, នោះ ហៅថា ‘‘នាមសព្ទ,, ។

‘‘នាមនាម,, ប្រែថា ‘‘ឈ្មោះរបស់នាម ,, មានពីរយ៉ាងគឺៈ សាធារណនាម ១ និងអសាធារណនាម ១



## មេរៀនទី១៤:-សាធារណនាម (Nom commun)

សាធារណនាម គឺនាមគ្រាន់តែសំដែងឈ្មោះដែលជាសាធារណៈទូទៅទៀតបាន៖ រដ្ឋ, ក្រុង, វិថី, ខេត្ត, ស្រុក...ជាដើមនេះ មិនអាចទឹងដឹងប្រាកដថា ក្រុងណា រដ្ឋណា, វិថីណា, ខេត្តណា..បានទេ ។

សាធារណនាមមាន៤យ៉ាងគឺ៖

១- បកតិនាមឬនាមធម្មតា,

២- កិតនាម ឬ នាមក្រិត (Nom dérivé),

៣- សមាសនាម (Nom composé),

៤- កត្តនាម ឬការកនាម (Nom d'agent).

១–បកតិនាម : គឺជានាមដែលកើតឡើងជាធម្មតា ដែលពុំចេញមកពីពាក្យឯណាឡើយ ដូចជាពាក្យ៖ ទន្លេ, មនុស្ស,

សត្វ, ភ្នំ, ដី, ទឹក, ភ្លើង, ខ្យល់ ... ។ល។

២- កិតនាមឬនាមក្រិត : គឺនាមឯណាដែលមានកំណើតចេញពីនាមដើម ឬ គុណនាម ឬ កិរិយាសព្ទ ដូចពាក្យ:

ចំណាស់ < ចាស់, ទំហំ < ធំ, សំដើង < ស្ដើង, គម្រាស់ < គ្រាស់. .ចេញមកពីគុណនាម ។

ចំណង់ < ចង់, ដំណឹង < ដឹង, តំអូញ < ត្អូញ, សំណោក < សោក ... ចេញមកពីកិរិយាសព្ទ ។

ឈ្មួញ < ជំនួញ, ... ចេញមកពីនាម ។

(កុំប្រើពាក្យថា "សេចក្ដី" ផ្សំផងឡើយ) ។

តែបើតាមសង្កេត នាមក្រិតចេញមកពីកិរិយាមានច្រើនជាងនាមក្រិតចេញមកពីនាមឬគុណនាម ប៉ុន្តែតែងប្រែក្លាយទៅជា "ការណនាម" (Nom d'action) គឺឈ្មោះអំ-ពើដែលគេត្រូវធ្វើ មិនអាចក្លាយទៅជា "ការកនាមឬតទ្ធិតនាម" (Nom d'agent) គឺឈ្មោះអ្នកធ្វើនូវអំពើនោះបានឡើយ ។

៣- សមាសនាម ( Nom composé ): សមាសនាមគឺជា នាមដែលកើតឡើងអំពីដំណំនៃពាក្យ ពីរម៉ាត់ភ្ជាប់គ្នាក៏មាន, នៃពាក្យច្រើនម៉ាត់ភ្ជាប់គ្នាក៏មាន ជួនកាលកើតឡើងដោយ នាមនឹងនាម, ដោយគុណនាមនឹងគុណនាម, ដោយ កិរិយានឹងកិរិយាក៏មាន, ជួនកាលកើតឡើងដោយនាមនឹង គុណនាម, ដោយនាមនឹងកិរិយាក៏មាន ។

ឧទាហរណ៍ :

ន+ន: ផ្ទះឈើ, ពាងទឹក, ស្រុកស្រែ, ផ្ទះថ្ម.. ។

គុ+គុ: តូចស្ដើង, ធំធាត់, សុភាពរាបសា ... ។

កិ+កិ: ឈ្លោះប្រកែក, តឹងតែង, ប្រមាញ់ប្រមង ... ។

ន+គុ: ទឹកខ្មៅ, ផ្ទះធំ, មនុស្សល្អ, បន្ទាត់ត្រង់ ... ។

ន+កិ: សៀវភៅសរសេរ, កាំបិតកោរ ... ។

ក) សមាសនាមខ្មែរ ច្រើនកើតតែពីនាមនឹងនាម, នាម នឹងគុណនាម, នាមនឹងកិរិយា ឬពាក្យច្រើនម៉ាត់ភ្ជាប់គ្នា ។

១) ត្រង់គុណនាមនិងគុណនាមឬកិរិយានិងកិរិយាពាក្យខ្មែរសុទ្ធដូចជាពុំសូវឃើញមានសោះ ។

គ)នាមនិងគុណនាមភ្ជាប់គ្នា បើប្រើជាសមាសមកបាន, ប្រើជាបច្ច័យក៏បាន ។ យើងអាចនឹងប្រទះឃើញរបៀបប្រើសមាសនាមនេះកើតមានច្រើនដែលមានបំណងជាឧទាហរណ៍ដូចជា " មុខងារនៃគុណនាម " ។

ឃ)ខ្មែរយើងយកសមាសនាម បាលីឬសំស្ក្រឹត មកប្រើជាច្រើន ។ ដើម្បីឲ្យដឹងថាពាក្យនេះជាសមាសនាមយើងគោរពរបៀបទ្រឹស្តីទៀត ៖

១. សិស្ស+អនុសិស្ស=សិស្សានុសិស្ស,
ជន+អភិបាល=ជនាភិបាល,
ទេវ+អនុគ្រោះ=ទេវានុគ្រោះ... ។

៤– កិរិយានាមឬការកនាម (Nom d'action) គឺជានាមដែលគេយកកិរិយា ឬ គុណនាម មកប្រើជានាមដូចពាក្យថា ៖

ក្រៅពីសាធារណនាម ៤ យ៉ាងខាងលើនេះ យើងមានៈ

សមូហនាម– (Nom collectif) នាមសព្ទដែលសំដែងអំពីការ

រ្វូប, រ្វូម, ការប្រមូលមនុស្ស, សត្វ, វត្ថុរបស់ដូចជា

ក្រុម, ហ្វូង, កង, ពួក ៗ ។ ប្រជុំជន, បណ្ដាជន ,

មហាជន, មនុស្សនិករ, ខ្មែរជាតិ, តិណជាតិ. . ៗ

រូបីនាម (Nom concret) នាមដែលជាឈ្មោះសត្វ, មនុស្ស

វត្ថុដែលមានរូបរាងទ្រង់ទ្រាយពិតប្រាកដ, ឃើញច្បាស់

នឹងចក្ខុបសាទ, ពាល់មានសម្ផស្សដឹង, ខន, តគ្រាត,

ជាដើម, ដូចជា មន្ត្រី, គ្រូ, ជាង, កម្មករ, សេះ,

ដើមឈើ, ឈើគូស ខ្ញុំហៅរូបនាមក៏បាន ៗ

អរូបីនាម (Nom abstait) ដែលឲ្យឈ្មោះចំពោះគុណ-

សម្បត្តិ ៗ កិច្ចដែលធ្វើ, លំនាំដែលធ្វើ ដូចជាៈ

សប្បុរសធម៌, ប្រាជ្ញា, ស្មារតី, មេត្រីភាព, មិត្តភាព...ៗ

អរូបីនាម នាមដែលចិត្តបញ្ចេញមានសភាព ,

លក្ខណៈផ្សេងៗ ហៅថាអរូបក៏បាន ។

អ្នកដើរ , អ្នករែក , អ្នកធំ , អ្នកតូច , អ្នកប្រសប់ អ្នកទំនុកបំរុង ... ។

<u>សេចក្ដីសង្កេត</u> : បើសង្កេតមិនបានម៉ត់ចត់ គេអាចថា "តទ្ធិតនាម" ដូចគ្នាឬប្រហែលគ្នា នឹងសមាសនាម "គឺត្រង់នាមភ្ជាប់នឹងគុណនាម ឬត្រង់នាមភ្ជាប់នឹងកិរិយា ។

យើងយកនាម "ទឹកខ្មៅ" ១ មកពិនិត្យទៅតាមន័យនៃព្យាង្គមួយៗ យើងអាចសំគាល់បានថា "តទ្ធិតនាម ខុសគ្នាពី " សមាសនាម ,, មែន ។

ពាក្យ "ទឹកខ្មៅ ,, មានន័យថាទឹក ១ យ៉ាងកើតឡើងដោយយកល័ក្តទៅលាយនឹងទឹក ហើយមានពណ៌ផ្សេងៗ សំរាប់សរសេរ ។ ពាក្យ " ទឹកខ្មៅ ,, នេះ កើតឡើងដោយផ្សំនាម " ទឹក ,, នឹងគុណនាម " ខ្មៅ ,, កាលបើពាក្យកើតឡើងហើយ គេពុំអាចបំបែកពាក្យនេះជាពីរព្យាង្គវិញបានទេ ហើយពាក្យនេះ ប្រើសម្រាប់សំគាល់វត្ថុផ្សេង

ពីរតួដើម (ពាក្យទាំងឡាយរបៀបនេះ ហៅជាតទ្ធិតនាម) ។

បើយើងយកពាក្យ “ ទឹកខ្មៅ ,, ដដែលមកបំបែកឲ្យទៅ
ជាពីរព្យាង្គទៅវិញ ; នាម “ ទឹក „ មានន័យជាទឹកដដែល ,
គុណនាម “ ខ្មៅ „ នៅមានន័យជាខ្មៅដដែល គឺថាទឹកនោះ
មានពណ៌ខ្មៅ ។ ដូចនេះពាក្យ “ ទឹកខ្មៅ „ ខាងក្រោម
នេះជាសមាសនាម ។



## មេរៀនទី១៨:- អសាធារណនាម (Nom Propre)

នាមដែលសំដែងឈ្មោះប្រាកដ មិនជាសាធារណៈ ដែលឲ្យទៅទៀតបាន គឺជានាមសំរាប់សំគាល់តែមនុស្សម្នាក់, សត្វមួយ, វត្ថុមួយតែប៉ុណ្ណោះ៖

ឧទាហរណ៍ ៖

ឈ្មោះមនុស្ស; ទូ-គន: យុត្តិវង្ស, ពូរ៉ា គីម ... ។

ឈ្មោះសត្វ: ករពាល, ករខ្យ, ករចំរើន ... ។

ឈ្មោះវត្ថុ; កំពេញ, កម្ពុជាវង្ស, ថៃខ្សែធំ ... ។

ហៅនាមនេះជាដើមហៅថា «អសាធារណនាម» ។

## មេរៀនទី១៦.– លិង្គរបស់នាម (Genre)

នាមទាំងឡាយមានភេទផ្សេងៗគ្នា ។ ភេទជាគ្រឿងសម្រាប់សំគាល់នាម ដែលប្រព្រឹត្តទៅដោយអាការៈផ្សេងៗគ្នា ហៅថា «លិង្គ» ។

លិង្គមាន ៣ យ៉ាងគឺៈ បុំលិង្គ (អានថាប៉ុងលិង), ឥត្ថីលិង្គ និងនបុំសកលិង្គ, ពប់យកអលិង្គ ដែលមិនប្រាកដជាភេទអ្វីមកផ្សំផង ជា ៤ យ៉ាង ។

– បុំលិង្គ គឺភេទសម្រាប់មនុស្សប្រុស, សត្វឬវត្ថុឈ្មោល ដូចជាពាក្យថា កូនប្រុស, ក្មេងកម្លោះ, គោឈ្មោល, ក្របីស្ទាវ ... ជាដើម ។

–ឥត្ថីលិង្គ គឺភេទសម្រាប់មនុស្សស្រី, សត្វឬវត្ថុញី

ដូចជាពាក្យថា៖ កូនស្រី, ក្មេងស្រី, កូនក្រមុំ ( កូនពេញក្រមុំ ), គោញី, មាន់ញី, ស្វាញី, ... ជាដើម ។

- ឯបុំសកាលិង្គ ជាភេទសំគាល់មនុស្ស, សត្វប្រុសក្តី ញីក្តី មិនថាគ្រប់អាយុ ...

ទើយ គឺភេទមិនមែនជាប្រុសឬជាស្រី ជាឈ្មោលឬជាញី ។

- អលិង្គបានដល់ភេទដែលមិនមានគ្រឿងសំគាល់សត្វ

ឥត្ថីភេទ គឺសត្វដែលមិនមែនជាភេទប្រុស, ភេទស្រីឬភេទ

ទើយឡើយ បានដលពាក្យជាទិបាតសត្វទាំងឥសដូចជា៖

ជង, ក្តី, ដែរ, ទោះ, ទោះបី, ទោះយោបី, កំដោយ, បើ...

ជាដើមនេះ ជាអលិង្គ, នឹងពាក្យថា «ក្មេង, កូន, ប្អូន, បង,

ចៅ, គោ, ក្របី, សេះ, ដំរី, ក្អែ, ឆ្មា, ជ្រូក, មាន់, ទា,

ពពែ.. ជាដើម កំជាអលិង្គដែរ ព្រោះមិនទាន់ត្រូវគដជា

ភេទគ្នីនៅឡើយ ទាល់តែថែមពាក្យថា "ប្រុសឬឈ្មោល"

នឹង «ស្រីឬញី» ទៅលើពាក្យទាំងនោះទៀតទើបដឹងច្បាស់

ថាជា «បុំលិង្គ» នឹង «ឥត្ថីលិង្គ» បាន ។

តាមដោយបញ្ញត្តិនៃក្បួនហោរាថា "នាមរបស់មនុស្ស
ប្រុស នឹងនាររបស់ស្រ្តីគឺជា "បុំលិង្គ",, នាមរបស់មនុស្ស
ស្រីឬនាមរបស់ស្រុក, ភូមិ, ខេត្ត, នគរ, វត្ត សុទ្ធជា
ឥត្ថីលិង្គ ឯក្នុងល្បែងខ្លះ វត្ថុដែលជាគ្រឿងលេងដូចយ៉ាង
អង្គញ់, ចាយទុំ, ចាយខ្សែកចាយខ្សែ, ចត្រង្គ... ជា "ឥត្ថី-
លិង្គ,, ដែរ ។

លិង្គសម្រាប់ប្រើជាពាក្យប្រុសស្រី ដូចពាក្យថា៖ ឪ,
តា, ពូ, មា, បិតា, អយ្យកោ, បិតុលា, កុមារ, យក្ខ, ចោរ,
ភិក្ខុ, សាមណេរ, ពានរ, ព្រាហ្មណ៍, បេក្ខជន, បណ្ណាធិ-
ការ... ជាពាក្យសំរាប់បុំលិង្គ, ឯពាក្យថា៖ យាយ,
ម៉ែ, ម្ដាយ, មីង, អយ្យិកា, មាតុលា, កុមារី, យក្ខិនី,
ចោរី, ភិក្ខុនី, សាមណេរី, ពានរី, ព្រាហ្មណី, បេក្ខជននី,
បណ្ណាធិការិនី, ... ជាពាក្យសម្រាប់ឥត្ថីលិង្គ ។

លិង្គទាំងពីរ-បួនយ៉ាងនេះ កាលបើកំណត់ដោយកំណើត

ទង់ដោយសន្មត មានឈ្មោះថែកចេញទៅជាពីរយ៉ាង គឺ៖

ជាតិលិង្គ១, សម្មតិលិង្គ១ ។

ក) ជាតិលិង្គ: គឺលិង្គកំណត់ដោយភេទប្រុស ឬ ភេទស្រី

ឬមិនមែនភេទប្រុស ស្រីតាមកំណើត តាមភេទពិត៖ ប្ដី,

ត្នោឈ្មោល, ក្របីឈ្មោល... ពាក្យទាំងនេះមានភេទជាមនុស្ស

ប្រុស សត្វឈ្មោល; ប្រពន្ធ, ក្ដៃញី, ក្របីញី ... ពាក្យ

ទាំងនេះមានកំណើតជាភេទមនុស្សស្រី, សត្វញី; សំពត់,

ទេះ, ក្ដារ, ដី, ទឹក, ភ្លើង... ពាក្យទាំងនេះមានកំណើត

ហើយមានភេទមិនមែនជាប្រុស ឬជាស្រីឡើយ ដូចនេះក៏ជា

« ជាតិលិង្គ » ដែរ ។

ខ – សម្មតិលិង្គ: គឺជាលិង្គដែលកំណត់ដោយសន្មតិ

សទំនងអំពីកំណើតអំពីភេទ មិនមែនប្រុស មិនមែនស្រី

រណកស់នៅជា នបុំសកលិង្គ តែលោកសន្មត ជាឥត្ថីលិង្គ

ញ ។ សម្មតលិង្គ ហៅថា «អលិង្គ» វិញក៏បាន ។

## មេរៀនទី១៧:– វិចនៈរបស់នាម (Nombre du nom)

ពាក្យសម្រាប់ញែកចំនួននៃសត្វមួយ ៗ ឲ្យដឹងថាតិច ឬច្រើនប៉ុណ្ណោះ ហៅថា វចនៈ មាន២យ៉ាងគឺ ឯកវចនៈ និងពហុវចនៈ ។

### ឯកវិចនៈ (Singulier) :

ពាក្យដែលជាដំណាងមនុស្សតែម្នាក់ឬតែមួយ ហៅថា « ឯកវចនៈ » ។

### ពហុវិចនៈ (Pluriel) :

ពាក្យដែលជាដំណាងមនុស្សច្រើនគ្នា ឬ របស់ច្រើនតាំងពី ២ ឡើងទៅ ហៅថា “ពហុវចនៈ” ។

ក្នុងភាសាខ្មែរ វចនៈទាំងពីរយ៉ាងនេះ មិនជាការសំខាន់ប៉ុន្មានឡើយ ។

តាមការសង្កេត, កាលណានាមមានរៀនភ្ជាប់ពីខាង

ដើមឬពីខាងចុងដោយសំខ្យាស័ព្ទមួយ នាមនោះជាឯកវចនៈ; បើកាលណាជាពហុវចនៈវិញ គេថែមសំខ្យាស័ព្ទពីរ, បី, បួន ... ឬផ្សេងពាក្យទៀត ដូចពាក្យថា, ឆ្កែពីរ, គោបី, ប្រុសៗ, ស្រីៗ, ក្មេងៗ, ចាស់ៗ, ក្មេងទាំងឡាយ, កូនទាំងឡាយ, នាងទាំងឡាយ, ឈើទាំងឡាយ, អស់ទាំងសត្វ, អស់លោក, អស់អ្នក, អស់នាង, យើងទាំងអស់គ្នា, ពួកយើង...ជាដើម ។ មានពាក្យខ្លះចេញពីសំស្ក្រឹតឬបាលី មានរូបៈរេសក់សំគាល់វចនៈខ្លះដែរ ដូចពាក្យថា៖ កុមារ (ឯក.), កុមារា (ពហុ.); រុក្ខ (ឯក.) រុក្ខា (ពហុ.); យក្ស(ឯក.), យក្សា (ពហុ.); ព្រឹក្ស (ឯក.), ព្រឹក្សា (ពហុ.); មនុស្ស (ឯក.) មនុស្សា (ពហុ.)...ដូច្នេះជាដើម ។



# សម្ពន្ធ និង មុខងាររបស់នាម

## (AnalYse et fonction du nom)

*ចំណាត់បទ ឬ ចំណាត់ប្រយោគ គឺការចាប់បទកន្សោមៗ មួយៗ ឬ ក្នុងប្រយោគមួយៗ ឲ្យដឹងថាបទណាចូលទៅរកបទណា, បទណាដែលជាប្រធាន, ជាកិរិយា, ជាអំពើ, តាមលំនាំវេយ្យាករណ៍ ហៅថា "សម្ពន្ធ" ។*

*១. ខ្ញុំទៅធ្វើការឯក្រសួងសាធារណការ ។*

*ខ្ញុំ*: ឧត្តមបុរិសសព្វនាម ឯកវចនៈ ជាប្រធានរបស់កិរិយា "*ទៅ*"

*ទៅ*: សកម្មកិរិយា បច្ចុប្បន្នកាល ឯកវចនៈ ដែលមានប្រធាន "*ខ្ញុំ*"

*ធ្វើ*: ជាកិរិយាប្រាប់បំណង របស់ ទៅ (ទៅដើម្បីធ្វើ)

**ការ**: ជាអំពើរបស់ *ធ្វើ*

ឯ: ជាអាយតនិបាតប្រាប់ទី

***ក្រសួងសាធារណការ***: សាធារណនាម ឥត្ថីលិង្គ ឯកវចនៈ

កម្មរងអំពើ ប្រាប់ទីកន្លែង «ទៅ»

បែបយ៉ាងនេះហៅថា «សម្ពន្ធ» ។

ញ្ញ សម្ពន្ធនាមសព្ទៈ គឺយកនាមនីមួយៗក្នុងឃ្លា ក្នុងប្រ-
យោគ មកថ្លែងជាចំណែកឯង ហើយសំដែង ជាតិ - លិង្គ,
វចនៈ... ។

ន . - ដើម្បីបកសម្ពន្ធ «នាមសព្ទ» ត្រូវមើល ៖

ទី១) ជាតិរបស់នាម តើនាមនោះជា សាធារណៈ ឬ ជាអសាធារណៈ

ទី២) ចំនួន គឺលិង្គ និងវចនៈ

ទី៣) ប្រព្រឹត្តិការណ៍ គឺតើជាប្រធាន, ជាកម្មរងអំពើ, ជាអកម្មរងអំពើ ឬជាកម្មបំពេញបទ ។

ន - ប្រធាន.- នាមឯណាដែលធ្វើអំពើទៅលើកិរិយាសព្ទ នាមនោះជាប្រធានរបស់កិរិយា ៖

ឧ - ស្ត្រីដងទឹក ។ អ្នកណាដងទឹក? គឺ - ស្ត្រី - ស្ត្រី

ជនទឹក ; ស្រីធ្វើអំពើជន - ដូច្នេះស្រីជាប្រធាន នៃកិរិយា «ជន» ។

១ - កម្មរងអំពើ - នាមឯណាដែលទទួល នូវអំពើពីកិរិយា នាមនោះជា កម្មរងអំពើ របស់កិរិយា ។

ឧ. ស្រីជនទឹកទន្លេនៅថ្ងៃរសៀល ។

- ស្រីជនអ្វី? - ស្រីជនទឹក ទឹករងអំពើនៃកិរិយា ជន ; ដូច្នេះ «ទឹក» ជា <u>កម្មរងអំពើ</u> នៃកិរិយា «ជន» ។

ក - អកម្មរងអំពើ. - នាមឯណាដែលពុំទទួល ពុំរងអំពើ ចំពោះ ឬផ្ទាល់ពីកិរិយា នាមនោះជាអកម្មរងអំពើ ចំពោះកិរិយា ។

ឧ - ស្រីជនទឹកទន្លេនៅថ្ងៃរសៀល ។

ថ្ងៃរសៀល ពុំមែនរងអំពើនៃកិរិយា «ជន» ទេ បើជាទៀតទៅ «អកម្ម» របស់កិរិយាជន ។ «<u>អកម្មរងអំពើ</u>» ពាក្យនេះពុំសូវបានសេចក្ដីច្បាស់លាស់

ទេ ។ ដូច្នេះដើម្បីឲ្យបានសេចក្ដីច្បាស់ប្រាកដ អកម្មក្រិយាមិនបែកចេញទៅជាផ្សេងទៀត ( សូមមើលទៅមេរៀនខាងមុខ ដែលមានចំណងជើងថា « កម្ម » )។ ដើម្បីឲ្យដឹងថា អកម្មក្រិយាណាជាអកម្មប្រាប់គុ ណនោះ សូមឲ្យសង្កេតមើលនិបាតសព្ទ ដែលនៅពីខាងដើម អកម្មក្រិយានោះ ( សូមមើលមេរៀន « និបាតសព្ទ » ) ។

ឃ–កម្មបំពេញបទ.–នាមឯណាដែលញ៉ាំងន័យរបស់នាម ១ ទៀតឲ្យបានពេញលេញឡើង នាមនោះជាកម្មបំពេញបទរបស់នាម ១ ទៀត ។

• ស្ដ្រីដងទឹកទន្លេនៅថ្ងៃរសៀល ។

ស្ដ្រីដងទឹកអ្វី? – ស្ដ្រីដងទឹកទន្លេ ; – ទន្លេធ្វើន័យរបស់ទឹកឲ្យបានប្រាកដឡើង ; ដូចនេះ « ទន្លេ » ជាកម្មបំពេញបទរបស់នាមទឹក ។

ឧទាហរណ៍នៃសម្ពន្ធរបស់នាមក្នុងប្រយោគ ៖

– ស្ត្រី ។ ដងទឹកទន្លេនៅថ្ងៃរសៀល ។

ស្ត្រី ។ : { បគតិនាម (១)
សាធារណនាម ឥតលិង្គ ពហុវចនៈ ប្រធានរបស់កិរិយាដង ;

ទឹក: { បគតិនាម (២)
សាធារណនាម នបុំសកលិង្គ ឯកវចនៈ កម្មវត្ថុផ្ទាល់របស់កិរិយាដង ;

ទន្លេ: { បគតិនាម (៣)
សាធារណនាម នបុំ . ឯក . កម្មបំពេញបទរបស់នាមទឹក ;

ថ្ងៃរសៀល: { សមាសនាម (៤)
សាធារណនាម , នបុំ. ឯក. អកម្មប្រាប់ពេលរបស់កិរិយាដង ។

(១)-(២)-(៣)-(៤) ៖ បើយើងពុំដឹងច្បាស់ យើងគ្រាន់តែដាក់ថា សាធារណនាម ក៏បានដែរ ក៏ប៉ុន្តែដើម្បីធ្វើឲ្យឯកឡៃនៃសម្គាល់យើងនោះ កាន់តែវិសេសឡើង ហើយឲ្យដាក់ប្រាកដក្នុងវេយ្យាករណ៍ យើងត្រូវដាក់ថា បកតិនាម ឬ សមាសនាម ឬ ជាតទ្ធិតនាមផង ។

## មេរៀនទី១៩ - គុណនាម (Adjectif)

ពាក្យដែលសំដែងប្រកាសនូវលក្ខណៈរបស់នាមនាម ឬធ្វើនាមនាមឲ្យមានបទ សម្រាប់សំគាល់ឲ្យដឹងថា នាមនាមនោះល្អ ឬ អាក្រក់, ធំ ឬ តូច, ខ្ពស់ ឬ ទាប, ដូចពាក្យថា ៖

ល្អ, អាក្រក់, ធំ, តូច, ខ្ពស់, ទាប, ស, ខ្មៅ, វែង, ខ្លី, . . . ជាដើម គឺសំដៅយកសណ្ឋានទ្រង់ទ្រាយនិងអាការៈលើសឡើង ឬ ថយចុះរបស់នាមនាម ហៅថា « គុណនាម » ។

គុណនាម មានប្រយោជន៍ជាគ្រឿងប្រកាសលក្ខណៈរបស់ "នាមនាម" ឲ្យជាទីចូលចិត្តបានងាយ គឺជាគ្រឿង

ជួយធ្វើនាមនាមឲ្យបញ្ជាក់ប្រាកដថាមានលក្ខណៈបែបនេះ ឬ បែបនោះ ។

គុណនាមមាន ៣ យ៉ាងគឺ៖ បកតិគុណនាម វិសេសគុណនាម និង អតិវិសេសគុណនាម ។

**បកតិគុណនាម (Adjectif qualificatif)** - គុណនាម ដែលសម្តែងលក្ខណៈរបស់នាមនាម តាមលំនាំធម្មតាប្រក្រតី មិនទាន់វិសេសឡើយ គឺគុណនាមគ្រាន់តែសម្តែង ឲ្យដឹងលក្ខណៈស្មោះតាមធម្មតាប៉ុណ្ណោះ ដូចពាក្យថា ៖ ផ្ទះតូច, សាលាធំ, បន្ទាត់វែង, សៀវភៅក្រាស ... ជាដើម ហៅថា "បកតិគុណនាម" ។

**វិសេសគុណនាម** - គុណនាមដែលសម្តែងលក្ខណៈ នាមនាមឲ្យវិសេសឡើងជាងប្រក្រតីតែមិនសម្តែងលក្ខណៈខ្ព ថាណាស់ ឬថយថោកណាស់នោះទេ គ្រាន់តែសម្តែងឲ្យដឹង ថាវិសេសជាងធម្មតាប៉ុណ្ណោះ៖ ដូចពាក្យថា៖ ផ្លូវត្រង់ជាង

ឈើខ្ពស់ថ្លូក, សាច់សល្អ... ជាដើម ហៅថា "វិសេសគុណនាម"។

សេចក្ដីសង្កេត. - វិសេសគុណនាមប្លែកពីបកតិគុណនាម ដោយបកតិគុណនាមមានពាក្យថា៖ ខ្មៅ, វែង, ស្លូត, ត្រង់... ជាដើមតែប៉ុណ្ណោះ; ឯវិសេសគុណនាម មានពាក្យថា៖ "ជាង, ល្អ, គ្រាន់, វិសេស, ប្លែក...", ភ្ជាប់ពីខាងចុងគុណនាមដែលជាបកតិគុណនាមនោះផង។

ឧ. ខ្មៅជាង, សល្អ, ល្អគ្រាន់..។

អតិវិសេសគុណនាម (Adjectif de superlatif) - គុណនាមដែលសម្ដែងលក្ខណៈឲ្យវិសេស ឬប្លែកបំផុត ដូចពាក្យថា៖ ល្អបណ្ដាច់, ពេកណាស់, ពន់ពេក, ក្រៃលែង, វិសេសណាស់, ត្រកាលណាស់, សក្បុស, សស្គុស, ខ្មៅយង់,.. ជាដើម ហៅថា៖ "អតិវិសេសគុណនាម"

ចំណាំ.-អតិវិសេសគុណនាម មិនមែនគួរក្រៅពីបកតិ-

គុណនាមថែមពាក្យ «ណាស់, បំផុត, ក្រស, ស្គុស, បណ្ដាច់, ចំបង... ឥតចុះឡើង ។

## មេរៀនទី២០.– លិង្គនិងវចនៈរបស់គុណនាម
## Genre et nomrbe de l'abjectif

គ្មានត្រូវជាទីសំគាល់ឲ្យដឹងថា គុណនាមនេះជាបុំលិង្គ, ឥត្ថីលិង្គ, នបុំសកលិង្គ, ឬឯកវចនៈ, ពហុវចនៈ បានឡើយ ។ ដោយហេតុថា គុណនាមត្រូវតែភ្ជាប់ទៅនឹងនាម ហើយសម្ដែងលក្ខណៈរបស់នាមនោះ រូបគុណនាមមានលិង្គនឹងវចនៈ ដូចគ្នានឹងនាមនោះដែរ គឺថា ៖ បើនាមនោះជាបុំលិង្គ, ឥត្ថីលិង្គ, នបុំសកលិង្គ ឬជាឯកវចនៈ, ពហុវចនៈ គុណនាមក៏មានលិង្គនឹងវចនៈ ដូចនាមនោះដែរ ។

ចំណែកអក្ខរាវិរុទ្ធ របស់គុណនាមវិញនៅដដែល ឥតមានផ្លាស់ប្ដូរទៅតាមលិង្គឬវចនៈឡើយ ។

# មេរៀនទី២១:-សម្ពន្ធនិងមុខងាររបស់គុណនាម

**( AnalYse et Fonction de l'Adjectif )**

## មុខងាររបស់គុណនាម (Fonction de l'Adjectif).-

*គុណនាមដែលសំដែងលក្ខណៈរបស់នាម មានមុខងារជាគុណបទរបស់នាមដែលប្រាស្រ័យជាមួយ ។*

វិធាន.- *ដើម្បីនឹងធ្វើសម្ពន្ធគុណនាម ត្រូវមើល ជាតិ តើជាគុណនាមបែបណា ? (ជាបកតិគុណនាមឬវិសេសគុណនាមឬជាអតិវិសេសគុណនាម) លិង្គ (បុ ឬ.ឥ ឬ.នបុ.) វចនៈ (ឯក ឬពហុ ) និងប្រព្រឹត្តិការណ៍ (មុខងារ) (គុណបទរបស់នាមណា ? )*

*១. នាយយូរិនមានខោកញ្ចាស*

*កញ្ចាស = ជាបកតិគុ. ឯក. គុណបទរបស់ខោ ។*

## មេរៀនទី២២:– សំខ្យាសព្ទ (Nombre)

សព្ទសម្រាប់រាប់នាមហៅថា " សំខ្យាសព្ទ ,, ។

សំខ្យាសព្ទមានពីរយ៉ាងគឺ៖ បកតិសំខ្យា ១ និងបូរណសំខ្យា ១ ។

### ក – បកតិសំខ្យា – (Nombres cardinaux)

អត្ថន័យ – សំខ្យាដែលរាប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមនាមថា ប៉ុណ្ណេះ, ប៉ុណ្ណោះ ដូចរាប់ថា " មួយ, ពីរ, បី, បួន, ប្រាំ " ជាដើមហៅថា " បកតិសំខ្យា ,, ។

បកតិសំខ្យាមានពីរពួក គឺសំខ្យាសព្ទនាម ១ និងសំខ្យាគុណនាម ១ ៖

១ – សំខ្យាសព្ទនាមមានបួនគឺ៖, មួយ, ពីរ, បី, និងបួន ។

២ – សំខ្យាដែលរាប់តាំងពីប្រាំតទៅសុទ្ធជា " សំខ្យាគុណនាម ,, តាំងអស់ដូចជា៖ ៦, ៧, ៨, ៩, ១០, ២០, ៣០, ... ៩០, ៩០០០ .. ។

វិធីរាប់បកតិសំខ្យា –វិធីរាប់បកតិសំខ្យា ខ្មែរចែកចេញជាបួនផ្នែក ព្រោះមានសេចក្ដីប្លែកគ្នាខ្លះ ដូចអធិប្បាយតទៅនេះ៖

## ១–វិធីរាប់ពីមួយដល់ដប់

ការរាប់ពីមួយដល់ដប់ចែកចេញជាពីរពួកទៀតគឺ៖ ពួកបកតិសំខ្យាសុទ្ធ មានដំណើរប្រាប់ចំនួនជាដាច់ខាតដោយឡែកពល់ ៗ សុទ្ធគឺ មួយ, ពីរ, បី, បួន, ប្រាំ នឹងពួកបកតិសំខ្យា-សុទ្ធមានដំណើរប្រាប់ចំនួនផ្សំជាមួយនឹងប្រាំគឺ៖

ប្រាំនឹងមួយ ជា ប្រាំមួយ
ប្រាំ – ពីរ – ប្រាំពីរ
ប្រាំ – បី – ប្រាំបី
ប្រាំ – បួន – ប្រាំបួន

តពីប្រាំបួនទៅគឺ «ដប់» ដែលជាចំនួនដាច់ខាតទៀត ។

## ២–វិធីរាប់ពី «១១» ដល់ «១០០»

តពីចំនួនដប់ឡើងទៅត្រូវបន្ថែមចំនួនរាយពី ១ ដល់៩ ទៀតគឺ៖

ដប់ទីមួយ ជា ដប់មួយ

ដប់ — — ដប់ពីរ

........................

ដប់ទីប្រាំបួន - ដប់ប្រាំបួន ។

ផុតពីដប់ប្រាំបួនទៅ គឺដប់ពីរដង=ម្ភៃ តពីម្ភៃនេះទៀត ត្រូវផ្សំនឹងចំនួនកាយដដែល គឺម្ភៃមួយ..ម្ភៃប្រាំពីរ...

ដប់បីដង គឺ សាមសិប

..............................

ដប់៤ដង – សែសិប

..... ......................

ដប់១០ដង – មួយរយ

## ៣–វិធីរាប់ពី«រយ»ដល់«កោដិ»–

តាំងពីរយរៀងទៅដល់កោដិ បកតិសំខ្យាមានសព្ទជាចំនួនជាបវាគុណះដល់ចំនួននោះត្រូវធំជាងចំនួនមុនៗ១០ដងៗ

កតិសំខ្យាមានដំណើរប្រាប់ចំនួនជាដាច់ខាតទាំងនោះគឺ ៖

| | |
|---|---|
| រយ = ១០០ | សែន = ១០០.០០០ |
| ពាន់ = ១.០០០ | លាន = ១.០០០.០០០ |
| ម៉ឺន = ១០.០០០ | កោដិ = ១០.០០០.០០០ |

ចន្លោះពីរយទៅពាន់, ពីពាន់ទៅម៉ឺន... ត្រូវយកចំនួនពី១ ល់៩៩ មកថែមក្រោយពាក្យមុន បានទៅជា មួយរយ យ(១០១)... មួយរយហាសិប(១៥០) .. មួយរយកៅសិប ប្រាំបួន(១៩៩)... ៣ម៉ឺន, ២សែន៣ពាន់... ។ល។ ... ។

-វិធីរាប់ពី‹‹បកោដិ,, ដល់‹‹អសំខេយ្យ,,.-

បកតិសំខ្យាប្រាប់ដំណើរ ជាចំនួនដាច់ខាត លើស កោដិទៅ សុទ្ធជាបកតិសំខ្យាបាលី តែខ្មែរយកមកប្រើ ព្វក្រើជាខ្មែរ ។ ចំនួនទាំងអស់នោះធំជាងចំនួនមុនៗដល់ ទៅរយសែនដង គឺត្រូវថែមសូន្យ៧ទៅលើចំនួនដើម ទើប តជាចំនួនធំបន្ទាប់ៗគ្នា ដូចតទៅនេះ ៖

| សព្ទបាលី | សព្ទប្រែ | |
|---|---|---|
| បកោដិ | រយសែនកោដិ | (សូន្យ ១៤) |
| កោដិបកោដិ | រយសែនបកោដិ | (សូន្យ ២១) |
| នហុតំ | រយសែនកោដិបកោដិ | (សូន្យ ២៨) |
| និន្នហុតំ | រយសែននហុត | (សូន្យ ៣៥) |
| អក្ខោភិនី | រយសែននិន្នហុត | (សូន្យ ៤២) |
| វិន្ទុ | រយសែនអក្ខោភិនី | (សូន្យ ៤៩) |
| អព្ពុទំ | រយសែនវិន្ទុ | (សូន្យ ៥៦) |
| និរព្ពុទំ | រយសែនអព្ពុទ | (សូន្យ ៦៣) |
| អហហំ | រយសែននិរព្ពុទ | (សូន្យ ៧០) |
| អពពំ | រយសែនអហហ | (សូន្យ ៧៧) |
| អដដំ | រយសែនអពព | (សូន្យ ៨៤) |
| សោគន្ធិកំ | រយសែនអដដ | (សូន្យ ៩១) |

| | | |
|---|---|---|
| ឧប្បលំ | រយសែនសោគន្ធិក | (សូន្យ៩៨) |
| កុមុទំ | រយសែនឧប្បល | (សូន្យ១០៥) |
| បុណ្ឌរីកំ | រយសែនកុមុទ | (សូន្យ១១២) |
| បទុមំ | រយសែនបុណ្ឌរីក | (សូន្យ១១៩) |
| កថានំ | រយសែនបទុម | (សូន្យ១២៦) |
| មហាកថានំ | រយសែនកថាន | (សូន្យ១៣៣) |
| អសង្ខេយ្យំ | រយសែនមហាកថាន | (សូន្យ១៤០) |

សេចក្ដីសង្កេត – បណ្ដាសំខ្យាផ្នែកនេះ ខ្មែរយើងពុំដែលយកមកប្រើទេ ច្រើនមានតែនៅក្នុងគម្ពីរក្បួននក្ខត្ត ៗ យើងច្រើនប្រើពាក្យថា ១លាន, ១០លាន, ១០០លាន ..ទៅតាមរបៀបគុណ ៗ តែយូរៗម្ដង យើងតែងឮចាស់ៗនិយាយថា "ច្រើនពាន់កោដិ, ពាន់អសង្ខេយ្យ"... ដូច្នេះ ៗ

១កោដិមានសូន្យប្រាំពីរ ; ១បកោដិ គឺមាន១កោដិមួយរយសែនដង ត្រូវថែមសូន្យ៧លើកោដិទៀត ដូចនេះ

បកោដិមានសូន្យ ១៨ ។

វិធីប្រើបកតិសំខ្យា — បើនឹកចង់តែអ្វី ៗ ត្រូវដាក់បកតិសំខ្យា ទៀនភ្ជាប់ពីខាងដើម ឬពីខាងចុងទាម តាមដោយទំនង ស្រួលតាមគន្លងភាសា ដូចពាក្យថា ៖

មួយរៀល, ពីររៀល. មួយពាន់រៀល, ពីរពាន់នាក់, មួយពាន់ហាប. ៗលៗ

<u>បំណាំ</u> : — ក្នុងពាក្យខ្លះ គេត្រូវការប្រើយកបកតិសំខ្យាភ្ជាប់ ពីខាងដើមក៏បាន, ពីខាងចុងក៏បាន ។ វិធីប្រើបកតិសំខ្យា ពីខាងដើមឬពីខាងចុង ភ្ជាប់នូវពាក្យដដែលនោះ សូមកុំនឹកស្មានថា សំដីសិតទៅដដែលនោះឡើយ គឺមានន័យខុសគ្នាស្រឡះ ៖

១. ល្អបី បានន័យថា ល្អមានចំនួនបី

បីល្អ ——— វត្តមានចំនួនចំណុះបីដងនៃល្អ ។

## ១ – បូរណសំខ្យា (Nombres ordinaux).-

អត្ថន័យ – សំខ្យាដែលរាប់តាមតាម បង្គ្រប់ជាជាន់ៗ តាមលំដាប់ តាមថ្នាក់, គឺរាប់ថា « ទី១, ទី២,... ឬរាប់ថា ជាដំបូង, ជាបន្ទាប់, ជាគំរប់ ២, ជាគំរប់ ៣ ... ជាដើម និង ពាក្យថា៖ បឋម, ទុតិយ, តតិយ, ចតុត្ថ, បញ្ចម, ឆដ្ឋ, សត្ត, អដ្ឋ...ជាដើម ហៅថា «បូរណសំខ្យា» ។

បូរណសំខ្យា ពុំមែនអ្វីក្រៅពីបកតិសំខ្យាបន្ថែមពាក្យ «ទី» ឬ «គំរប់» ពីខាងដើមនោះទេ ។ បូរណសំខ្យា ជាសំខ្យាគុណនាមទាំងអស់ដែរ ។

**វិធីប្រើបូរណសំខ្យា** – នីតិប្រើបូរណសំខ្យាត្រូវភ្ជាប់បូរណសំខ្យានៅខាងចុងនាម ដូចពាក្យថា៖ ប្រការទី ១, ប្រការទី ៣ ... ជំពូកទី ៤, ជំពូកគំរប់ ៥ ... ។ តែត្រង់ «ជំពូកទី ១» នឹងថា «ជំពូកគំរប់ ១» មិនបានទេ ពីព្រោះថា សំខ្យាទីដំបូងបង្អស់ មិនទាន់មានចំនួនណាមកបង្គ្រប់នៅ

ទៀយ ៗ ត្រូវថា «ជំពូកដំបូង» ឬ «ជាដំបូង» ឬជា "ជំពូកទី ១" វិញ ។

ជួនកាល គេមានយកបកគតិសំខ្យា ប្រើជាបូរណសំខ្យា ដែរ ដូចពាក្យថា៖ "សៀវភៅទំព័រ ១០" បានសេចក្តីថា "សៀវភៅទំព័រទី ១០" ។

ឧទាហរណ៍ — កូនច្បង, កូនពៅ, ថ្នាក់បន្ទាប់, បោះពុម្ពលើកទី ១, គ្រាទីប្រាំ ... ។ល។ ... ។

ខ្មែរមានយកបូរណសំខ្យាបាលីមកប្រើខ្លះដែរ៖ បឋមមាសាធ, ទុតិយាសាធ, ទុតិយភូមិ, ត្រៃវេទ, សត្តសទ ចតុភាគ ..ជាដើម ។



# មេរៀនទី២៣ :- សព្វនាម ( Pronom )

នាមដែលប្រើជំនួស ឬជាជំនួយនាមនាមដែលពោលចេញឈ្មោះរួចមកហើយ ឬដែលកំពុងនិយាយចំពោះមុខ ដើម្បីមិនឲ្យជួនពាក្យដដែលៗ គឺយកពាក្យដទៃដោយឡែកមកប្រើជំនួសឬកំដរប្រកៀកគ្នា ជាមួយនឹងនាមនាមនោះវិញ ហៅថា " សព្វនាម " ។

សព្វនាមមានពីរយ៉ាងគឺ៖ បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

## បុរិសសព្វនាម

### ( Pronom personnel )

សព្វនាមដែលប្រើជំនួសឈ្មោះមនុស្ស, សត្វឬអ្វីៗ ដោយចំពោះរូប ប៉ុន្តែមិនចេញឈ្មោះទេ យកពាក្យដទៃផ្សេងពីនេះមកប្រើជំនួសវិញ ហៅថា " បុរិសសព្វនាម " ។

បុរិសសព្វនាម ចែកចេញជាបុរិសៈមានបីគឺ៖ បឋម-
បុរិស១, មជ្ឈិមបុរិស១ និងឧត្តមបុរិស១ ។

ក- បឋមបុរិស (3è Personne) - សម្រាប់ប្រើជំនួស
មនុស្ស, ឬសត្វអ្វីៗដែលយើងនិយាយចេញចំឈ្មោះរួចហើយ
ត្រូវយកពាក្យថា៖ វា, គាត់, គេ, នាង, លោក, ព្រះអង្គ
ទ្រង់,...មកជំនួសវិញ ដើម្បីកុំឲ្យស្ទួនពាក្យដដែលៗ នាំឲ្យ
ពិបាកស្ដាប់ ហើយជាស់ត្រចៀកផង ។

ឧទាហរណ៍៖ - លោកវណ្ណា កាលមិនទាន់អញ្ជើញទៅកំពត
លោកវណ្ណាមានមាឌស្គម ។ ប្រយោគនេះ ឃើញថាពាក្យ
ហៅលោក "វណ្ណា" ស្ទួនគ្នា នាំឲ្យមិនពីរោះស្ដាប់ ដូចនេះ
ត្រូវផ្លាស់ជាក់បុរិសសព្វនាមមួយវិញ៖ លោកវណ្ណា កាល
មិនទាន់អញ្ជើញទៅកំពត លោកមានមាឌស្គម ។

ខ- មជ្ឈិមបុរិស (2è Personne). សម្រាប់ប្រើជំនួសឈ្មោះ
បុគ្គលដែលគេកំពុងតែនិយាយទៅរកគ្នាចំពោះមុខ ហើយ

និយាយមិនចេញឈ្មោះនោះឡើយ ត្រូវយកពាក្យថា ៖

“ព្រះអង្គ, លោក, អ្នក, នាង, ឯង, គា. ហែង, ... ”

នេះជំនួសវិញ តាមពាក្យខ្ពស់, កណ្ដាល, ទាប ។

ឧទាហរណ៍ ៖

- បើលោកបានអញ្ជើញទៅលេងសៀមរាប លោកនឹងបានឃើញប្រាសាទអង្គរមិនខាន ។
- កាលណាទើបអ្នកផ្ញើសំបុត្រតបដំណឹងនេះ មកខ្ញុំវិញ ?
- នាងកុំប្រកាន់ថាខ្លួននាងជាស្រី ហើយខ្លួនមិនបាច់រៀនសូត្រនោះមិនត្រូវទេ ។
- បើឯងចង់ដឹង ចាំអញនិយាយប្រាប់ ។
- នរណាធ្វើអ្វីគា បានជាយំ ?
- បើហែងឯងមិនស្ដាប់អញ, អញនឹងវាយហែងឲ្យស្គាល់ដៃ ។

គ. ឧត្តមបុរស (le Personne). គឺជាសព្វនាម សម្រាប់ប្រើជំនួសឈ្មោះខ្លួនឯង (សំគាល់បុគ្គលអ្នកនិយាយ) គឺជាខ្លួនឈ្មោះអ្វី ៗ មិនបាច់បញ្ចេញឈ្មោះនោះទេ ដូចពាក្យថា ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំប្របាទ, ខ្ញុំបាទ, ខ្ញុំ, អញខ្ញុំ, ខ្ញុំម្ចាស់, អាត្មាភាព, អាត្មាអញ, អញ, យើង, យើងខ្ញុំ យើងទាំងឡាយ ... នេះជំនួសវិញតាមពាក្យខ្ពស់, កណ្ដាល, ទាប ៗ

ឧទាហរណ៍ .— ខ្ញុំព្រះករុណា ចេះតែបារម្ភខ្លាចក្រែងព្រះតេជ-

ព្រះគុណមិនសូវជា ៗ

— ខ្ញុំបាទ សូមក្រាបប្រណិប័តន៍ចូលមកលោកឪពុក អ្នកម្ដាយ សូមបានជ្រាប ៗ

— លោកគ្រូបានបង្គាប់យើងទាំងអស់គ្នាឲ្យមានសៀវភៅ "វេយ្យាករណ៍ខ្មែរទំនើប" មួយម្នាក់ ៗ

— យើងខ្ញុំបួងសួងដល់គុណព្រះរតនត្រ័យសូមឲ្យលោក

ជួយឧបត្ថម្ភអ្នក ។

- យើងបរិភោគបាយជាមួយគ្នា ។

- អញឲ្យឯងត្រឡប់មកវិញនៅពេលល្ងាចនេះ ដើម្បីអញបើកត្រានឲ្យ ។

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមបុរស | វា, គេ, គាត់, នាង, លោក, ព្រះអង្គ, | វាទាំងអស់, គេទាំងឡាយ, គាត់ទាំងឡាយ, នាងទាំងអស់, លោកទាំងឡាយ, ព្រះអង្គទាំងឡាយ, |
| មជ្ឈិមបុរស | អា, ហង, ឯង, អ្នក, លោក, នាង, ព្រះអង្គ, លោកម្ចាស់, | អាទាំងអស់គ្នា, ឯងរាល់គ្នា, អស់អ្នក, អស់លោក, អស់នាង, គ្រប់ព្រះអង្គ |

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ១ ឧត្តមបុរស | ខ្ញុំ, ខ្ញុំបាទ, ខ្ញុំប្របាទ, ខ្ញុំព្រះករុណា, ខ្ញុំម្ចាស់, អាត្មា, អាត្មាភាព, អញ, | ពួកខ្ញុំ, ខ្ញុំបាទទាំងអស់គ្នា, ពួកយើង, ពួកយើងខ្ញុំ, ពួកអញ, |

## វិសេសនសព្វនាម

(Pronom démonstratif)

សព្ទសម្រាប់ប្រើជាជំនួសនាមនាម មានលំនាំជាបទវិសេសនៈ ដើម្បីមិនឲ្យប្រទាំសេចក្ដីក្នុងសង្កាត់នៃប្រយោគមួយៗ ហៅថា «វិសេសនសព្វនាម» ដូចឧទាហរណ៍ថា

«លោកនេះមានអធ្យាស្រ័យយោគយល់ច្រើន; លោកឯទៀតមិនសូវបេះអត់ធ្មត់ទេ» ។

ពាក្យថា «នេះ, ឯទៀត» ជាវិសេសនសព្វនាម ។

វិសេសនសព្វនាមមាន២យ៉ាងគឺៈវិសេសនសព្វនាមនិយម១ នឹងវិសេសនសព្វនាមអនិយម១ ។

៦. វិសេសនសព្វនាមនិយម (Pronom indéfini).-

វិសេសនសព្វនាមដែលសំដែងសេចក្ដីជាច់ស្រេចហៅថា «និយម», ដូចជា៖ នោះ, នុះ, នុះនឹ, ហ្នឹង, នេះ, ម្នាក់ទៀត, មួយទៀត, ឯនេះ, ឯនោះ.. ។

៧- វិសេសនសព្វនាមអនិយម (Pronom relatif) –

វិសេសនសព្វនាម ដែលសំដែងសេចក្ដីមិនទៀងទាត់មិនដាច់ស្រេច ហៅថា «អនិយម», ដូចជា៖ ណា, ឯណា, ណាមួយ, ដែល, ដទៃ, ឯទៀត, ដទៃទៀត, ផ្សេងទៀត, ណាខ្លះ, ដូចម្ដេច, ពួកមួយ, ពួកខ្លះ, អ្នកខ្លះ, ខ្លះ, ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, អ្វី, អ្នកណា... ។

## សម្ពន្ធសព្វនាម (Analyse du Pronom).-

វិធាន: ដើម្បីនឹងធ្វើសម្ពន្ធសព្វនាមត្រូវមើលតើជាសព្វនាមបែបណា ? ជាបឋមបុរសសព្វនាម, ឬជាមជ្ឈិមបុរសសព្វនាម

ឬជាឧត្តមបុរិសសព្វនាម គឺជា ត្រូវតែគេគិតសព្វនាមនោះជាជំនួសឬជាជំណាងនាមសព្វណា មើលលិង្គនឹងវចនៈ រួចគេមើលប្រព្រឹត្តិការណ៍របស់វា ។

បំណាំ.— ១)- បុរិសសព្វនាមតាំងម្យ៉ាយ ប្រើទៅតាមលំដាប់ ពាក្យខ្ពស់, ពាក្យកណ្ដាល, ពាក្យទាប, ពាក្យកជសព្ទ ឬពាក្យសន្ត ។

២)- បុរកុំប្រទ្យំ នាង លោក ព្រះអង្គ ត្រង់បឋមបុរិសៈ

៣)- ដោយនូវសេចក្ដីគួរសម ខ្មែរយើងមានយកពហុវចនៈមកប្រើជាឯកវចនៈ ដូចជា៖ យើង ជំនួស ខ្ញុំ, អញ; អ្នក ជំនួស ឯង ។

ឧ. អ្នកទិញសៀវភៅវេយ្យាករណ៍ខ្មែរ យើងក៏ទិញដែរ។



## មេរៀនទី២៤:-កិរិយាសព្ទ (Verbe)

ពាក្យពោលនូវអំពើធ្វើឬពោលនូវដំណើរ ហៅថា "កិរិយាសព្ទ" ដូចពាក្យថា "ដេក, ដើរ, ឈរ, អង្គុយ ស៊ី, ផឹក, ងូត, លាង, ដុស, ដុះ, និយាយ, ស្ដី, យំ, ស្រែក ហៅ, កាប់, កាត់, វាយ, ប្រហារ, ឈូស, ចាំង, រៀន, អាន, សរសេរ, តែង, ធ្វើ... ជាដើម ។

កិរិយាសព្ទនេះចែកចេញជា ២ យ៉ាងគឺ៖ សកម្មកិរិយា ១ និង អកម្មកិរិយា ១ ។

ក)-សកម្មកិរិយា (Verbe transitif).- កិរិយាសព្ទណា ដែលមានបទឯទៀត បំពេញទើបមានសេចក្ដីពេញលេញ ឡើងបាន ដូចជាពាក្យថា៖ គេស្ទូចត្រី ។ ខ្ញុំឈូសឈើ ។ ចោរលួចទ្រព្យ ។ ពាក្យថា "ត្រី, ឈើ, ទ្រព្យ" ជាកម្មរបស់កិរិយា "ស្ទូច, ឈូស, លួច," គឺកិរិយាសព្ទៗណា

ដែលស្រែកហៅរកកម្មហៅថា « សកម្មកិរិយា » ។ បទ

ដែលយកមកបំពេញហៅថា " កម្មរបស់កិរិយា " ។

១–អកម្មកិរិយា (Verbe intransitif) – កិរិយាសព្ទដែល

មានអំពើគ្រប់គ្រាន់ដោយខ្លួនឯងហើយ មិនបាច់មានបទដទៃ

មកបំពេញអំពើឲ្យគ្រប់គ្រាន់ទៀតឡើយ ដូចពាក្យថា៖

– កូនយំ ។ ក្មេងដេរ ។ ក្មេងខ្ចីឈឺ ។ ឆ្កែកខ្ញុំមក ។

សត្វហើរ ។ ក្មេងដេះ ។ ខ្លាគ្រហឹម,... យ៉ាងនេះជា

ដើម គឺជាកិរិយាសព្ទមិនស្រែកហៅរកកម្មទេ ហៅថា

" អកម្មកិរិយា " ។

បំណាំ.– អកម្មកិរិយានេះ មិនបាច់ពឹងកម្មទេ

១. ទឹកហូរ ។ ព្រាបដេរ ។ គោពេន ។ សត្វហើរ ។ ពាក្យ

ខ្វះចុំណោះ គាប់កើតបានជាមួយប្រយោគយ៉ាងពេញបរិបូណ៌

ហើយ ។ ចំណែកសកម្មកិរិយាវិញ បើប្រើខ្វះចុំណោះមិន

កាលកើតបានជាមួយប្រយោគទេ ដូចពាក្យថា៖

— ចោរលួច, គេសួរ; ខ្ញុំឈូស, បងខ្ញុំទិញ, . . .

ពាក្យទាំងនេះមិនចេញជាប្រយោគទេ ព្រោះគេមិនដឹងថា៖

ចោរលួចអ្វី? គេសួរអ្វី? ខ្ញុំឈូសអ្វី? បងខ្ញុំទិញអ្វី? . . .

ដើម្បីឲ្យបានជាប្រយោគបរិបូណ៌ គេត្រូវបន្ថែមពាក្យមួយទៀតជាបទកម្មថា៖ ចោរលួចគោ ។ គេសួរត្រី ។ ខ្ញុំឈូសឈើ ។ បងខ្ញុំទិញព្រៃ . . . យ៉ាងនេះជាដើម ។

កិរិយាទាំងឡាយ ធ្វើអំពើទៅ ជួនកាលអំពើនោះបានទៅដល់គេដទៃទៀត, ជួនអំពើនោះក៏ត្រឡប់បានមកលើខ្លួនឯងវិញ ។

១ —ហេតុកិរិយា.— កាលណាកិរិយាធ្វើអំពើទៅ អំពើនោះបានដល់គេដទៃទៀតកិរិយានោះហៅថាហេតុកិរិយា

១.បង្រៀន, ពន្យល់, បញ្ចេញ, បញ្ចូល . . . ។

បង្រៀន គឺលោកគ្រូបង្រៀនទៅ ការចេះដឹងនឹងបានដល់

កូនសិស្សជាអ្នកទទួលអំពើ ។

២–សុទ្ធកិរិយា.– កាលណាកិរិយាធ្វើអំពើទៅហើយ អំពើនោះត្រឡប់បានមកដល់ខ្លួនវិញ គឺធ្វើអំពើចំពោះខ្លួនឯង កិរិយានោះ ហៅថា សុទ្ធកិរិយា ។

ឧ. រៀន, យល់, ដេក, ដើរ, អង្គុយ . . .

រៀន គឺអំពើរបស់កិរិយា បានមកដល់អ្នកនោះវិញ មិនមែនដល់អ្នកដទៃទេ ។

៣–កិតកិរិយា.–កិរិយាដែលចែកចេញពីនាមសព្ទដូចជាៈ ដួញ, ដួយ, ដះ. .ហៅថា "កិតកិរិយា" (សូមមើលទៅ "កិតកិរិយា" នៅមេរៀនក្រោយ) ។

ប្រធាន (Sujet).– នឹងចងជាប្រយោគក្ដី ធ្វើជាឃ្លាក្ដី កិរិយាតែឯង ឬ កិរិយាជាមួយនឹងកម្ម ពុំអាចញ៉ាំងប្រយោគ ឬ ឃ្លានោះឲ្យបានសេចក្ដីគ្រប់គ្រាន់ឡើយ ត្រូវយកពាក្យ

ផងទៀតមកប្រើ ដើម្បីនឹងធ្វើឲ្យអំពើឬឲ្យដំណើររបស់កិរិយាសម្ដែងឡើងបាន ។

ពាក្យដែលយកមកប្រើនោះហៅថាប្រធានកិរិយា

ដូចជាប្រយោគមួយថា "ប្អូនខ្ញុំលេងតែម្នាក់ឯងនៅវាលមុខផ្ទះ" ។ "ប្អូនខ្ញុំ" ជាប្រធានរបស់កិរិយា "លេង"

"ប្រធាន" គឺជាពាក្យដែលជាធំក្នុងការសម្រេចអំពើប្រធាននៃកិរិយានេះ ជួនកាលជានាមសព្ទ, ជាសព្វនាម ឬក៏ជាពាក្យច្រើនផ្គុំគ្នា ។

វិធាន.– ដើម្បីនឹងរកប្រធាននៃកិរិយា ត្រូវចោទពាក្យសួរថា "អ្នកណា? (ចំពោះមនុស្ស), អ្វី? (ចំពោះសត្វឬវត្ថុ)"

១. ខ្ញុំដើរលេង ។ អ្នកណាដើរលេង? ខ្ញុំ. ខ្ញុំជាប្រធាននៃកិរិយា "ដើរលេង" ។

កម្ម (Complément).– បើប្រសិនណាជាគេនិយាយថា "តាបានការពារ..." គេយល់បានថា ប្រយោគនេះមិន

ទាន់ពេញ ឬមិនទាន់ចប់ ព្រោះគេមិនដឹងជាទាហានការពា
ត្រូវឡើយ ។ បើគេនិយាយថា « ទាហានការពារមាតុភូមិ
យ៉ាងនេះ ទើបគេយល់ដល់គំនិតនៃប្រយោគ ។ ពាក្យ
« មាតុភូមិ » នេះជាកម្មរបស់កិរិយា ។

កម្មនៃកិរិយា គឺជាពាក្យដែលគេបន្ថែមលើកិរិយាស
ដើម្បីឲ្យប្រយោគនោះមានន័យ គឺថាឲ្យប្រយោគនោះមា
សេចក្តីពេញលេញ ដូចជាពាក្យថា « ខ្ញុំមាន... » ប្រយោ
នេះមិនមានន័យត្រូវឡើយ ព្រោះគេមិនដឹងជាខ្ញុំមានអ្វី ? មា
ប្រពន្ធ ឬមានកូន ឬមានសៀវភៅ ឬមានផ្ទះ នោះគេមិនអា
យល់ដោយច្បាស់បានទេ ចុះបើថា « ខ្ញុំមានប្រាក់ » ប្រ
យោគនេះគេអស់សង្ស័យទៀតហើយ ព្រោះគេដឹងថា
មានប្រាក់ មិនមែនខ្ញុំមានប្រពន្ធ,មានកូន,ឬសៀវភៅ...ទេ

កម្មសម្រាប់ធ្វើអំពើរបស់កិរិយា មានពីរយ៉ាងគឺៈ សកម្ម

បទ ១ និងអកម្មបទ ១ ។

## សកម្មបទ - ( Complément d'objet direct )

សព្ទ ឬពាក្យណាមួយដែលទទួលនូវអំពើរបស់កិរិយាសព្ទ ដោយត្រង់ ហៅថា " សកម្មបទ ,, ។

## អកម្មបទ·- ( Complément d'objet indirect )

សព្ទ ឬពាក្យណាមួយដែលមិនបានទទួលនូវអំពើរបស់ កិរិយាសព្ទដោយត្រង់ទេ ហៅថា "អកម្មបទ,, ។

វិធាន.- ដើម្បីនឹងរកកម្មរបស់កិរិយា ត្រូវពោលពាក្យចោទ ា " នរណាប្រព្រឹត្តអំពើនោះ? ,, ឬ អ្វីប្រព្រឹត្តអំពើនោះ? ' អ្វី ? ណា ? ឯណា ? កន្លែងណា ? ទីណា ? ពេលណា ? ហ៊ានដូចម្ដេច ? ហេតុដូចម្ដេច ? ,, ។ ឧទាហរណ៍ :- " ខ្ញុំ បើកទ្វារ ,, ខ្ញុំបើកអ្វី ? - ទ្វារ ទ្វារជាសកម្មបទរបស់កិរិយា បើក ។ អ្នកនិរទេស នឹកដល់ប្រទេសរបស់ខ្លួន នឹកទៅ

ណា ? – ប្រទេសរបស់ខ្លួន ជា អកម្មបទរបស់កិរិយា "នឹក,,

ដើម្បីតម្រូវតាមកាលៈទេសៈ "អកម្មបទ,, រងអំពើន
មានប្រាប់ដោយយ៉ាងថែមទៀត គឺប្រាប់ដំណើរឬប្រាប់បរិត, ប្រាប់ទីកន្លែង , ប្រាប់ពេលវេលា , ប្រាប់ហេតុ , ប្រាប់បំណង , . . . ។

ឧទាហរណ៍. – ខ្ញុំទៅភ្នំពេញ ; ខ្ញុំនឹងចេញទៅនៅថ្ងៃចន្ទ ; ខ្ញុំទៅកាន់ផ្សារដើម្បីទិញសៀវភៅ ។ ខ្ញុំធ្វើការដោយប្រុស ។ ខ្ញុំធ្វើកិច្ចនេះមិនបានល្អព្រោះហេតុខ្ជិល ។ . . .

– ខ្ញុំទៅឯណា ? – ភ្នំពេញ ជា អកម្មបទរងអំពើប្រាប់ទីកន្លែង ។

– ខ្ញុំនឹងចេញទៅនៅ (ពេល) ថ្ងៃណា ? – នៅថ្ងៃចន្ទ ជា អកម្មបទរងអំពើប្រាប់ពេលវេលា ។

– ខ្ញុំទៅកាន់ផ្សារដើម្បីអ្វី ? – ដើម្បីទិញសៀវភៅ ជា អកម្មបទរងអំពើប្រាប់បរិត ។

– ខ្ញុំធ្វើតេនេះមិនបានល្អព្រោះហេតុអ្វី ? – ព្រោះហេតុខ្ជិល ជា អកម្មបទរងតំពើប្រាប់ហេតុ ។

## កិរិយាអាខ្យាត :–

ក្នុងភាសាបាលី កិរិយាមានបែបបំបែកចុងសព្ទជាវិភត្តិ, កាល, បទ, វចនៈ, បុរិសៈ, ធាតុ, វាចក និង បច្ច័យ ។ ដំណើរធ្វើឲ្យមានបែបសំគាល់ទាំង ៨ យ៉ាងនោះ ហៅថា កិរិយាអាខ្យាត ។

ក្នុងភាសាខ្មែរ កិរិយាពុំមានផ្លាស់ចុងសព្ទឡើយ គឺនៅតែដដែល គេគ្រាន់តែបន្ថែមប្រធាន, បុរិសៈ, វចនៈ, និង កាលទៅលើកិរិយា ។

ក) <u>ប្រធាននៃកិរិយា</u> គឺជាពាក្យដែលធ្វើអំពើឬដំណើរនៃកិរិយាឲ្យសំដែងឡើង ។

ប្រធាននៃកិរិយាមាន បុរិសៈ និង វចនៈ ជាមួយគ្នា ។ បុរិសៈ និង វចនៈ ទាំងនោះគឺ ៖

| បឋមបុរស: ឯក. | មជ្ឈិមបុរស: ឯក. | ឧត្តមបុរស: ឯក. |
| --- | --- | --- |
| ពហុ. | ពហុ. | ពហុ. |

១)-កាលនៃកិរិយា ប្រាប់ពេលដែលកិរិយាត្រូវសំដែង ៗ

កាលមានបីគឺ៖

បច្ចុប្បន្នកាល.- ប្រាប់ពេលឥឡូវនេះ ហើយសំគាល់បាននឹងពាក្យ "កំពុង, កំពុងតែ...," ។ ឧ. ខ្ញុំសព្វថ្ងៃនេះកំពុងតែខំបង្កើតក្បួនជាអក្សរសាស្ត្រជាតិ; កំពុងធ្វើការ ។

អតីតកាល.- ប្រាប់កាលដែលកន្លងរួចមកហើយ សំគាល់បានដោយពាក្យ "បាន, បានហើយ...," ឧ. ខ្ញុំបានទទួលទានបាយរួចហើយ ។

អនាគតកាល.- ប្រាប់កាលដែលនឹងមាននៅខាងមុខហើយ សំគាល់បានទូវពាក្យ "នឹង, គង់, គង់តែ," ។ ឧ. សៀវភៅវេយ្យាករណ៍ខ្មែរទំនើបនេះ គង់តែមានថ្ងៃណាមួយនឹងហុចអត្ថប្រយោជន៍មកដល់នានាទាំងឡាយមិនខាន ។

## សម្ពន្ធកិរិយាសព្ទ

## ( Analyse du verbe )

វិធាន.- នឹងសម្ពន្ធកិរិយាសព្ទ ត្រូវមើលប្រភេទរបស់កិរិយា តើជាសកម្មកិរិយា ឬអកម្មកិរិយា ; រួចមើលកាល តើជាបច្ចុប្បន្នកាល , អតីតកាល ឬអនាគតកាល ; ហើយមើលលិង្គ និងវចនៈឲ្យសព្វគ្រប់ រួចសំរេចប្រធានរបស់កិរិយានោះ ។

ពិសេស.– បើមានពាក្យ " កំពុង , កំពុងតែ . . . " កិរិយាសព្ទនោះប្រាប់បច្ចុប្បន្នកាល ; បើមានពាក្យ "ពីម្សិល, ម្សិលមិញ , ព្រឹកមិញ , គ្រានោះ , លំដាប់នោះ , ដងនោះ, កាលនោះ, ក្សណៈនោះ, ឬមានពាក្យ បាន, បានហើយ...,, នៅពីដើមឃ្លា គឺប្រាប់អតីតកាល; ហើយបើមានពាក្យ "នឹង, សឹម, គង់តែ.... ,, នៅពីខាងដើមប្រយោគ គឺប្រាប់អនាគតកាល ។

## មេរៀនទី២៥:- កិរិយាវិសេសន៍ ( Adverbe )

ពាក្យបំពេញកិរិយាសព្ទ ដើម្បីធ្វើកិរិយាសព្ទឲ្យវិសេសឡើងថ្មី ធ្វើឲ្យប្លែកពីប្រក្រតី ហៅថា«កិរិយាវិសេសន៍»។ កិរិយាវិសេសន៍ អាចបន្ថែមសព្ទរបស់គុណនាមឲ្យប្លែកឡើងបានដែរ បើកាលណានៅក្នុងពាក្យគុណបទសម្ពន្ធ នោះគុណនាមនិងកិរិយាវិសេសន៍ បន្តភ្ជាប់គ្នាជាបទ ហើយហៅ"អតិវិសេសគុណនាម" ក៏បានឬក៏ហៅញែកពីគ្នាចេញក៏បាន ។

កិរិយាវិសេសន៍តាំងឡាយគឺៈ ឆាប់ , យឺត , លឿន , រហ័ស , ភ្លាម , ខ្ទឹក , ខ្ទិ , ខ្ទាក់ , រឿយៗ , មួយៗ , ខ្ញុញ , ដេរដាស , ពាសពេញ , គ្រៀបគ្រា , ជៀមជាម , ខ្ទន់ខ្ទប់ , ប៉េលប៉ាល , ប៉េរ , ប៉ើបៗ , ប៉ើក , ប៉ុកប៉ិន , ប្រដិតប្រដី , ប៉ោចៗ , ម៉ុំនឹរម៉ោក... ។

ដូចជាឧទាហរណ៍ថា.- ទៅឆាប់ , ដើរយឺត , ទៅលឿន

មកភ្លាម, តែខ្ទិត, រឹងខ្ទិ, ធាប់ខ្ទិ, ជ្រុះភ្លាក់ៗ, ដេញប្រកិត,
និយាយប៉ាចៗ ; គេស៊ីប៉ុកប៉ុន, គេស៊ីប្រជិតប្រជី, ទៅម៉ាំង·
មាក់, មនុស្សច្រើនខ្ទាន់ខ្ទាប់, មនុស្សច្រើនហូរហៀរ, ច្រើន
តាន់តាប់ ; ទឹកជន់ពេញត្រៀបត្រា. កុំពោលជៀមជាម, ផ្ញើ
មារយាទព្រឹមព្រម, រលំគ្រេង, អណ្ដែតប៉េលប៉ាល, ពោល
រៀយៗ, ដួលគួង, អង្គុយប៉ុក, ស្ងៅប៊ុន, ឃើញភ្លាមៗ,
ដំណើរកើតៗ . . . ។

## មេរៀនទី២៦:– ព្យាង្គ (SYllable)

អត្ថន័យ.– ចំណែក ឬ សង្កាត់នៃពាក្យផ្សេងៗដែលយកមក ផ្សំគ្នាឲ្យកើតជាមេពាក្យ នីមួយៗ ដូចជាពាក្យថា៖ សាលា (ព្យាង្គសា-លា), នគរ (ព្យាង្គ ន-គ), សម្តេច (ព្យាង្គសំ-ដាច់) យ៉ាងនេះជាដើម ហៅថា "ព្យាង្គ" ។

មាន ៤ យ៉ាងគឺ: ឯកព្យាង្គ ឬ ព្យាង្គទោល ១, ទ្វេព្យាង្គ១, ត្រៃព្យាង្គ ១ និង ពហុព្យាង្គ១ ។

–ឯកព្យាង្គ "សង្កាត់តែមួយ" ឬ "ពាក្យទោល" គឺចេញពីសំដីមួយម៉ាត់ ដូចជាពាក្យថា៖ កើត, ចាស់, ឈឺ, ស្លាប់, លេង, ផឹក, ទឹក, ដេក, ដើរ, ឈរ, សុខ, ទុក្ខ, ធំ, តូច, ឃើត, លឿន ... ជាដើម ។

–ទ្វេព្យាង្គ "សង្កាត់ពាក្យ២ម៉ាត់" គឺចេញពីសំដី២ម៉ាត់ រួមមកបានជារូបពាក្យតែមួយ ដូចជាពាក្យថា៖ សម្តេច,

សាលា, ភ្នំពេញ, ប្រាសាទ, វិមាន, សង្កាត់, ឧស្សាហ៍, សំបុត្រ, លំនៅ, ភូមិន្ទ, បន្ទាយ, ឪពុក, បិតា.. ជាដើម។

- ត្រីព្យាង្គ «សង្កាតពាក្យ ៣ ម៉ាត់» គឺចេញពីសំដី ៣ ម៉ាត់ រួមមកជារូបពាក្យតែមួយ ដូចពាក្យថា៖ អក្សរ-សាស្ត្រ, សាមគ្គី, វិទ្យាល័យ, វិទ្យាសាស្ត្រ, ចតុមុខ, នគាល័យ, សាស្ត្រាចារ្យ, រាជបុត្រ, កុមារី, សាសនា, វេទនា, កន្ទេះ-ឡង់, សេដ្ឋកិច្ច... ជាដើម ។

- ពហុព្យាង្គ «សង្កាត់ពាក្យដែលចេញពីសំដីច្រើនម៉ាត់» ដូចជាពាក្យថា៖ សិស្សានុសិស្ស, ថេរានុថេរ, រាជ-កិច្ចានុកិច្ច, ពុទ្ធសាសនា, ពុទ្ធសាសនបណ្ឌិត្យ, ឧស្សាហ-កម្ម, សន្តានុក្រម, វេទនានុក្រម, កម្ពុជរដ្ឋ, គណៈរដ្ឋមន្ត្រី, ក្រសួងសិក្សាធិការ, សតិសម្បជញ្ញៈ, ខេមរទេវានុប្បវត្តិ, គណៈកម្មការវប្បធម៌, អំពិលអំពែក... ជាដើម ។

# មេរៀនទី២៧:-ព្យាង្គតម្រួត

ពាក្យទាំងឡាយមានពាក្យខ្លះកើតឡើងពីព្យាង្គរាយ ខ្លះមកពីព្យាង្គតម្រួត ។ ព្យាង្គតម្រួតកើតពីពាក្យពីរព្យាង្គជាធម្មតា កាលណាព្យាង្គទាំងពីរនោះ ព្យាង្គខាងដើមមានអក្សរប្រកប ហើយអក្សរប្រកបនោះជាអក្សរនៅគន្លងគជាមួយគា-នឹងពាក្យព្យាង្គបន្ទាប់ ដូចជាពាក្យថា៖ សម្តេច, អង្គរ, អង្ករ, សង្កើច, សង្កេត, សង្ខេប, សណ្ដែក, សន្ទូច, សង្គម, សង្កៀរ, . . ជាដើម ហើយព្យាង្គទាំងពីរនេះ បើញែកគាចេញជាព្យាង្គមួយៗនោះគ្មានសព្ទប្រែទេ បើបែរជាប្រែបានក៏ប្រែខុសពីពាក្យដែលគេចង់សំដៅនោះដែរ ដូចជាថា៖ សន្ទូច, សម្ព័ន, ដណ្ដើរ... បើញែកជា សន់·ទូច សំ·ទៀង ដន់·ដើរ យ៉ាងនេះ នោះពាក្យនីមួយៗឥតសព្ទថាជាអ្វីឡើយ ៗ

ក្នុងពាក្យព្យាង្គតម្រួតនេះ កាលបើអក្សរដែលវណ្ណយុត្តិមួយកន្លងនឹងត្រីសព្ទតាមចំបែរឡើទៅជាអឃោសៈនឹងជាឃោ-

ស: ៧តួនេះគឺ៖ ង៉, ញ៉ា, ម៉, យ៉, រ៉, វ៉, និងហ៊ា នៅក្នុងព្យាង្គទីពីរនៃពាក្យ នោះអក្សរតួនេះតែងតែមានសូរសព្ទផ្អោនទៅតាមអក្សរក្នុងព្យាង្គទី១ឬព្យាង្គខាងដើមជាដរាប មិនចាំបាច់ប្រើមូសិកទន្តនិងត្រីសព្ទបន្ថែមលើពាក្យទាំងនោះឡើយ ដូចជាពាក្យថា៖ បម្លាយ, សម្ញែងឬសំញែង, ប៉ុន្មាន, សន្យា, ចំរើនឬចម្រើន, អង្វរ, តំហក, ដំហាន ... ជាដើម ។

ពាក្យពីរព្យាង្គទាំងឡាយ មិនអាចនឹងបញ្ញត្តថាត្រូវតែសរសេរតម្រួតគ្នាទើបបាន និងសរសេររាយតួពុំបានដូច្នោះឡើយ ព្រោះ៖

១- មានពាក្យពីរព្យាង្គខ្លះ ត្រូវតែសរសេរតម្រួតគ្នាជាដរាបទើបបាន មិនអាចសរសេររាយតួបានឡើយ ដូចពាក្យថា៖ បន្លែ, កន្ទុល, សង្កើប, សង្កត់, សម្ដេច, សម្បត្តិ, សក្ការ, សម្ពន្ធ, សម្ពោធ, សង្កេត, ... ។ ពាក្យជំពូកនេះច្រើនជាពាក្យឃ្លាតក្លាយមកពីបាលី, សំស្ក្រឹត; ឯពាក្យខ្មែរសុទ្ធសាធមានតិចតួចណាស់ ។

២. ពាក្យពីរព្យាង្គខ្លះ ត្រូវតែសរសេរពេញតួជាដរាប មិនសរសេរតម្រួតគ្នាពុំបាន ដូចជាពាក្យថា៖ សំដី, សំដៅ, ដំរី, ដំនឹ, ដំនុំ, ដំបៅ, ដំបូល, ដំបែ ... ។

៣. ពាក្យពីរព្យាង្គខ្លះទៀត អាចមិនសរសេរតម្រួតគ្នា តែដោយផ្លាស់និគ្គហិត ( ំ ) ជា "ង" ឬ "ម" ក៏បាន, សរសេរពេញតួក៏បាន តាមតែអាសាចិន្តានិក មិនមានពាស់ខុសអ្វីឡើយ ។ ពាក្យទាំងនោះមានច្រើនជាអនេក ដូចជា៖ សំបើមឬសម្បើម, កម្រឬកំរ, បម្រើនឬបំរើន, ជម្ងឺឬជំងឺ, សង្វេគឬសំវេគ, សង្វរឬសំវរ, សម្ងាត់ឬសំងាត់, សម្រាន្តឬសំរាន្ត, សម្លាញ់ឬសំឡាញ់ ... ។

ក្រៅពីនេះពាក្យពីរព្យាង្គដទៃទៀត ដែលកើតឡើងពីការផ្សំព្យញ្ជនៈពេញតួរួមបញ្ចូលគ្នា ហើយត្រូវបានប្រើជាពាក្យតែមួយម៉ាត់ ហើយមានព្យាង្គពីរ ពាក្យទាំងនោះមិនសរសេរឲ្យដាច់ឃ្លាតឆ្ងាយពីគ្នាពុំបានឡើយ ។ ពាក្យពីរព្យាង្គដែលមានអក្សរពេញតួយ៉ាងដូច្នេះ ព្រោះអក្សរក្នុងព្យាង្គដើមជាអក្សរ

ឃោសៈក្តី ជាអក្សរអឃោសៈក្តី នោះព្យាង្គខាងចុងដែលមាន អក្សរដូចបានពោលមកខាងលើនេះ ក៏តែងតែមានសូរសព្ទ បន្ថែមទៅតាមព្យាង្គខាងដើមដែលជាអក្សរឃោសៈឬជាអក្សរ អឃោសៈនោះ ហើយដល់កាលណាសរសេរ មិនចាំបាច់ ដាក់មូសិកទន្តឬត្រីសព្ទបន្ថែមទៀតទេ ដូចជាពាក្យថា៖ ព្រហស្បតិ៍, ព្រហើន, ព្រហាម, តំហក, ត្រហឹម, ត្រហស្ត, ជំហាន, ចំហាន, ក្រវែល, ក្រវិលក្រវ៉ាយ, ប្រវែង, ប្រវ៉ាយ, ប្រវ័ញ្ចន៍, ប្រមឹក, ក្រមុំ, ក្រយា, ក្រយៅ, ក្រញូរ, ក្រញី, ក្រញូវ... ។

អក្សរ "ប" នេះអាចបញ្ចេញសម្លេងបាន៣បែបគឺ៖ "ប, ប៉ និង ប៊" ដូចជាពាក្យថា៖ ក្របី, ចំប៉ា, សាប៊ូ, ។ ប៉ុន្តែអក្សរ "ប" នេះ បើទុកជាប្រកបប្រើក្នុងព្យាង្គទី២នៃពាក្យ ក៏ដោយ ក៏នៅតែនិយមបញ្ចេញសម្លេងតាមទំនើងចិត្តរបស់ខ្លួន មិនព្រមបញ្ចេញសម្លេងជា "ប៊" ទៅតាមព្យាង្គខាងដើម ឡើយ ដូចជាពាក្យថា៖ ក្របី, ក្របែល, ត្របក, ត្របាក់,

ត្របែក , សំបើម , សំបែង , ដំបៅ ,... ជាដើម នៅតែបញ្ចេញសម្លេង " ប „ ដដែលៈ ហើយមិនត្រូវគានថា " ក្របី, ក្របើល, ត្រប៉ាក , ត្រប៉ែក , សំប៉ើម , សំប៉ែង , ដំប៉ៅ... នោះទេ „

បើចង់ឲ្យអក្សរ « ប » នេះបញ្ចេញសម្លេងជា « ប៉ » តាមពាក្យដែលត្រូវការប្រើនោះ ត្រូវតែដាក់មូសិកទន្តជាដាច់ខាត បន្ថែមលើព្យាង្គទីពីរនោះទៀត ដូចពាក្យថា៖ ផ្កាចំប៉ី, ផ្កាចម្ប៉ា, កន្ទួលសំប៉ែត, ជិះសំប៉ាន , កប៉ាល់បារ, ដួលស្រប៉ាប់ទៅនឹងដី , ក្មេងនេះស្រែកហៅប៉ាម៉ា , ខ្ញុំញាត់ក្រដាសពេញហោប៉ៅក្លូកសង្ហា ដើម្បីបំភ័ន្តគំនិតគេថាខ្លួនខ្ញុំមានប្រាក់ច្រើន ៗ...

អក្សរ " ល „ នេះក៏បន្ទន់សម្លេងបានជាពីរបែបដែរ គឺៈ បង្អោនសម្លេងរបស់ខ្លួនទៅតាមព្យាង្គខាងដើមដែលជាអឃោសៈនោះក៏មាន នៅរឹងតែបញ្ចេញសម្លេងតាមទំនើងរបស់ខ្លួនក៏មាន ៗ

— អក្សរ " ល „ ដែលត្រូវតែមានសម្លេងជា " ឡ „,

តាមព្យាង្គខាងដើមដូចជាពាក្យថា៖ប្រលោមលោក, ប្រល័យ, ប្រលង ឬប្រឡង, ជម្ពៃ, ជម្ពឹង, ជម្ពើង, ជម្ពោះឆ័ត្រ, បម្ពៃ បម្ពោះ, បម្ពង, បន្ទុះ, បម្ពែក, សម្ពុ, សម្ពក់, សម្ពាញ់ ឬសំពាញ់ ... ។

- អក្សរ «ល» ដែលនៅមានសម្លេងរងឹតង្អជា «ល» ផងដែល គឺមិនព្រមបង្អេនសម្លេងទៅតាមព្យាង្គខាងដើមដែលជាអក្សរអឃោសៈនោះគឺ៖ អន្ទក់, អន្ទង, អន្ទង់, អនន, អន្ទើ, អន្ទៃ, វៀរលែងតែពាក្យ «អន្ទាយ» ១ ម៉ាត់នេះ ដែលត្រូវបញ្ចេញសម្លេងតាមព្យាង្គខាងដើម មិនត្រូវអានថា៖ «ទឹកខាប់អន្ទាយ; (ទឹកខាប់អន-ណាយ) ដូច្នេះឡើយ ត្រូវអាន-អន-ណ៉ាយ ដូច្នេះទើបត្រូវ ។

អក្សរ «ល» ដែលរងឹតង្អមិនព្រមបញ្ចេញជា «ឡ» កាលណាព្យាង្គខាងដើមនោះតាំងផ្ដើមឡើងជា «អ-ន» ។

ចំណែកអក្សរ «រ» ក៏យ៉ាងដូច្នេះដែរ គឺជួនកាលក៏បញ្ចេញសម្លេងទៅតាមព្យាង្គខាងដើមជា «រ៉» ដូច្នេះក៏មាន

ជួនណាទៅជា "រ" តាមរូបកំណើតវិញក៏សឹងមាន ៗ ប៉ុន្តែដែលនៅជាអក្សរ "រ" មិនព្រមទៅជា "រ៉" នោះ មាន ពាក្យតិចមាត់ដែរទេ គឺ៖ អង្រង់, អង្រន់, អង្រឹង, អង្រែត, អង្រែស, អង្រែ ៗ ក្រៅពីនេះ ហើយប្រកាន់ខ្ជួនជា "រ" ទៀតហើយ តែបណ្ដាយតាមព្យាង្គខាងដើមគេទាញកែ យ៉ាងណា ក៏តាមតែចិត្តរបស់គេចុះ ដូចពាក្យថា៖ អម្រស់-អម្រែ; ជ័រ, ចំរើ, ចំកម, កំរើក ... ជាដើម ៗ

ការដែលតម្រួតពាក្យនោះ លុះតែអក្សរប្រកបរបស់ព្យាង្គខាងដើម និងអក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់គ្នាផង គឺថា អក្សរទី១នៅលើអក្សរទី២, អក្សរទី៣ នៅលើអក្សរទី៤, អក្សរទី៥នៅលើអក្សរទាំង៤ក្នុងវគ្គរបស់ខ្លួនរៀងជាបទៅ ៗ

ដូចឧទាហរណ៍ថា៖ កក្ខ, បច្ឆិម, សង្ខារ, បង្គាប់, ដណ្ដើម, កន្ទាំង, ជញ្ជាំង, កញ្ចប់, កញ្ចាស់, ជន្ទរ, ជញ្ជីង, កន្ទុក, កន្ទុល, កញ្ជើ, សណ្ដាប់, បម្រុង, បម្រើ,.... ជាដើម ៗ

តាមសង្កេតទៅឃើញមានច្រើនតែអក្សរទី ៥ គឺ៖ ង, ញ, ណ, ន, ម, នៃវគ្គទេ ដែលតម្រួតនៅលើតួឯទៀតសម្បូណ៌ជាងគេ តែទុកជាយ៉ាងនេះក៏ដោយ ក៏នៅតែមានពាក្យពីរព្យាង្គខ្លះទៀត តម្រួតលើអក្សរទីបំផុតនៃវគ្គដែរ តែអក្សរដែលតម្រួតនោះនៅក្នុងវគ្គផ្សេងគ្នាទៅវិញ ដូចជាពាក្យថា៖ សម្តេច, សម្តែង, កម្ពុច, សម្ពាយ, សម្ព្រង, សម្ពុំ, ប៉ុន្មាន, កម្ពិល.. ជាដើម ។

ប៉ុន្តែពួកសេសវគ្គ " យ, រ, ល, វ, ស, ហ, អ, ពួកនេះ នៅពីក្រោមតួអក្សរបុនវគ្គណា ៗ ក៏បាន តាមសំដីដែលជួលទៅ ដូចជាពាក្យ៖ សង្សារ, សង្ស័យ, សន្សើម, សម្រេច កន្ត្រង, កន្ត្រៃ, កន្ល់, អន្សូរ, បញ្ហា, បន្សា, តណ្ហា, បន្យាត់, ពន្យល់, កន្ទង់, គន្លាល, បង្រិត, កម្ហុង, កម្សត់, ជន្លាយ, ផ្លោះ ជាដើម... ។

ក្រៅពីនេះពាក្យ " សន្តាន, សន្តោស, ចិន្តា, អន្តរ,

(អន្តរធាន, អន្តរកប្ប...)កន្តារ(ដ៏)(Désert)” ដែលជាពាក្យបាលី យើងខ្ចីយកមកប្រើ ហើយគានបំប្លែងសម្លេងទៅជា “សណ្ដាន, សណ្ដាស, បិណ្ដា, អនង, កណ្ដា” ទៅវិញ យើងត្រូវតែនាំគ្នាសរសេរពាក្យទាំង ៤ មាត់នេះ ជាយ៉ាងនេះដដែល ដើម្បីនឹងរក្សាគោលដើមរបស់ពាក្យ ។

ក្នុងភាសាបាលីដែលយើងយកមកប្រើ ដូចជា “បក្ខ, ភិក្ខុ, វត្ថុ, កក្កដា, កញ្ញា.” នេះមានវិធីតម្រួតទៀងទាត់ណាស់ គឺព្យញ្ជនៈទី ១ ត្រួតលើតួឯងក៏បាន លើព្យញ្ជនៈទី ២ ក៏បាន ; ព្យញ្ជនៈទី ៣ ត្រួតលើតួឯងក៏បាន លើព្យញ្ជនៈទី ៤ ក៏បាន ; ឯព្យញ្ជនៈទី៥ត្រួតលើតួឯងក៏បានដែរ លើកលែងតែ “ង” មួយចេញដែលនឹងតម្រួតលើតួឯងពុំបាន ឬត្រួតលើអក្សរណាមួយក្នុងវគ្គរបស់ខ្លួនក៏បាន ។ ព្យញ្ជនៈក្នុងអវគ្គពួកគឺ “យ, ល, ស,” នេះតម្រួតលើតួឯងបាន ដូចពាក្យថា ៖ កក្កដនេត្រ, ខែកក្កដា

ចក្កព័ន, សក្ការបូជា, ទុច្ចរិត, មច្ចុរាជ, បច្ចាមិត្រ, សច្ចាប្រ-ណិធាន, វិត្តសង្ក្រាន, វត្ត, កិត្តិសព្ទ, ទិសត្តឃាដ, អត្តលេខ, ចក្ខុប្បសាទ, ចតុប្បាទ, សប្បាយ, សប្បុរស, ចក្ខុ, ភិក្ខុ, អក្ខរៈ, បេក្ខជនសេរី (Candidat libre) មច្ឆជាតិ, អច្ឆរា, មិច្ឆាទិដ្ឋិ, បុប្ផទន្ត, បុប្ផជាតិ, បុប្ផានារី, វត្ថុ, អត្ថកោវិទ, អត្ថកថា, ទុគ្គត, បុគ្គល, បុគ្គលិក (Personnel), មគ្គុទ្ទេសក៍ អគ្គបណ្ឌិត, អគ្គមហាបុរសរ័តន៍, ទុជ្ជន, វេជ្ជកាល, វេជ្ជទាយាទ ភេសជ្ជៈ, តិរោកុឌ្ឌសូត្រ, សត្តុទ្រម, មទុរដ្ឋ, បុព្វសិក្ខា, បព្វជិត, បព្វជ្ជា, បុព្វាចារ្យ, ឧក្រោសនសព្ទ, អនេកអនេក្យ, ព្យគ្ឃ, មជ្ឈិម, មជ្ឈដ្ឋាន, អព្ភាកាស, វិព្ភុទធម៌, ព្រះពុទ្ធឃោ-សាចារ្យ, យុទ្ធោបករណ៍, ទុក្កសិត, កញ្ញា, កតញ្ញូ, បញ្ញា, បញ្ញត្តិ, បណ្ណាល័យជាតិ, ឧណ្ណាលោម, ពណ្ណរាយ, កាព្យ, កណ្ណី, កិន្នរ, សន្និបាត, សន្និដ្ឋាន, កម្ម, ការម្មណ៍; ធម្មជាតិ, ព្រះសម្មាសម្ពុទ្ធ, វេជ្ជធម្មញ្ញូ, ធម្មតា ... ជាដើម ។

៦ សញ្ញាស្រៈ ដែលនៅពីលើឬពីមុខ នឹងពីក្រោយឬពីក្រោម តួព្យញ្ជនៈលើ គឺផ្សំនឹងព្យញ្ជនៈក្រោម ៗ មិនត្រូវសរសេរតួព្យញ្ជនៈតម្រួតនោះទៅក្រោមស្រៈទេ ព្រោះថាដាក់ក្រោមស្រៈ ទៅជាស្រៈនោះធំជាងព្យញ្ជនៈទៅវិញ ដូចជាពាក្យថា ៖ សង្កាត់, សម្មា, ឆ្នោត, បព្វជា, បុព្វា, យ៉ាងនេះនឹងឲ្យមើលថា សង់-កាត់, ស័ម-ម៉ា, ឆ្នោត, ប័បព័បជា បុប-ជា, យ៉ាងនេះពុំបានឡើយ ដោយហេតុថាស្រៈអាស្រ័យនឹងព្យញ្ជនៈ ទើបបង្កើតជាពាក្យបាន ចុះនេះព្យញ្ជនៈអាស្រ័យនឹងស្រៈវិញ គេមានពុំដាច់ទេ ហើយនឹងឲ្យហៅថាជាព្យាង្គតម្រួតក៏មិនបានដែរ ព្រោះក្នុងព្យាង្គតម្រួត គេតម្រួតលើតួព្យញ្ជនៈ មិនមែនតម្រួតលើស្រៈនោះទេ ហើយបើទៅតែក័ន្តប្រឡំបែបនេះទៀត នឹងបាត់ជាខុសពេញទី នឹងឲ្យអក្សរាស្រ័យខុះពុំបានឡើយ ។

# មេរៀនទី២៨

## អាយតនិបាត ( Mot euphonique du temps )

ពាក្យមួយចំណែកសម្រាប់ប្រើភ្ជាប់នឹងពាក្យដទៃ ដើម្បីឲ្យដឹងថាពាក្យណាភ្ជាប់នឹងពាក្យណា សេចក្ដីជាប់ទាក់ទងគ្នាយ៉ាងណានោះ ហៅថា "អាយតនិបាត"។

អាយតនិបាតមានអត្ថប្រព្រឹត្តទៅតាមទំនងសេចក្ដីដូចតទៅនេះ៖

អាយតនិបាតទី១.- "នៃ" សម្រាប់ប្រើជាបទប្រធាន ឬដើមបទចំពោះពាក្យកាព្យខ្លះដូចជា "នៃអំពើជាកុសល ផនតប្បធ្វើ; នៃគ្រូបាធ្យាយ ប្រដូចនូវមាយ ឪពុកឯងហោង .; នៃមូលពឹងក្រឡឹង នៃត្រង់ពឹងបន្ទាត់ នៃកិរិយាពឹងសំពត់ អ្នកបរិសុទ្ធពិតពឹងសីល; នៃបុណ្យទឹងបាប អំពើសុភាព នោះក៏តែងតាម ប្រដូចស្រមោល អន្ទោលតាមប្រាណ មិន

ដែលបៀសបាន ត្រង់ក្ដីសល់រលំ ។

## អាយតនិបាតទី២ - (មានអត្ថ៥យ៉ាង) ។

១ – "នូវ" សម្រាប់ភ្ជាប់កម្មរបស់សកម្មកិរិយា

ឧទាហរណ៍ : ខ្ញុំធ្វើនូវអំពើល្អ, គេស្ដាប់នូវធម៌, សុភាសិតពោលនូវពាក្យត្រូវត្រង់ត្រាប់, លោកសំដែងនូវធម៌...។

ប៉ុន្តែក្នុងភាសាដែលគេនិយាយជាធម្មតា គេច្រើនកាត់ពាក្យ "នូវ" ចោល ដូចជាគេនិយាយថា "លោកសំដែងធម៌"...។

២.-"កាន់" សម្រាប់ភ្ជាប់កម្មទៅអកម្មកិរិយា

ឧទាហរណ៍: កូនខ្ញុំទៅកាន់សាលាដើម្បីសិក្សារួចហើយត្រឡប់មកកាន់ផ្ទះវិញ...។

ប៉ុន្តែតាមភាសាធម្មតា គេច្រើននិយាយកាត់បទ ដូចជាថា "កូនខ្ញុំទៅសាលាដើម្បីសិក្សារួចហើយត្រឡប់មកផ្ទះវិញ"។

៣.-"ញ៉ាំង"ជាទីទទួលសម្រេចនូវអំពើដែលគេប្រើ

ឲ្យធ្វើ ។

ឧទាហរណ៍: ពពកសត្វផង សាហាវយង់យង ប្រយ័ត្ន ញ៉ាំងបាន...; ពន្លឺញ៉ាំងលោកឲ្យផុតពីងងឹត, គ្រូប្រដៅសិស្សញ៉ាំងសិស្សឲ្យរៀន... ។

៤ "អស់" ជាទីប្រព្រឹត្តទៅ រហូតដល់ ។

ឧទាហរណ៍: អ្នកមកអស់ប៉ុន្មានថ្ងៃហើយ? ម្ដាយមីងខ្ញុំទៅបាត់ជំបង់អស់យប់មួយហើយ ។

៥.– "ចំពោះ" – "ចំពោះ" ជាទីទទួលពាក្យដែលគេនិយាយចំពោះខ្លួន ។

ឧទាហរណ៍: គេផ្ដាំមកនឹងខ្ញុំ; ខ្ញុំបាននិយាយនឹងអ្នករួចហើយតើ, ខ្ញុំសូមជូនកូនកន្សែងនេះចំពោះអ្នក... ។

អាយតនិបាតទី៣––(មានអត្ថ៦យ៉ាង) គឺ៖

១ –"ដោយ" ជាគ្រឿងសម្រេចនូវអំពើ

ឧទាហរណ៍: គេធ្វើការដោយសេចក្ដីភក្ដី; ដោយ

កម្លាំងប្រាជ្ញានិងកម្លាំងកាយ ខ្ញុំខំប្រឹងតជាវេយ្យាករណ៍ខ្មែរទំនើបនេះឡើង ; ដោយស្នាព្រះហស្តព្រះករុណាជាម្ចាស់ជីវិតលើត្បូងព្រះបាទ «នរោត្តម-សីហនុ» ប្រទេសកម្ពុជាបានឯករាជ្យពេញទី ។

២ - "ដោយនូវ, តាម, ដោយសារ" ជាផ្លូវជាលំនាំដែលថ្លែកពីការសម្រេចនូវអំពើ ។

ឧទាហរណ៍: ព្រះពុទ្ធរុងរឿងដោយនូវតេជះ; ចូរឯងធ្វើតាមពាក្យរបស់អញ, តាមចិត្តខ្ញុំ ខ្ញុំបង់ចិទមាត់ឲបដៃវិញទើបបានគ្មានខុសគ្មានគេនិន្ទា , ខ្ញុំរស់នៅដោយសារសេចក្តីទំនុកបំរុងរបស់ឪពុក-ម្តាយខ្ញុំ ។

៣ - "គឺ, ដែល" ជាអ្នកសម្រេចនូវអំពើខ្លួនឯង ។

ឧទាហរណ៍: ធម៌គឺការៈដែលទ្រទ្រង់, គឺអ្នកនេះហើយ ឬដែលមិនចូលចិត្តលើកដំកើងអក្សរសាស្ត្រជាតិ; ត្រូវសូត្រពាក្យដែលខ្ញុំបានឲ្យទន្ទេញ ។

៤.- "ហេតុ, ព្រោះ, ព្រោះតែ" ជាហេតុ, ជាទំនង, ជាដំណើរ ។

ឧទាហរណ៍: ហេតុតែខ្ញុំក្រហើយបានជាលំបាកយ៉ាងនេះ។ ប្អូនខ្ញុំមិនបានទៅសាលារៀនព្រោះវាឈឺ ។ ខ្ញុំធ្វើនេះ ព្រោះតែចង់ឲ្យអ្នករាល់គ្នាចេះដឹងអក្សរសាស្ត្រជាតិបានជ្រៅជ្រះ ។ ព្រោះតែអ្នករាល់គ្នាមិនចូលចិត្តអានអក្សរសាស្ត្រជាតិ បានជាយើងខ្សត់ខ្សោយទស្សនាវដ្ដី ។ ព្រោះតែយើងមិនគិតខំសិក្សាអក្សរសាស្ត្រជាតិ បានជាសរសេរខុសរាល់រាល យ៉ាងនេះ; សត្វលោកមានចិត្តខ្ពស់ទៀង ព្រោះលាភ ។

៥.- "មាន" ជាអាការៈ ។

ឧទាហរណ៍: បើយើងមានចិត្តមានថ្ងើម ត្រូវតែស្នេហាជាតិ។

៦.- "ដោយ, មួយ, ជាមួយគឹង" ជាគ្រឿងប្រកបជាមួយ ។

ឧទាហរណ៍: ចូរព្រមព្រៀងគ្នាមួយអន្លើដោយដំណើរនោះៗ

អាយតនិបាតទី៤ – (មានតែ ៣ យ៉ាង) គឺ៖

១.– "ដល់" ជាទីទទួលនូវអំណោយ ។

ឧទាហរណ៍៖ ក្រលំបាកឲ្យនូវផលដល់អ្នកកំជិល ។ សេចក្តីអន្តរាយផងទាំងពួងកុំបីមានដល់អ្នកឡើយ ។

២.– "ដើម្បី ឬ បម្រុង" ជាទីធ្វើបពួន ។

ឧទាហរណ៍: គេបង្គាប់ឲ្យអ្នកពលគ្នាមានចិត្តក្លាហាន ដើម្បីការពារមាតុប្រទេសនៅគ្រាអនាគត; របស់នេះខ្ញុំបំរុងទុកជូនអ្នក ។

៣.– "បំណែក ឬ និង" ជាទីត្រូវគេបៀតបៀន ។

ឧទាហរណ៍: អ្នកណាប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្ត អ្នកនោះគង់ដល់នូវសេចក្តីវិនាសជាពុំខាន ។

អាយតនិបាតទី៥.– (មានតែ ៣ យ៉ាង) គឺ៖

១.– "អំពី ឬ ពាក" ជាដែនចេញឬជាដែនដែលគេត្រូវវៀរលែង ។

ឧទាហរណ៍ ភ័យអំពីសេចក្ដីស្លាប់; បុគ្គលគប្បីឃាត់នូវ
ចិត្តចាកបាប គឺជាបុគ្គលគប្បីលះបង់បាប ។

២.- "ជាង" ជាដែនប្រៀបធៀបឲ្យដឹងថា លើសឬថយ
ជាងគ្នា ។

ឧទាហរណ៍ ខ្ញុំអាយុតិចជាងអ្នក តែអ្នកមានមាឌតូចជាងខ្ញុំ ។

៣.- "ហេតុ, ព្រោះ, ព្រោះតែ" ជាទីមូលហេតុ,
ដើមចម ។

ឧទាហរណ៍ សង្គ្រាមទាំងឡាយកើតព្រម ព្រោះសេចក្ដី
លង់នាំកាទ៌ឲ្យកើត ។

អាយតនិបាតទី៦ -(មានអត្ថ៤យ៉ាង) គឺ៖

១ -"នៃ, របស់" ជាគ្រឿងជាប់ដោយម្ចាស់របស់ ។

ឧទាហរណ៍៖ ផ្ទះស្លឹកទាំងឡាយនៃអ្នកជាយក្រុង; សៀវភៅ
នេះជារបស់ខ្ញុំ ។

២ - "នៃ" ជាគ្រឿងជាប់ដោយពួក, ដោយក្រុម ។

ឧទាហរណ៍: ប្រជុំនៃជនទាំងឡាយ; ហ្វូងនៃគោទាំងឡាយ;

៣.– "នៃ" ជាគ្រឿងជាប់ដោយការសព្ទខាងដើម ។

ឧទាហរណ៍: កិច្ចដោយប្រពៃមិនមានឡើយ ព្រោះការៈនៃពន្ធទ្រព្យគាត់មានក្នុងកាលឥឡូវនេះ ។ ការៈនៃអត្តកុលបុត្រតបៀងក៏បានដោយកម្រ ។

៤. "កាល, កាលបើ, កាលដែល" ជាសេចក្ដីជ្រកចូលមកប្រហែលដូចជាបទប្រធានដោយខ្មែរ ។

ឧទាហរណ៍: កាលដែលខ្ញុំមកសាលារៀន បងស្រីខ្ញុំនៅកំពុងដេរប៉ះ, កាលបើព្រលប់មួយ អ្នកពល់គ្នាត្រូវប្រឹងខ្មែរ

៥.– "ដ៏ទៃ, បណ្ដា" ជាសេក្ដីដកញែកចេញឲ្យដាច់ដោយខ្មែរ អំពីបង្អួចដែលរួម ដែលប្រមូល ។

ឧទាហរណ៍: បណ្ដាមនុស្សទាំងឡាយ ក្សត្រិយ៍គៀវកាចបំផុត; ជំនុំមនុស្សទាំងដប់នាក់នេះ ត្រូវចាត់មនុស្សបីនាក់ឲ្យទៅបាំផ្ទះ, ដំនុំអ្នកនគរទាំងមូល ព្រះមហាក្សត្រជាធំបំផុត ។

អាយតនិបាទិតត.–( មាន៩ យ៉ាង ) គឺ៖

១.– «ក្នុង» ជាទីកំបាំង ។

ឧទាហរណ៍៖.–គេអង្គុយក្នុង ; ខាងក្នុងនៃបន្ទប់ ។

២.– «ក្នុង» ជាទីជ្រកជ្រាបឬលាយគ្នា ។

ឧទាហរណ៍ –ប្រេងស្ថិតនៅក្នុងសណ្ដែកដាំងឡាយ ; ទឹកដោះស្រស់ស្ថិតនៅក្នុងទឹក ។

៣.–«ក្នុង» ជាទីអាស្រ័យ ។

ឧទាហរណ៍ : – ត្រីតាំងឡាយនៅក្នុងទឹក ។

៤.–«ក្នុង» ជាកាល, ជាពេល ។

ឧទាហរណ៍ . – ក្នុងសម័យនេះ យើងត្រូវនាំគ្នារៀនវេយ្យាករណ៍ខ្មែរទំនើប ។

៥.–«លើ, ឰដ៏, ត្រង់, នា» ជាទីរងទ្រផ្កាប់, ជាទីជ្រៀតជ្រែក ។

ឧទាហរណ៍ ៖ - ខ្ញុំអង្គុយលើគ្រែ ; បុរសនេះមានរោមពួងដី ទ្រូងឬត្រង់ទ្រូង ; ពពួកអមរស្ថិតនៅពេញផ្ទៃអាកាសវេហាស៍ ។

៦ - "នាកាល, កាលបើ, កាលដែល" ជាសេចក្ដីដែលគចូលប្រហែលជាបទប្រធាន ។

ឧទាហរណ៍ ៖ នាកាលព្រះអាទិត្យអស្ដង្គតទៅ ព្រះចន្ទរះឡើង ; កាលដែលខ្ញុំនៅពីកុមារនៅឡើយ ... ។

៧ - "និមិត្ត" ជាគ្រឿងចំណាំ-ជាហេតុ ។

ឧទាហរណ៍ ៖ ដំរីគេសម្លាប់និមិត្តភ្លុកវា (ព្រោះភ្លុក, ព្រោះតែភ្លុក) ។

៨.- «ជំនុំ, បណ្ដា» ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួម ដែលប្រមូលគ្នា ។

ឧទាហរណ៍ ៖ - ជំនុំឬបណ្ដាក្មេងទាំងឡាយនោះ ក្មេងម្នាក់នេះចេះគ្រាន់បើជាងគេ ។

៩.- «ជិត, ទៀប, ជាទីជិត, ប្រប ។

ឧទាហរណ៍.— ថៃ្ងទៀបអស្ដង្គត ។

## មេរៀនទី ២៩ :- អាលបនៈ

អាលបនៈ ជាពាក្យ សម្រាប់ប្រើជាសំដីស្រែកហៅ ឬពោលចំពោះ មានអាការៈដូចជាស្រែកហៅ ដូចពាក្យថា៖ « បពិត្រ , ម្នាល , នែ , ហៃ » តាមសេចក្ដីគោរពឬមិនគោរព ។

ឧទាហរណ៍.- ម្នាលកូនសម្លាញ់ ! កូនត្រូវខំរៀនឲ្យមែនទែនតាំងពីនៅក្មេង, បពិត្រមហាបពិត្រ, បពិត្រព្រះសម្ពុទ្ធ សូមព្រះអង្គគង់នៅអស់កាលវែង, នែ! កូនម្ដេចក៏មិនទៅសាលា, ហៃបុត្រ•ត្តម ចូរប្រាថ្នាខំ រៀនសិល្បសាស្ត្រ

បើខ្ជិលយ៉ាងនេះ នឹងចេះកាលណា យូរទៅគង់ជា ខ្ញុំគេពុំខាន; នែ! នាងទាំងឡាយមិនត្រូវធ្វេសប្រហែសក្នុងការរៀនវេយ្យាករណ៍ខ្មែរទំនើបនេះឡើយ ។

## មេរៀនទី–៣០

### និបាតសព្ទ( Préposition ?ou locution... ?)

និបាតសព្ទ ជាសព្ទសម្រាប់ផ្សំពាក្យសំដីត្រង់ឃ្លាល្បះនីមួយៗជាជំនួយដល់នាមសព្ទនិងកិរិយាសព្ទ ដើម្បីធ្វើប្រយោគសេចក្ដីជាប់ទាក់ទងគ្នា ឲ្យច្បាស់លាស់ពីរោះស្រួលស្ដាប់ ដូចជាពាក្យថា « ក៏, ក៏បាន, ក៏ដែរ, ដែរ, ក្ដី, ផង, ឯ, បើ, ទោះ, ទោះបី, បើទុកជា, ទើប, ពុំនោះសោត, កាល, លុះត្រាណា, លុះត្រាតែ, ព្រោះ, ដ្បិត...ជាដើម ។

និបាតសព្ទមានច្រើនយ៉ាងគឺ៖

១-និបាតប្រាប់កាល,ប្រាប់ពេល(កាលត្ថ-
ជោតក)

ពាក្យថា៖ គ្រានោះ, លំដាប់នោះ, ដងនោះ, កាលនោះ
ក្សណនោះ, ព្រឹក, អំពីព្រឹក, ថ្ងៃ, កន្លងវេលាថ្ងៃ, ល្ងាច,
ពេលល្ងាច, ម្សិល, ម្សិលមិញ, ពីម្សិលមិញ, ស្អែក, ខាន
ស្អែក, ខានស្អែកមួយ, អម្បាញ់មិញ, ភ្លាម, មួយរំពេច,
សឹង, តទៅ, កន្លងមុខ ។

២-និបាតប្រាប់ទី (ឋានត្ថជោតក)

ពាក្យថា៖ ខាងលើ, ខាងក្រោម, ខាងក្រោយ, ខាងក្នុង,
ខាងក្រៅ, ខាងមុខ, ចន្លោះ, រវាង, ស្ពាត, ទី, កំបាំង, កំ-
បាំងពីមុខ, ចំពោះមុខ, នៅមុខ, ឯមុខ, ឯគាយ, ខាងគាយ
ឯនាយ, ខាងនាយ ... ។ល។

៣.-និបាតប្រាប់សេចក្ដីកំណត់ (បរិច្ឆេទត្ថ-
ជោតក)

ពាក្យថាៈ-ប៉ុន្មាន , ប៉ុនណា , ផងណា , ផងនោះ - ត្រឹមណា , ត្រឹមនោះ , កំណត់ត្រឹមណា , កំណត់ត្រឹមនោះ , មានប្រមាណ , ប៉ុនណា . . ។

៤.- និបាតប្រាប់សេចក្ដីប្រៀបប្រដូច (ឧបមានុបមេយ្យត្ថវាចក)

ពាក្យថា ៖ ដូច , ដូចជា , បីដូច , ហាក់ដូច , ប្រដូច , ប្រហែលដូច , យ៉ាងណា , យ៉ាងណាមិញ , យ៉ាងនេះ , យ៉ាងនោះ , ដូច្នេះ , ដូច្នោះ , ដូចម្ដេចមិញ . . ។ល។ ។

៥.- និបាតប្រាប់ប្រការ (បការត្ថវាចក)

ពាក្យថា ៖ ម្ដេច , ដូចម្ដេច , ដោយប្រការដូចម្ដេច , ដោយប្រការយ៉ាងណា , ដោយប្រការយ៉ាងនោះ , ដោយប្រការដូច្នោះ . . ។ ល ។

៦.- និបាតប្រាប់សេចក្ដីឃាត់ , ហាម , ដាច់ - ខាត ( បដិសេធនត្ថវាចក )

ពាក្យថា៖ កុំ, ពុំ, មិន, មិនមែន, ឥត, ខាន, ពិត, មែន, តែប៉ុណ្ណោះ, គ្រាន់, មិនមែន, ពិតមែន, មែនពិត, វៀរលែង, វៀរលែងតែ, លើកលែងតែ, កុំឡើយ, ណ្ហើយ, ល្មមហើយ... ។ល។

៧.- និបាតប្រាប់សេចក្តីតាមឮ (អនុស្សវនត្ថវាចក)

ពាក្យថា៖ ឮថា, បានឮថា, ឮដំណឹងថា, តាមឮមកថា, មានដំណាលមកថា, មានសេចក្តីដំណាលមកថា... ។ល។

៨.- និបាតប្រាប់សេចក្តីជញ្ជឹង, រំពឹង, ប្រមើល, ស្មាន, ណាត់, (បរិកប្បត្ថវាចក)

ពាក្យថា៖ បើ, បើថា, បើជា, ប្រសិនបើ, តោះបើ, ល្គឹកតែ, បើដូច្នោះ, បើដូច្នេះ, ធ្វើម្តេច, ធ្វើម្តេចហ្ន៎, ធ្វើម្តេចអេះ, ប្រសិនជា... ។ល។

៩.- និបាតប្រាប់សេចក្តីសួរដណ្តឹង (បុច្ឆ-

ឆន្ទភាពគះ)

ពាក្យថា៖ ឬ, ឬក៏, ឬក្តី, ឬទេ, ដូចម្តេច, ដែរឬ, យ៉ាងដូចម្តេច, យ៉ាងណា, ទេដឹង, យ៉ាងណានេះ, តើ-ហ៎, ហ្ន៎ មែនឬ ... ។ល។

១០.- និបាតប្រាប់សេចក្តីឆ្លើយ-ទទួល (សម្បដិច្ឆន្ទភាពគ)

ពាក្យថា៖ តើ, ក្រ៎, បាទ, ប្របាទ, ប្របាទម្ចាស់, ករុណា, ករុណាពិសេស, ចះ, ចាះ, ពរម្ចាស់, មែ, ព្រះមែម្ចាស់, ចំរើនពរ, ថ្វាយព្រះពរ ... ។ល។

១១.- និបាតប្រាប់សេចក្តីតឿន (ឧយ្យោជឆន្ទភាពគ)

ពាក្យថា៖ ហ៎, លឿនឡើង, ឆាប់ឡើង, ឆាប់ៗ, (ដូចជាតឿន), ... ។ល។...

១២.- និបាតប្រាប់សេចក្តីច្រើនយ៉ាង (អ-

នេកត្ថាបទកា)

ពាក្យថា ៖ ក៏, ឯ, ផ្សិត, ក្តី, ផង, មួយ, ខ្លះ, ឬ, ពិត, មែន, ដែរ, សឹក, មែនពិត, ពីព្រោះ, ក៏ដោយ, ក៏បាន, មួយវិញទៀត, ពុំនោះសោត, ចំណែកខាង, ប៉ុន្តែ, ប៉ុន្តែថា, ដូចជា, ក្រែងតែ, ក្រែងលោ, ចុះបើ, ម្យ៉ាងទៀត ... ។ល។

១៣.-និបាតប្រាប់សេចក្តីគ្រាន់តែបំពេញបទ (បទបូរណត្ថាបទកា)

ពាក្យថា៖ ហ្ន៎, ហ៏, ហ:, យ៉ី, យើ, ៨! យ៉ីអើ!, យ៉ីអើហ្ន៎...។ល។...

១៤.-និបាតប្រាប់សេចក្តីផ្សេង (នានត្ថាបទកា)

ពាក្យថា មែន, ខុស, ទទេ, ទៀត, វិញ, ខ្ពស់, ទាប, ប្រាកដ, ដោយពិត, មួយវិញទៀត; ម្យ៉ាងវិញទៀត, ពន់ពេក, ក្រៃពេក, ក្រៃលែង, ក្រៃកន្លង, ពេកក្រៃ, រឿយៗ, ញយៗ,

សូម្បី, តាំងពី, តាំងពីដូច, សូម្បីតែ, ចាប់ដើម, តិចតួច កុហក, មួយគ្រា ជាក់លាក់, ពីចម្ងាយ, ក៏មែនហើយ, ម្ដង តិចៗ, សំរៀមៗ, ចុមៗ, មួយរយដង, មួយអន្លើ, ខ្លួនឯង, ...។ល។...

១៨.– និបាតប្រាប់សេចក្ដីក្រើនរំឭក ជាគល.បទៈ សម្រាប់អ្នកគ្មានតេជះទៅកាន់អ្នកមានតេជះ ឬ អ្នកមាន តេជះ ទៅកាន់អ្នកគ្មានតេជះ (គាលបទត្ដូចក)

ពាក្យថា នែ, នែអ្នក, នែហៅ, នែប្រស្ដែង, រ៉ឺ, រ៉ឺយ, អស់លោកទាំងឡាយ, នាង, គានាង, នែគា, នែគាចង្រៃ, នែហង់, នែមេចង្រៃ, នែអ្នកដ៏មានកាយ, នែអ្នកដ៏ចំរើន, បពិត្រព្រះករុណា, បពិត្រព្រះអង្គ, បាទព្រោស, សូមបាទមេត្តាព្រោស, សូមទ្រង់មេត្តាព្រោស, សូមព្រះតេជះ, សូមព្រះតេជះដ៏កល់លើត្បូង (តាមថ្នាក់ទាប, កណ្ដាល, ខ្ពស់)..។ល។...

## មេរៀនទី៣១:–ឧទានសព្ទ ( interjection )

សព្ទដែលត្រាប់សូរសម្លេង ឬ ជាសម្លេងភ្ញាក់មាត់ដោយភ្ញាក់ផ្អើល ដោយសេចក្ដីតក់ស្លុតញាប់ញ័រខ្លះ ឬ មានសេចក្ដីត្រេកអរត្រេកពេក ជាសម្លេងមិនមែនជាភាសាខ្លះ ហៅថា "ឧទានសព្ទ" "ដូចជាពាក្យថា៖, អ៊ា!, អ៊ូយ!, ចុះ!, ត្រាំង!, ក្លឹង!, ប្រិបៗ!, ប៉ក់ៗ!, កាបៗ!, ចុបៗ!, ហោៗ!, ទូងៗ!, ខ្ទុកៗ!, វ៉ែកៗ!, យ៉ី!, យ៉ីអើ!, ហ៊ូ!, ធុ!, ពុទ្ធោ!. កម្រោសអ៊ុំមេះ! អុញ្ញាន!... ។ល។ ...

## មេរៀនទី៣២:–បរិវារសព្ទ

មានពាក្យខ្លះឥតសព្ទប្រែ សំរាប់តែបន្ថែមសំដី ពាក្យ

ទាំងនោះ ហៅថា "បរិវារសព្ទ" ។

បរិវារសព្ទ ជាធម្មតា សម្រាប់ភ្ជាប់នឹងនាមឬនឹងគុណ-នាមមានលំនាំដូច អតិវិសេសគុណនាម ។ ពាក្យទាំងនោះគឺ៖ ក្មេងក្មាង, ចាស់ទុំ, មនុស្សម្នា, ផ្ទះសម្បែង, បានក្បាន, ស្ងួស្ងុក, សត្វពាត់, ទំនែក, ស្គុសស្គាយ, ក្មេង-ក្មាត់, ប្រសប់ប្រសូន, ចំណីចំណុក, ដំបងព្រនង់, ថ្នាំសង្កូវ, ស្មៅព្រៅ, ព្រៃផ្សៃ, អម្រេសអម្រ, ម៉េះម៉ា, ឆ្អឹងឆ្អែង, យួនព្រួន, ចិនព្រិន, ស្រាហ័សាញ់, ស្គោកស្គាំង, គោអំពែ, សេះអំពែះ, រំដេករំដាក, រំយេករំយាក, រគេក-រគូក, រកេករកូក, រយើរយៃ, រញេរញ៉ារ, ទទឹទទ័រ, បន្ទុ-បន្ទារ, ផ្សូវផ្សា, អីអ៊ែអ៉ាន់ ។ល។ ...

## មេរៀនទី ៣៣:- នាមក្រិត-កិរិយាក្រិត

ពាក្យជាកិរិយាសព្ទមួយម៉ាត់ ឬ ពាក្យជាគុណសព្ទមួយម៉ាត់ ដែលយារចេញពីពាក្យដើម ឬ បែកចេញពីពាក្យដើម ក្លាយទៅជានាមសព្ទដោយអំណាចអពាស ហៅថា " ក្រិតៈ ឬ ក្រិត " ។

មាន ២ យ៉ាងគឺៈ ក្រិតនាម ឬ នាមក្រិត ១ និងកិរិយាក្រិត ១ ។

ក- ក្រិតដែលជា នាមសព្ទ ដូច កំណើត, កំណប់, ដំហារ, ចំណង, ទំនិញ, សំណាង, ចំណង់ . . . ជាដើម ហៅថា ក្រិតនាម ឬ នាមក្រិត ។

ខ- ក្រិតដែលជាកិរិយាសព្ទដូច កើត, កប់, ឈរ, ចង, ទិញ, សាង, ចង់... ជាដើមហៅថា កិរិយាក្រិត ។

## កិរិយាក្រិត

ក្រិតដែលជាកិរិយាសព្ទ ឬ កិរិយាសព្ទ ដែលគេបក្លាយចេញទៅជានាមសព្ទបានដោយអំណាច អក្សរ ដូចជាជូន> ជំនួន; គួរ> គំនួរ; សាប > សំណាប; ពួស> ផួស; ពួត <ពំនួត; បៀរ > បំណៀរ, បេះ > បំណេះ, ដើរ > ដំណើរ, ដេក> ដំណេក, កល់ > កំណល់, សល់ > សំណល់, គុំ > គំនុំ. ឃ្លាន > គំលាន ; កើត > កំណើត ; កេណ្ឌ > កំកេណ្ឌ ; ហោច > បំណាច ; ទឹង > កំហឹង ; សួរ > សំនួរ ; ស្បថ > សំបថ ; សែន > សំណែន ; សើច > សំណើច ; ស្រែក > សម្រែក... លើកតែពាក្យខ្លះដែលវេយ្យាករណ៍មានអព្យាស្រ័យឲ្យប្រើ ដូចពាក្យថា ៖ ដើរ > ថ្មើរ ; ដេរ > ថ្នេរ; ត្រង់ > តម្រង់ ឬ ដម្រង់ ; ត្រូវ > តម្រូវ ឬ ដម្រូវ ; ប្រជុំ > ផ្ដុំ...ជាដើម ហៅថា " កិរិយាក្រិត " ។

កិតនាមខ្លះជាកិរិយា ជាក់ជានាម ដូចពាក្យ៖ផ្លូវដើរ,

អ្នករក, អ្នកសែន, អ្នកលី, អ្នកដេក, អ្នកទៅ, អ្នកមក, អ្នកបេះ, អ្នកនៅ, អ្នកខ្ចី... សឹងជាកត្តុនាម ។

កិរិយាក្រិតនោះឯង តែងតែបកក្លាយទៅជា នាមសព្ទនោះ បានតែជា "ការណនាម"( Nom d'action)គឺ "ឈ្មោះអំពើដែលគេត្រូវធ្វើ" មិនអាចក្លាយទៅជា "ការកនាម" ឬកត្តុនាម(Nom d'agent)(គឺ "ឈ្មោះអ្នកធ្វើនូវអំពើ")នោះឡើយ

កិរិយាសព្ទដែលមិនក្លាយចេញទៅជានាមសព្ទ ដោយអំណាចអក្ខរាស មិនហៅថា ការិយាក្រិតទេ ដូចពាក្យ "ចំរើន, សរសើរ, សរសេរ, ទន្ទេញ, រៀនសូត្រ, សិក្សា, ស្ដាប, ផឹក, ស៊ី, ... ជាដើម បើត្រូវការបង្កើតកិរិយាសព្ទនោះក្លាយចេញទៅជានាមសព្ទត្រូវបន្ថែមពាក្យ "សេចក្ដី, ការ" ពីខាងដើមកិរិយាសព្ទនោះជាជំនួយថែមទៀត ទើបទៅជានាមសព្ទតាមចំណង់បាន ។

ឧទាហរណ៍ .- សេចក្ដីចំរើន, សេចក្ដីសរសើរ, ការសរសេរ,

ការទន្ទេញ, ការរៀនសូត្រ, ការសិក្សា,. សេចក្ដីស្លាប់, ការផឹក, ការស៊ី ... ជាដើម ។

កិរិយាសព្ទក្ដី គុណនាមក្ដី ដែលនឹងក្លាយចេញទៅជានាមសព្ទ ឬ កិរិយាសព្ទបាន លុះតែធ្វើដោយអំណាចអក្សរ ។

## មេរៀន ទី៣៤:-អាគម

អាគម គឺជាអក្សរដែលចុះថែមមកត្រង់ចន្លោះពាក្យដែលជាបាលីដូចជាពាក្យថា ចតុរង្គ, និរន្តរ, បរិយោសាន, ចតុរា-រិយសច្ច.. ; ចតុរារិយសច្ច មកពីចតុ + អរិយសច្ច ចុះរថែមមកជា ចតុរ ហើយធ្វើ អ ជា អា > ចតុរារិយសច្ច ។ ចតុរង្គ មកពី ចតុ + អង្គ ចុះរ មកជា ចតុរ + អង្គ > ចតុរង្គ ។ និរន្តរ មកពី និ + អន្តរ ចុះរថែមមកជា និរ + អន្តរ > និរន្តរ ។ បរិ-

យោសាន មកពី បរិ + ឱសាន ចុះ យ ថែមមកជា បរិយ + ឱសាន > បរិយោសាន។ អក្សរ "រ-យ" ដែលចុះថែមដើម្បីស្រួលសព្ទមាន ហៅថា អាគម ។

## សន្ធាន ( Conjonction )

និបាតសព្ទ សម្រាប់ប្រើបន្ទាក់សេចក្តីដោយឡែកក្នុងប្រយោគនីមួយ ៗ ដូចជា "ពុំនោះ, បើពុំនោះ, ពុំនោះសោត ..ជាដើម ហៅថា "សន្ធាន" ប្រែថា "ការត, ការបន្តភ្ជាប់, ការធ្វើឲ្យមូលគ្នា" ។

ឧទាហរណ៍. ការនេះត្រូវតែចាត់បំរើម្នាក់ឲ្យទៅប្រាប់ផ្តាំផ្ញើនឹងមនុស្សអ្នកទៅមក, ឬក៏សរសេរសំបុត្រឲ្យបំរើយកទៅ, ពុំនោះផ្ញើនឹងគេអ្នកទៅមក ពុំនោះសោតបិទតែមប្រើផ្ញើតាមប្រៃសណីយ៍ក៏បាន ។

## មេរៀនទី៣៩..សមាស

នាមដែលបំប្រួញបទតាំងពីពីរពាក្យឡើងទៅ ឲ្យជាប់គ្នាតែមួយ គឺបន្តពាក្យមុខបទមួយផ្សេងទៀតរួមជាពាក្យមួយម៉ាត់ ហៅថា «ពាក្យសមាស» ។

ពាក្យសមាស ជានាមគួបគ្នាដោយនាមនឹងនាមក៏មាន ដោយនាមនឹងគុណនាមក៏មាន, ដោយនាមនឹងកិរិយាក៏មាន ដោយកិរិយានឹងកិរិយាក៏មាន ។ ពាក្យសមាស ហៅថា

សមាសនាម(Nom composé)

សមាសនាម មានពីរយ៉ាងគឺៈ សមាសនាមបាលី១, សមាសនាមខ្មែរ១ ។ នៅសមាសនាមបាលី បើកាលណាពាក្យដែលយកមកភ្ជាប់ជាពាក្យកើតឡើង អំពីស្រៈពេញតួ ត្រូវផ្លាស់ស្រៈនោះជាស្រៈនិស្ស័យ ។ ហើយភ្ជាប់មកជាមួយព្យញ្ជនៈនៃបទខាងមុខ ដូចជា គជ+ឥន្ទ្រ > គជេន្ទ្រ, កុមារ+ឥន្ទ > កុមារិន្ទ; រាជ+វង្ស+អនុវង្ស > រាជវង្សានុវង្ស,

សមាន: + អនុភាព > សមានានុភាព; សកល: + លោក > សាកលលោក; រាជ: + សម្បត្តិ > រាជសម្បត្តិ; កម្ពុជ + រដ្ឋ > កម្ពុជរដ្ឋ; ប្រវត្តិ + សាស្ត្រ > ប្រវត្តិសាស្ត្រ; វីរយ: + ភាព > វីរិយភាព ... ជាដើម ។

សមាសនាមខ្មែរទាំងឡាយគឺ៖ សៀវភៅសរសេរ, ដបទឹកសរសេរ, សៀវភៅមើល, សត្វគោរាត, គោសៀម, ក្រដាសផ្ដិត, ក្រដាសខាត់, ក្រដាសប៉ុយ, ជើងម៉ា, កណ្ដុ-ចិន, ពពេចផ្កា, ពស់វែកទាម, ពស់វែកក្របី, ត្រីបង្កា-ក្យៀង, ដង្កូវនាង... ជាដើម ។

## មេរៀនទី៣៦:- សមូហនាម ( Nom collectif )

នាមនាមប្រាប់សេចក្ដីប្រជុំ, ប្រមូល, រួបរួម ដូចជាពាក្យ៖ ពួក, បន, ក្រុម, ហ្វូង, ប្រជុំ... ជាដើម ហៅថា

" សម្មាធាម " ។

ឧទាហរណ៍ ៖– ពួកចត្បួន ពុំមែនមានសុខតែស្គតនោះទេ មានការបរិហារ ខះដៃ ដូចជា ខា, ជ័រព្រៃ, ជ្រូកព្រៃជាដើម ។ ពួកនៃអ្នករៀន, ប្រជុំនៃជនានុជន, បទនៃអ្នកសីផក ។

## មេរៀនទី៣៧ ៖– ឧបសគ្គ ( Obstacle? )

ឧបសគ្គ ជាពាក្យសព្ទ (ពាក្យមិនផ្លាស់ប្តូររូបទីសព្ទ Invariable ) សម្រាប់ប្រើចំពោះតែបុព្វបទ រៀនភ្ជាប់ពីខាងដើមនាមសព្ទនិងកិរិយាសព្ទតាមគួរដល់ការប្រកប មានចំនួនតែ ២០ សព្ទប៉ុណ្ណោះគឺ ៖

អតិ ប្រែថា កន្លង, ក្រៃពេក, ពន់ពេក, លើសលែង, ហួសពេក, បំផុត, ណាស់ ...

ឧទាហរណ៍៖— អតិបណ្ឌាល (កាចក្រៃពេក), អតិជាតបុត្រ (កូនប្រសើរជាងឪ), អតិពាល (ក្មេងណាស់, ល្ងង់ពេក). អតិមូល (ថ្លៃហួសពេក), អតិក្រិស (ស្គមណាស់), អតិទារុណ (គគ្រោកក្រៃ, កាចឆ្នើម), អតិសុខុមាល (ដែលធ្លាប់តែស្រណុកក្រៃពេក), អតិសោភ័ណ (ល្អក្រៃង)... អតិកល្យាណ ។

អធិ ប្រែថា ក្រៃ, ក្រៃលែង, ក្រៃពេក, លើសលប់, លើសលែង, សន្ធឹក ។

ឧទាហរណ៍.— អធិជ័យ (ជ័យលើសលប់), អធិការ, អធិបតី, អធិពជ ។

អនុ ប្រែថា តាម, តូច, បន្ទាប់, រង, ក្រោយ, បណ្ដោយ, លំដាប់ ..

ឧទាហរណ៍,- របៀបអនុក្រម (លំដាប់ពាក្យ), អនុគ្រោះ (ការជំនួយទំនុកបំរុង), អនុចិន្តា (ការគិតតាម), អនុជ (ប្អូន), អនុញ្ញាត (យល់ព្រម), អនុទិន

(ថៃ្ងបន្ទាប់), អនុវត្ត (ប្រព្រឹត្តតាម, ធ្វើតាម), អនុប្រធាន, កជានុសិទ្ធ, អនុថេរ ។

អភិ ប្រែថា ក្រៃពេក, លើសលែង, ឆ្ពោះ, ចំពោះ, ខាងមុខ...

ឧទាហរណ៍៖– អភិក្រោធ (ក្រោធខ្លាំង); អភិជ័យ (ជំនះយ៉ាងសំបើម), អភិញ្ញាតជន (ជនដែលគេស្គាល់ច្រើន), អភិតរុណ (ក្មេងណាស់, ខ្ចីណាស់), អភិនន្ទ (ត្រេកអរខ្លាំង), អភិនន្ទន៍ (អំណរខ្លាំង), អភិបាល. អភិជន, អភិមង្គល ។

អប ប្រែថា ប្រាសចាក, ឃ្លាតចាក, ចៀស, គេច, ត្រឡប់ជា,

ឧទាហរណ៍៖– អបគ្រម (ការគេចចេញ). អបគមន៍ (សេចក្តីព្រាត់ប្រាសគ្នា), អបទ្រព្យ (ទ្រព្យមិនល្អ, របស់ក្លែង), អបមង្គល (ឥតសេចក្តីចំរើន), អបលក្ខណ៍ (ហីនលក្ខណ៍, ខាតលក្ខណ៍)... អបទោស, អបទ្រូព, អបយស ។

អបិ ឬ បិ ប្រែថា ជិត, ខាងលើ...

អវ ឬ ឱ ប្រែថា ចុះ, ចុះក្រោម, ទាប, ស្រប...

ឧទាហរណ៍៖– អវជាតបុត្រ (កូនក្រៅគន្លងធម៌),

អវសាន (ទីបំផុត, ចុងបំផុត), អវជ័យ...

អា ប្រែថា ទូទៅ, សព្វ, ក្រៃលែង...

ឧ ប្រែថា ឡើង, ខ្ពស់, ក្រៅ,...

ឧប ប្រែថា ជិត, ចូលទៅជិត, មាំ, ស៊ប់...

ឧទាហរណ៍៖– ឧបរាជ, ឧបនាយក, ឧបរដ្ឋមន្ត្រី, ឧបទូត,

ឧបត្ថម្ភ, ឧបករណ៍, ឧបនិស្ស័យ, ឧបជ្ឈាយ៍...

ទុ ប្រែថា អាក្រក់, ក្រ, កម្រ, លំបាក, ពិបាក..

ឧទាហរណ៍៖– ទុគ៌ត, ទុព៌ល, ទុគ៌ម, ទុច្ចរិត, ទុក្ករកិរិយា,

ទុជ៌ន, ទុល្លភាព, ទុកតារ, ទុក្ភាសិត...។

និ ប្រែថា ចេញ, មិនសល់, មិនមាន, ឥត..,

ឧទាហរណ៍៖– និរគុណ, និរទោស, និរន្តរ, និរភ័យ...

នី ប្រែថា ចេញចូល, ចុះ...

ប ប្រែថា ទូទៅ, ខាងមុខ, ចេញ, មុន..,

បដិប្បតិ ប្រែថា ចំពោះ, តប, ត, ប្រាស, ត្រឡប់...

ឧទាហរណ៍— បដិការ, បដិទិន, បដិលោម, បដិសណ្ឋារៈ ។

បរា ប្រែថា ខាងមុខ, សាបសូន្យ, ចាញ់,

ឧទាហរណ៍ៈ— បរាជ័យ, បរាភព, បរាមុខ ... ។

បរិ ប្រែថា ជុំ, ជុំវិញ, គ្រប់គ្រាន់, ស្រេច, ។

ឧទាហរណ៍ៈ— បរិវេណ, បរិមណ្ឌល, បរិនាយក ... ។

វិ ប្រែថា ផ្សេង, ថ្លែក, ច្បាស់, ជាក់, ប្រាកដ... ។

ឧទាហរណ៍ៈ— វិកាល, វិបរិត, វិជ្ជា, វិតក្ក, វិចារណញ្ញាណ, វិសាល ... ។

សំ ប្រែថា ព្រម, ជាមួយ, ល្អ, ប្រពៃ, ...

ឧទាហរណ៍ៈ— សន្និសីទ, សន្និបាត, សម្ពន្ធ, សម្បទា, សម្បទាន, សម្បុណ្ណ, សម្បត្តិ, សម្បជញ្ញៈ, សំសន្ទនា ... ។

សុ ប្រែថា ងាយ, ស្រួល, ស្រណុក, ល្អ, ប្រពៃណាស់,

*ម៉ុះ, ស៊ីម៉ុះ ..*

ឧទាហរណ៍— *សុគតិ, សុវិជ្ជា, សុគន្ធ, សុចរិត, សុវណ្ណ, សុពណ៌, សុភា, សុចិន្តា, សុភាសិត...*



## មេរៀនទី៣៨ :- វេវចនៈ : (SYnonYme)

ពាក្យដែលប្រើផ្លាស់ប្តូរគ្នា ឬជំនួសគ្នាបាន គឺពាក្យដែលមានសូរសំឡេងខុសគ្នា តែមានសេចក្តីត្រូវគ្នាឬប្រហៀលគ្នា ដូចពាក្យថា «ពេស្យា, វេសិយា, វេសី, នគរសោភិនី, លញ្ឆិកា, រូបជីវនី, រូបជីវា, រូបូបជីវិនី, វណ្ណទាសី, គណិកា, សំពឹង, ស្រីពិនពាង, ស្រីបន, ស្រីពេងផែង, ស្រីផ្កាមាស» ពាក្យទាំងអស់នេះបានសេចក្តីដូចគ្នា ប្រើពាក្យណាក៏បាន តាមសមគួរដល់ការលៃលក ហៅថា «វេវចនៈ»។

## សទិសសព្ទ (HomonYme homophone)

ពាក្យដែលមានសព្ទដូចគ្នា តែបានសេចក្តីខុសគ្នា ដូចជា កា (កាទឹក), កា (កាខ្នងសំបុត្រ, កាស្រោមសំបុត្រ), ការណ៍ (ទាស់ការណ៍), គឺមានសូរសំនៀងត្រូវគ្នា តែសរសេរខុសគ្នា ហើយមានន័យក៏ផ្សេងពីគ្នាដែរ ហៅថា

" សទិសសព្ទ " ។

## សទិសនាម (HomonYme homographe)

ពាក្យដែលមានសព្ទដូចគ្នា ហើយទាំងរូបពាក្យក៏ដូចគ្នា តែបានសេចក្ដីផ្សេងពីគ្នា ដូចជា កោះ (ដីកោះ) កោះ (ក្អែកកោះអណ្ដើក), កោះ (កោះសរជម្រង់), កោះ (យកស្ករទៅកោះទឹក), កោះ(ក្បឿនកោះជាប់នឹងដៃវណ្ណ), កោះ(កោះកុង, កោះអន្ទង់ចិន), កោះ (កោះមាន់, កោះតា, គឺមានសូរសំនៀងក៏ត្រូវគ្នា ហើយរូបពាក្យក៏ដូចគ្នា តែមានន័យផ្សេងពីគ្នា ហៅថា " សទិសនាម " ។

## មេរៀនទី ៣៩ :- អញ្ញត្រសព្ទ

អញ្ញត្រសព្ទ ប្រែថា „សព្ទដោយឡែក„ គឺពាក្យខ្លះដែលសរសេរខុសពីរបបប្រើ អក្សរខុសពីសម្លេង ទុកជាយ៉ាងណាក៏ដោយ គឺត្រូវតែរក្សារបបដើមទុកឲ្យគង់នៅ ដូចជា៖ ស្ដេច, ស្រេច, សម្ដេច, សេចក្ដី, នេះ, នោះ, ដូច្នេះ, ដូច្នោះ, អញ, អ្នក, ហោង . . . ជាដើម ដែលមានសម្លេងជា ស្ដាច់, ស្រាច់, សម្ដាច់, សាច់ក្ដី, និះ, នុះ, ដូចនិះ, ដូចនោះ, គាញ់, នាក់, អ្ហង, យ៉ាងនេះហៅថា អញ្ញត្រសព្ទ ។

ក្នុងភាសាខ្មែរ ពាក្យដែលសរសេរខុសពីរបបប្រើអក្សរ ឬខុសពីសម្លេងនិយាយនោះច្រើនតែស្រៈ „អេ„ ដែលប្រ-កបនឹងខ្យល់អក្សរក្នុង បរិវគ្គ ដូចជា៖ គ្រេច, ម្រេច, ភ្លេច, ម្ដេច, លេច, វេច, ពេជ្រ, ទន្ទេញ, វេញ, . . . ជាដើម។

## ការឆ្ដសព្ទ

សព្ទដែលមានស្រៈជាទីបំផុតនៃអក្សរៈដូចគ្នា ដូចពាក្យជា៖ កញ្ញា, កថា, បញ្ញា, ប្រាជ្ញា, វាចា, សាលា, សុណិសា, ភាសា, វណ្ណា, អត្ថា... ជាដើម យ៉ាងនេះ "ការឆ្ដសព្ទ" ។

## សន្តានពាក្យ (Famille des mots)

ពាក្យដែលជាបង្កោម ឬបុសតែមួយ ដូចជាពាក្យថា៖ ដឹង > បណ្ដឹង, ដំណឹង, ប្ដឹង, គឺចេញពីធាតុតែមួយ ហៅថា "សន្តានពាក្យ" ។

## ធាតុ (Racine)

មូលដើមនៃពាក្យខ្លះ ដូចយ៉ាង "ធរណី" ផែនដី មកពី

ជរ=ទ្រុឌទ្រោម. កម្ម "អំពើ" មកពី ករៈ "ធ្វើ" ធ្វើ, ការ, នេះជា "ធាតុ" ។

## បុព្វបទ (Préfixe)

អ (សំរាប់បដិសេធ).– សព្ទ "អ" ជាសព្ទបម្រាប់បដិសេធ ។ "អ" បដិសេធនេះសម្រាប់ភ្ជាប់ពីមុខសព្ទដទៃ ជាសេចក្ដីមានន័យថា "ពុំ, មិន, ឥត, គ្មាន, មិនមែន" ដូចពាក្យថាៈ "អកតញ្ញូ, អភ័យ, អមនុស្ស, អមតៈ, អធម៌, អយុត្តិធម៌, អកុសល, អផល, អធម្មិក, អគោចរ, អនត្ត... ជាដើម ។

"អ" បដិសេធនេះប្រើជា បុព្វបទ ហៅ "អ" បុព្វបទ ។

បុព្វបទ គឺនិបាតសព្ទឬអក្សរដែលដាក់ភ្ជាប់ពីខាងដើមនៃសព្ទឯទៀត, ជាជំនួយសព្ទនុះ ឲ្យមានសេចក្ដីប្លែកដោយឡែក ឬបំបែកសេចក្ដីឲ្យឃ្លាតឆ្ងាយពីប្រក្រតីដើម ។ បុព្វបទ

ដែលមានកំណើតពាក្យជាភាសាខ្មែរនោះគឺៈ ក, ប-ង, ប-ញ, ប-ណ, ប-ន, ប-ម ឬ បំ, ញ, ន, ។ បុព្វបទទាំងនេះ មានន័យថា "ឲ្យ.. ធ្វើឲ្យ .." ដូចពាក្យថា គ+គាយ > គគាយ, បង់+ខូច > បង្ខូច, បង់+ខុស > បង្ខុស, បង់+ខាត > បង្ខាត, បង់+ហិន > បង្ហិន; បង់+ហើរ > បង្ហើរ; បង់+វិល > បង្វិល; បង់+រៀន > បង្រៀន ... ។ល។

- បញ+ចូល > បញ្ចូល; បញ+ចេញ > បញ្ចេញ; បញ+ឈរ > បញ្ឈរ; បញ+ឈប់ > បញ្ឈប់, បញ+ឆោត > បញ្ឆោត ... ។ល។

- បណ+ដេញ > បណ្ដេញ; បណ+ដុះ > បណ្ដុះ, បណ+ដាល > បណ្ដាល, វៀរលែងតែពាក្យខ្លះ បណ្ដាក់, បណ្ដា, បណ្ដូល, បណ្ដោយ, បណ្ដោះអាសន្ន, នឹងបណ្ដាំ ។

- បន់+ត > បន្ត, បន+តឹង > បន្តឹង, បន+ថយ >

បន្ថយ , បន + ថែម > បន្ថែម, បន + ថោក > បន្ថោក ...។ល។

ទៀតលើសតែពាក្យ បន្តក់, បន្តោក, បន្តុច, បន្តឹង (បន្តឹងទន្សាយ), បន្ថើរ, បន្ទាយ , បន្ទារ, បន្ទាល់, បន្ទឹង, បន្ទុក, បន្ទូល, បន្ទោ, បន្ទោបង់, ... ។ល។

- បំ + ពោល > បំពោល, បំ + បែក > បំបែក, បំ + ពាក់ > បំពាក់, បំ+ភ័ន្ត > បំភ័ន្ត, បំ+ភ័យ > បំភ័យ ... ។ល។

— ញញាក់ញញ័រ, ញញីញញ័រ, ញញើតញញើម ...។ល។

- ទទ្រេតទទ្រោត, ទទឹមទទាម, ទទឹសទទាស ... ។ល។

ក្នុងភាសាខ្មែរយើង បុព្វបទនេះជួនកាលក៏ប្រើមួយត្រួត ក៏មាន ជួនណាជាពីរត្រួតក៏មាន ។

បុព្វបទទាំងនេះមានន័យថា "ធ្វើឲ្យ" -

<u>បំណាំ</u> — "ប" បុព្វបទដាក់ខាងដើមពាក្យក្នុងកវគ្គ ក្លាយទៅជា ប-ង ដូចពាក្យៈ ខំ > បង្ខំ; កាច់ > បង្កាច់; កាត់ > បង្កាត់; ខូច > បង្ខូច, ។

"ប" បុព្វបទដាក់ខាងដើមពាក្យក្នុង ចវគ្គ ក្លាយទៅជា ប-ញ

ដូចពាក្យ៖ ចេញ > បញ្ចេញ, ចូល > បញ្ចូល, ឈប់ > បញ្ឈប់, ចេះ > បញ្ចេះ ។

"ប" បុព្វបទដាក់ខាងដើមពាក្យក្នុង ដវគ្គ ក្លាយទៅជា ប-ណ

ដូចពាក្យ៖ ដុះ > បណ្ដុះ, ដេញ > បណ្ដេញ ,

"ប" បុព្វបទដាក់ខាងដើមពាក្យក្នុង តវគ្គ ក្លាយទៅជា ប-ន

ដូចពាក្យ៖ ត > បន្ត, តឹង > បន្តឹង, ថយ > បន្ថយ, ថែម > បន្ថែម, ទន់ > បន្ទន់, ធូរ > បន្ធូរ ។

"ប" បុព្វបទដាក់ខាងដើមពាក្យក្នុង បវគ្គ ក្លាយទៅជា ប-ម ឬ បំ ដូចពាក្យ៖ ពៅ > បំពៅ, ពុល > បំពុល, ពាក់ > បំពាក់, ពង់ > បំពង់, ។

គេនិយមប្រើ "បំ" ជាង "បម" ។

## មេរៀនទី៣៧:– វិបត្តិនៃស្រៈ

វិបត្តិនៃស្រៈដែលយើងយកមកពោលក្នុងមេរៀននេះគឺសំដៅត្រង់វិបត្តិនៃសូរសាស្ត្ររបស់ស្រៈតែប៉ុណ្ណោះ ដូចជា៖

ឥ អានថា អ៊ិ ឧទាហរណ៍៖ ឥត, ឥដ្ឋ, ឥន្ទ. ឥន្ទធនូ, ឥន្ទជិត, ឥណ្ឌៀ, ឥណ្ឌូចិន, ឥន្ទនិល, ឥន្ទវង្ស, ឥន្ទ្រីយ, ឥន្ទ្រី, ឥរិយាបថ, ឥន្ទ្រជិតចន្ទ ឬ ឥន្ទ្រជិត... ។ល។

ឥ អានថា អ៊ី ឧទាហរណ៍៖ ឥសី, ឥសូរ, ឥឡូវ, ឥឡូវនេះ ។

ឥ អានថា អិ ឧទាហរណ៍៖ ឥស្សរ, ឥធលោក, ឥណ, ឥទ្ធានុភាព, ឥទ្ធិ, ឥដ្ឋារម្មណ៍, ឥដ្ឋាការ... ។ល។

ឫ អានថា អ៊ឺ ឧទាហរណ៍៖ ឫសធរ. ឫស, ឫសាន, ឫសូរ: (វៀរលែងតែពាក្យ ឫសូរ អានថា ឥសូរ) ។

ឧ អានថា អ៊ុ ក្នុងពាក្យខ្មែរ ឧទាហរណ៍៖ ឧក ឬ អុក, ឧកញ៉ា,

ឧកហ្វ៊ង, ឧស ។

ឩ អានថា អ៊ូ ក្នុងពាក្យបាលីឬសំស្ក្រឹត ឧទាហរណ៍៖ ឧកាសៈ, ឧក្រិដ្ឋ, ឧគ្ឃោសនសព្ទ, ឧត្តារៈ, ឧណ្ណាលោម, ឧតុង្គ, ឧដង្គឧត្តម, ឧទកៈ, ឧទាហរណ៍, ឧទុម្ពរ, ឧទ្ទិស, ឧទ្យាន, ឧបករណ៍, ឧបការី, ឧបការៈ, ឧបជ្ឈាយ៍, ឧបត្ថម្ភ, ឧបទ្រព, ឧបនិស្ស័យ, ឧបមា, ឧរ, ឧសភា, ឧស្សាហកម្ម, ឧឡារិក ... ។ល។ ...

ឪ អានថា អ៊ើវ មានប្រើក្នុងពាក្យខ្មែរតិចណាស់ដែរទេ ដូចជា ឪ, ឪជំ, ឪជ្រឹង, ឪណាល, ឪទិន, ឪពុក, ឪម៉ាល់, ឪឡ, ឪឡឹក, ឪឡុង, ឪឡោក ។

ឫ មានប្រើក្នុងពាក្យខ្មែរសុទ្ធតែ ៦ ម៉ាត់ទេ គឺ ឫក, ឫកពា, ឫស, ឫសដី, ឫសដូង, ឫស្សី ។ ក្រៅពីនេះប្រើនតែពាក្យក្លាយមកពីពាក្យសំស្ក្រឹត ដូចជា ឫក្ស, ឫក្សពារ, ឫគ្វេទ, ឫទ្ធិ, ឫទ្ធានុភាព, ឫសកៈ, ឫសី, ឫសីប៉ូរសារ, ឫស្យា . . ។ល។

ឬ នេះឃើញមានប្រើជានិបាតសព្ទ សំដែងសេចក្ដីសង្ស័យ , មិនប្រាកដ , មិនដាច់ស្រេច , មិនអស់មិនហើយ ។

ឧទាហរណ៍៖ មិនមែនទេឬ? មែនឬមិនមែន ? មាស ឬ ប្រាក់? ដែរឬ ?

ឭ ឃើញមានប្រើក្នុងភាសាខ្មែរតែ២ម៉ាត់ទេគឺ រឭក និង រំឭក។

ឮ ប្រើជាកិរិយាសព្ទ ដូចជាពាក្យថា៖ នៅក្រៅនេះ ខ្ញុំឮសូរ សព្ទបម្រៀងដ៏ពីរោះ ,

ឯ ឲ្យអានថា "អេ" ដូចជាពាក្យថា ៖ ឯកជន , ឯកច្ឆន្ទ , ឯក- ទេស , ឯករណ៍ , ឯកស័ក , ឯរ៉ , ឯកប្បហារ... ។ល។

ឯ ត្រូវអាន "អែ" ឧទាហរណ៍: ឯ, ឯណា , ឯណោះ , ឯណេះ ឯក , ឯកឧត្ដម , ឯកអគ្គរាជទូត , ឯកអគ្គ ឯកឯង ។

ឱ្យ មានប្រើក្នុងពាក្យខ្មែរសុទ្ធតែមួយម៉ាត់ គឺ "ឮ" ក្រៅពី នេះសុទ្ធតែជាពាក្យក្លាយមកពីសំស្រ្កឹត ដូច ឧទាហរណ៍: ឮករណ៍ , ឮសូរ ...

មានប្រើគុណពាក្យខ្មែរសុទ្ធប្រហែលជា ៦-៧ ម៉ាត់ប៉ុណ្ណោះ ឱ៎, ឱត, ឱន, ឱប, ឱ្យ, ឱហាត, ឱះ ៗ ក្រៅពីនេះ សុទ្ធតែជាពាក្យឃ្លាតក្លាយមកពីបាលី ឬសំស្ក្រឹត ដូចជា ឱកាស, ឱង្ការ, ឱសថ, ឱង្ការ, ឱជារស, ឱដ្ឋៈ, ឱភាស ឱរ៉ទ, ឱរស, ឱស្ឋ, ឱក ... ។ល។

គុណពាក្យខ្មែរ ក៏មានចំណាស់អាន និង ចំណាស់ធម្មជាតិរបស់ពាក្យដែរ ឧបមាដូចពាក្យ «ពិត, ពឹត; មិន, មឹន...» ការប្រើស្រៈ ិ និង ឹ ។

ពាក្យកើតពីស្រៈ ឹ និងប្រើជាដាច់ស្រេចនូវពាក្យដែលមានអក្សរ «ង» ជាប្រគប និងពាក្យក្លាយចេញពី «ឫ» ដូចជាពាក្យម្រឹគ ក្លាយពីម្ឫគ; ព្រឹក្ស ក្លាយពីវ្ឫក្ស; គ្រឹត្យ ក្លាយពីក្ឫត្យ; ល។ មានពាក្យខ្មែរសុទ្ធកើតពីស្រៈ ឹ ហើយមានអក្សរផ្សេងក្រៅពី «ង» ជាប្រគប ដូចជាពាក្យ «ផឹក, ទឹក, ដឹក, ស្អឹក, ព្រលឹម, សឹក...ជាដើម នោះយើងត្រូវពិគ្រោះសម្លេងស្រៈ ។

ស្រៈ អ៊ឹ ចំពោះនេះកាលបើប្រគបនឹងខ្យល់កុន «វគ្គ»

មានសូរសព្ទជា អិបឬអិញ, អ៊ីបឬអ៊ីញ ដូចជា ដូចម្ដេច, ម៉េច, បេញ, សេញ, ម្រេញ, ខ្ទេចខ្ទី, គ្រេច, ពេជ្រ, ម្រេច, កំទេច, វេច, លេច, រេច, កំពេញ, ក្ដេច . . . ។ល។ តែវៀរ បន់ពាក្យមួយម៉ាត់គឺ ប្រេចមានសូរសព្ទជា «អេច» ទៅវិញ ។

មិនតែប៉ុណ្ណោះ ស្រៈ អែ ប្រកបទីងខ្យល់ក្នុង បរិគ្គ ដដែល ទៅជាមានសូរសព្ទមួយបែបទៀត គឺមានហាក់ដូចជាស្រៈ អា ប្រកបទីងខ្យល់ «ច» មានរស្សសញ្ញា ( ់ ) ដូចជា ស្ដេច, សម្ដេច, ស្រេច, សម្រេច, ស្រេច, ចាច់, សេចក្ដី, សេចក្ដា សេចគ្រេច, ផ្ដេច, ម្ដេជ្រ ប៉ុន្ដែពាក្យដែលមានសូរសព្ទទីង របៀបសរសេរបែបនេះមានតិចម៉ាត់ដែរទេ ក្រៅពីនេះស្រៈ អែ លែងមានសូរសព្ទបែបនេះទៀតហើយ ត្រូវសរសេរ ស្រៈ អា ប្រកបទីងខ្យល់មានរស្សសញ្ញា ដោយត្រង់ ៗ វិញ ដូចជា ចាច់, បំណាច់, ប្រចាច់, កាច់, សាច់, ជាច់, គ្រាច់.. ជាដើម ។

## មេរៀនទី៣៨:- អក្តាស

ការបន្ថែមអក្សរ ១ តួទៀត ពីខាងដើមពាក្យតាមបែបដែលលោកកំណត់ឲ្យប្រើ ដើម្បីធ្វើពាក្យនោះឲ្យប្លែកពីប្រក្រតីដើម ហៅថា "អក្តាសៈ„ ចែកចេញជាច្រើនស្ថានដូចតទៅនេះ៖

១- អក្តាសកិរិយាសព្ទ ឲ្យក្លាយទៅជានាមសព្ទ

ឧទាហរណ៍: ឲ្យ > អំណោយ, អត់ > អំណត់, ពូត > ពំនូត, កត់ > កំណត់, អួត > អំណួត, អរ > អំណរ, ឈ្នះ > ជំនះ ... ។ល។

២- អក្តាសគុណនាម ឲ្យក្លាយទៅជានាមសព្ទ

ឧទាហរណ៍: ចាស់ > ចំណាស់, តូច > តំណូច, ជា > ជំហា, ខ្ពស់ > កំពស់, ល្អ > លំអ, ក្រាស់ > កំរាស់, ខ្ជិល > កំជិល ... ។ល។...

៣- អក្តាសសុទ្ធកិរិយា ឲ្យក្លាយទៅជា ហេតុកិរិយា

ឧទាហរណ៍: កើត > បង្កើត; កាច់ > បង្ក្រាប; រៀន > បង្រៀន ស្រក់ > សម្រក់ ; ស្រាត > សម្រាត , ខុស > បង្ខុស , ខូច > បង្ខូច , ក > បង្ក , បេះ > បញ្ចេះ... ។ល។

៤ – អញ្ញត្តិកិរិយាវិសេសន៍ឱ្យក្លាយទៅជាគុណនាម

ឧទាហរណ៍: សេញ > សំពេញ , . . ។ល។ . .

៥ – អញ្ញត្តិកិរិយាវិសេសន៍ឱ្យក្លាយទៅជាកិរិយាសព្ទ

ឧទាហរណ៍: ស្រប > សំរប , ស្រុះ > សម្រុះ , ស្រួល > សម្រួល . . . ។ល។

៦ – អញ្ញត្តិនាមសព្ទ ជា នាមសព្ទដដែល

ឧទាហរណ៍: ស្មោក > សម្មោក . . . ។ល។ . . .

៧ – អញ្ញត្តិកិរិយាសព្ទឱ្យក្លាយទៅជា កិរិយាវិសេសន៍

ឧទាហរណ៍: ទីមទាម > ទទីមទទាម , ទីសទាស > ទទីសទទាស , ទ្រេតទ្រោត > ទទ្រេតទទ្រោត , ទ្រើកៗ > ទទ្រើក . . . ។ល។ . . .

៨ – អព្ភាសគុណនាមឲ្យក្លាយទៅជា កិរិយាសព្ទ

ឧទាហរណ៍: ស្អាត > សំអាត , ថ្កើង > តំកើង...។ល។...

## វិធីអព្ភាស

ដើម្បីនឹងធ្វើអព្ភាសៈពាក្យនីមួយៗឲ្យក្លាយទៅជានាមសព្ទក្តី, គុណសព្ទក្តី, កិរិយាសព្ទក្តី, កិរិយាវិសេសន៍ក្តី ត្រូវអព្ភាសតាមរបៀបខាងក្រោមនេះ៖

១.– បើកំណើតពាក្យជាអក្សរទី ១ក្នុងវគ្គទាំង ៥ នៃព្យញ្ជនៈ (ក, ច, ដ, ត, ប, និងតួ "អ" ១តួទៀតជា ៦តួត្រូវទុកអក្សរអព្ភាសឲ្យគង់រូបនៅដូចដើម ហើយចុះនិគ្គហិតតាម លើ

អក្សរតួមុខ រួចផ្លាស់អក្សរកំណើតពាក្យនោះជាតួ "ណ" ឯស្រៈនិស្ស័យនឹងតួប្រកបនៅដូចដើមដដែល ។

ឧ. ចំពោះព្យញ្ជនៈទី១នៃវគ្គទី១ដូចមានពាក្យតទៅនេះ៖

កត់ > កំណត់, កើត > កំណើត, កាប > កំណាប, កាន់ > កំណាន់, កេណ្ឌ > កំណេណ្ឌ, កាព្យ > កំណាព្យ... ។ល។

<u>វិធីអញ្ចាស:</u> ក-កត់ ចុះនិគ្គហិតលើតួ ក-កំ, ផ្លាស់ ក របស់ពាក្យ កត់ ជា ណ ផ្សំនឹង កំ-កំណត់ ។

ឧ. ចំពោះព្យញ្ជនៈទី១នៃវគ្គទី២ដូចមានពាក្យតទៅនេះ៖

ចត > ចំណត, ចាំ > ចំណាំ, ចាយ > ចំណាយ, ចូល > ចំណូល, ចេញ > ចំណេញ, ចែក > ចំណែក, ចេះ > ចំណេះ; ចោទ > ចំណោទ ... ។ល។

<u>វិធីអញ្ចាស:</u> ចត ជា ច-ចត ចុះនិគ្គហិតលើតួ ច ជា ចំ, ផ្លាស់ ច នៃកិរិយាសព្ទ ចត ជាណ ផ្សំគ្នាជា ចំណត ។

ឧ. ចំពោះព្យញ្ជនៈទី១នៃវគ្គទី៣ ដូចមានពាក្យតទៅ

នេះ៖ ដេក > ដំណេក, ដើរ > ដំណើរ, ដាំ > ដំណាំ, ដំ > ដំណំ ... ។ល។ (អញ្ញាសះ ដេក ជា ដ-ដេក, ចុះនិគ្គហិតអាគមលើ ដ ជា ដំ ផ្លាស់ „ដ„ នៃកិរិយាសព្ទ ដេក, ជា ណ ផ្សំជា ដំណេក) ។

ឃ. ចំពោះព្យញ្ជនៈទី១នៃវគ្គទី ៤ ដូចពាក្យតទៅនេះ៖ ត > តំណ, តែង > តំណែង, តាង > តំណាង, តាំង > តំណាំង, តូប > តំណូប... ។ល។ ...

(វិធីអញ្ញាសះ) ត ជា ត-ត, ចុះនិគ្គហិតអាគមលើ ត ជា តំ ផ្លាស់ "ត„ នៃកិរិយាសព្ទ ត ជា ណ ផ្សំជា តំណ)

ង. ចំពោះព្យញ្ជនៈទី១នៃវគ្គទី ៥ ដូចតទៅនេះ៖ ប៉ង > បំណង, បាច់ > បំណាច់, ប៉ែក > បំណែក, ប៉ះ > បំណះ... ។ល។

(វិធីអញ្ញាសះ) ប៉ង ជា ប-ប៉ង, ចុះនិគ្គហិតអាគមលើ ប ជា បំ ផ្លាស់ „ប៉„ នៃកិរិយាសព្ទ ប៉ង ជា ណ ផ្សំ

ជា បំណាង) ។

១. ចំពោះព្យញ្ជនៈ "អ" ដូចមានពាក្យតទៅនេះ ៖

អរ > អំណរ, អត់ > អំណត់ ... ។ល។ ...

វិធីអញ្ញាសៈ អរ ជា អ-អរ, ចុះនិគ្គហិតតាមលើតួ អ ជា អំ ផ្លាស់ "អ" នៃកិរិយាសព្ទ អរ ជា ណ ឲ្យជា អំណរ)

២.– បើកំណើតពាក្យជាអក្សរទី២ក្នុងវគ្គ (ខ, ឆ. ឋ, ថ, ផ,) ក្តី ជាអក្សរទី៤ក្នុងវគ្គ (ឃ, ឈ, ឍ. ធ, ភ) ក្តី ត្រូវផ្លាស់អក្សរអញ្ញាសៈ ជាអក្សរទី១នៃវគ្គ និងអក្សរទី ៣ នៃវគ្គតាមលំដាប់ គឺផ្លាស់ ខ > ក, ឆ > ច, ឋ > ដ, ថ > ត, ផ > ប, ឃ > គ, ឈ > ជ, ឍ > ឌ, ធ > ទ, ភ > ព ចុះនិគ្គហិតតាមអញ្ញាសៈ ផ្លាស់តួអក្សរនៃកំណើតពាក្យនោះជាអក្សរ "ហ" ឯស្រៈនិស្ស័យ និងតួប្រកបនៅដូចដែលទាំងអស់ ។

ខ. ចំពោះព្យញ្ជនៈទី២ ក្នុងវគ្គទី១ ដូចមានពាក្យថា៖ ខឹង > កំហឹង, ខុស > កំហុស, ខាក > កំហាក.. ។ល។

(វិធីអញ្ញាសៈ) ខឹងជាខ - ខឹង ផ្លាស់ ខជាក បុះនិគ្គហិតតាមលើកជាកំ, ផ្លាស់ខរបស់ខឹង ជាហ ផ្សំជាកំហឹង ) ។

គ. ចំពោះព្យញ្ជនៈទី២ និងទី៤ ក្នុងវគ្គទី២ ដូចពាក្យថា៖ ឆុត > ចំហុត, ឈរ > ជំហរ, ឈាន > ជំហាន ... ។ល។

វិធីអញ្ញាសៈ ឈរជាឈ - ឈរ ផ្លាស់ ឈជាជ, បុះនិគ្គហិតតាមលើ ជជាជំ, ផ្លាស់ឈ របស់ពាក្យឈរជាហ ផ្សំគ្នាជា ជំហរ ) ។

ឃ. ចំពោះព្យញ្ជនៈទី៤ ក្នុងវគ្គទី៤ ៖ធំ > ទំហំ (វិធីអញ្ញាសៈ ជាធ - ធំ, ផ្លាស់ ធជា ទ បុះនិគ្គហិតតាមលើទ ជា ទំ ផ្លាស់ ធ នៃពាក្យ ធំ ជា ហ ផ្សំជា ទំហំ ) ។

៣.- បើកំណើតពាក្យនោះជាអក្សរទី៣នៃវគ្គ (គ, ជ, ឌ, ទ, ព,) ត្រូវទុកអក្សរអញ្ញាសៈឲ្យគង់រូបនៅដូចដើម, បុះ

និគ្គហិតអាគម ផ្លាស់អក្សរកំណើត ពាក្យនោះជា ន ។ គរ > គំនរ (គរ អក្ខរៈជាគ-គរ ចុះនិគ្គហិតអាគមលើ គជា គំ, ផ្លាស់គរបស់ គរ ជា ន ផ្សំជាគំនរ), ជួយ > ជំនួយ (ជួយ អក្ខរៈជាជ-ជួយ ចុះនិគ្គហិតអាគមលើ ជជាជំ, ផ្លាស់ ជរបស់ ជួយ ជា ន ផ្សំជា ជំនួយ), ទួញ > ទំនួញ (អក្ខរៈទួញ ជា ទ-ទួញ ចុះនិគ្គហិតអាគមជាទំ ផ្លាស់ទ របស់ទួញ ជា ន ផ្សំជាទំនួញ, ទំ > ទ្រនំ (អក្ខរៈជា ទ-ទំ ចុះ រ អាគមលើទផ្សំជាទ្រ, ផ្លាស់ ទ របស់ទំ ជា ន ផ្សំជាទ្រនំ) ។

ជួនកាលផ្លាស់ន ជា ប ក៏មានខ្លះ ដូចពាក្យ ជួរ > ជំបួរ (អក្ខរៈជា ជ-ជួរ ចុះនិគ្គហិតអាគមលើ ជ ជា ជំ ផ្លាស់ជ របស់ពាក្យ ជួរជាន ផ្លាស់នជាប ផ្សំជា ជំបួរ) ។

៤ – បើកំណើតពាក្យនោះជាអក្សរ ល ត្រូវទុកអក្សរ អក្ខរៈឲ្យគង់រូបនៅដូចដើមចុះនិគ្គហិតអាគម ផ្លាស់អក្សរ

ស របស់កំណើតពាក្យនោះជា ណ ហើយទុកឲ្យគង់រូបនៅជា "ណ" ដដែលក៏មាន ផ្លាស់ "ណ" ជា "ន" ក៏មាន បើពុំនោះយកអក្សរ "ន" ទៅផ្ញើនឹងអក្សរ "ស" អព្ភាសៈ ហើយផ្សំនឹងស្រៈនិស្ស័យ របស់កំណើតពាក្យនោះក៏មាន ។

១. សង > សំណង (អព្ភាសៈជាស្ង-សង ចុះនិគ្គហិតអាគមលើ ស ជា សំ, ផ្លាស់ ស្ង របស់ពាក្យ សង ជា ណ ផ្សំជាសំណង), សួរ > សំណួរឬសំនួរ (អព្ភាសៈជាស្ង-ស្ងួរ ចុះនិគ្គហិតអាគមលើស្ង ជា សំ ផ្លាស់ស្ង របស់កិរិយាសព្ទស្ងួរជា ណ ផ្សំជាសំណួរ ផ្លាស់ ណ ជា ន ផ្សំជា សំនួរ ក៏មាន), សប់ > ស្នប់ (អព្ភាសៈជា ស-សប់ ផ្លាស់ ស របស់កិរិយាសព្ទសប់ជា ណ ផ្លាស់ ណ ជា ន រួច ន ទៅតម្រួតក្រោមស អព្ភាសៈ ជាស្ន ផ្សំជាមួយ ប់ ជ ស្នប់), សួ > ស្នួ (អព្ភាសៈជា ស.ស្ងួ ផ្លាស់ ស របស់ពាក្យស្ងួជា ណ ផ្លាស់ ណ ជា ន យក ន ទៅតម្រួតក្រោម ស អព្ភាសៈជា ស្ន ផ្សំជាមួយនឹងស្រៈ

និស្ស័យ ( ជា ស្ស ) ។

៤.–បើកំណើតពាក្យនោះជាអក្សរផ្ញើជើង ត្រូវអព្ភាសៈតាមតួអក្សរលើ, គឺបើអក្សរលើនោះ ជាតួអក្សរអ្វី ត្រូវអព្ភាសៈតាមតួអក្សរនោះ បុះនិគ្គហិតលើអក្សរអព្ភាសៈ, លុបតួអក្សររបស់កំណើតពាក្យនោះចេញ ទុកតែតួអក្សរក្រោម ផ្សំជាមួយនឹងអក្សរអព្ភាសៈ ។

១. គ្រប > គំរប (អព្ភាសៈ ជា គ-គ្រប បុះនិគ្គហិតតាមលើគជាគំ, លុប គ របស់កិរិយាសព្ទគ្រប ទុកតែ «រប» ផ្សំជាគំរប, ផ្លាស់និគ្គហិតជា «ម» ផ្សំជាគម្រប ក៏បាន ) ឃ្លាន > គំលាន (អព្ភាសៈជា ឃ-ឃ្លាន ផ្លាស់ឃ ជា គ បុះនិគ្គហិតតាមជាគំ, លុបឃរបស់កិរិយាសព្ទ ឃ្លាន ទុកតែត្រឹម «លាន» ផ្សំជាគំលាន, ផ្លាស់និគ្គហិតជាមផ្សំជា គម្លាន ក៏បាន ) ស្ទុះ > សំទុះ ( អព្ភាសៈជា ស-ស្ទុះ បុះនិគ្គហិតតាមជាសំលុប ទ របស់កិរិយាសព្ទ «ស្ទុះ» ទុកតែត្រឹម «ទុះ

ឲ្យជា សំទុះ, ផ្លាស់និគ្គហិតជា ង ឲ្យជា "សង្ទុះ" ក៏បាន);
ស្ដៀត > សំពៀត (អក្ខរាស:ជា ស-ស្ដៀត ចុះនិគ្គហិតតាមតម ជាសំ, លុប ស របស់គុណនាមស្ដៀតទុកត្រឹមតែ "ពៀត" ឲ្យជា សំពៀត) ។

៦.- បើកំណើតពាក្យនោះជាអក្សរផ្ញើផើង ហើយអក្សរផ្ញើផើងនោះជាអក្សរទី ២ ក្នុងវគ្គ ឬអក្សរទី ៤ ក្នុងវគ្គនោះត្រូវអក្ខរាស:តាមតួអក្សរលើនោះដែរ ប៉ុន្តែត្រូវផ្លាស់អក្សរអក្ខរាស:ជាអក្សរទី ១ ឬទី ៣ តាមលំដាប់វគ្គ ។

១. ខ្ពស់ > កំពស់ (អក្ខរាស:ជា ខ-ខ្ពស់ ផ្លាស់ ខ អក្ខរាស:ជា ក. ចុះនិគ្គហិតតាមតមលើជាកុំ, លុប "ខ" របស់ពាក្យខ្ពស់ចេញទុកត្រឹមតែ ពស់ ឲ្យជា កំពស់ ផ្លាស់និគ្គហិតជាម ឲ្យជា កម្ពស់ ក៏បាន); ថ្កើង > តំកើង (អក្ខរាស:ជា ថ-ថ្កើង, ផ្លាស់ ថ អក្ខរាស:ជា ត, ចុះនិគ្គហិតតាមតម លើជា

តំ, លុប "ប" របស់ពាក្យប្កើងចេញទុកត្រឹមតែ កើង ផ្សំជា តំកើង ផ្លាស់និគ្គហិតជាមផ្សំជាតម្កើង ក៏មាន), ធ្ងន់ > ទំងន់ (អក្សរៈ ជា ធ-ធ្ងន់ ផ្លាស់ ធ អក្សរៈ ជា ទ, ចុះនិគ្គហិតតាគមលើជា ទំ, លុប "ធ" របស់ពាក្យ "ធ្ងន់" ចេញ ទុកត្រឹមតែ "ងន់" ផ្សំជា > ទំងន់ ផ្លាស់និគ្គហិតជា ម ផ្សំជា ទម្ងន់ ក៏មាន), ខ្ជិល > កំជិល (អក្សរៈជា ខ-ខ្ជិល ផ្លាស់ ខ អក្សរៈ > ក ចុះនិគ្គហិតតាគមលើ ជា កំ, លុប "ខ" របស់ពាក្យខ្ជិលចេញ ទុកត្រឹមតែ ជិល ផ្សំជា កំជិល ផ្លាស់និគ្គហិតជា ម ផ្សំ ជា កម្ជិល ក៏មាន), ខ្ទេច > កំទេច (អក្សរៈជា ខ-ខ្ទេច ផ្លាស់ ខ អក្សរៈជា ក ចុះនិគ្គហិតតាគមលើជា កំ, លុប ខ របស់ពាក្យ ខ្ទេច ចេញទុកត្រឹមតែ ទេច ផ្សំជា កំទេច), ឆ្អិន > ចំអិន (អក្សរៈជា ឆ-ឆ្អិន ផ្លាស់ ឆ ជា ច ចុះនិគ្គហិតតាគមជា ចំ,

លុប ង របស់ពាក្យ ផ្អិត ចេញ ទុកត្រឹមតែ អិត ផ្សំជា បំអិត), ផ្អែម > បន្អែម (អក្ខរៈជា ផ-ផ្អែម ផ្លាស់ ផ អក្ខរៈជា ប ចុះនិគ្គហិតតាមផ្លាស់ជា ង លុប ផ របស់ ផ្អែម ចេញទុកត្រឹមតែ អែម ផ្សំជា បង្អែម ។

៧.–ចួនកាលគ្រាន់តែផ្សំអក្សរអក្ខរៈជាមួយនឹងអក្សរកំណើតពាក្យនោះតែម្តងក៏មាន ។

១.–ក + ករ > កករ, ក + កាយ > កកាយ, ក + កូរ > កកូរ, ក + ក្អាក > កក្អាក, ក + ក្អាយ > កក្អាយ, គ-គ្រឹក គ-គ្រេង > គគ្រឹកគគ្រេង, ទ-ទើស ទ-ទែង > ទទើសទទែង, ទ-ទឹស ទ-ទាស > ទទឹសទទាស, ទ-ទ្រេត ទ-ទ្រោត > ទទ្រេតទទ្រោត... ។ល។

## ពាក្យដែលត្រូវប្រើជាមួយនឹង«ដោយ»

១– គបដោយ = គបដោយសុវត្ថិភាព

២– ប្រកបដោយ = ប្រកបដោយសុខភាព, ប្រកប

ដោយសីលធម៌, ប្រកបដោយវិន្ទ្យធម៌ ។

៣ - បរិបូណ៌ដោយ=បរិបូណ៌ដោយគោគទ្រព្យ

៤ - សម្បូណ៌ដោយ =សម្បូណ៌ដោយគោជនាហារ

៥ - វិចិត្រដោយ =វិចិត្រដោយក្បូរក្បាច់ចំលាក់

៦ - រំលេចដោយ =រំលេចដោយពណ៌ផ្សេងៗ

ពាក្យ "ដោយ" ប្រើជាជំនួសកិរិយាវិសេសន៍

(Adverbe) ផងក៏បាន ។

១. ដោយរហ័ស ; ដោយប្រញាប់ ; ដោយច្រើន ..

ៗលៗ (មានសេចក្ដីស្មើគ្នានឹងពាក្យ "យ៉ាង") ។

# រៀនពាក្យ

## កទី១

អក្សរ "ង្អ, ម្ហ, ល្ល, ស្ប, ទ្ង, រ្យ," ទាំង៦តួនេះ ផ្ញើជើងទីឯអក្សរ "ក ទី ១" បានដូចគ្នា ហេតុនេះត្រូវចំ-ណាំ ដើម្បីកុំឲ្យច្រឡំរបៀបផ្ញើជើងទីឯអក្សរពីរតួខាងលើនេះ៖

ក្អ (មាន៩មាត់) គឺ: ក្អក, ក្អាញ, ក្អិកក្អក់ក្អុកក្អក់ក្អិក; ក្អិច, ក្អឹង ។

ខ្អ (ក្រៅពីនេះសុទ្ធតែ "ខ" ទាំងអស់) គឺ: ខ្អង, ខ្អល់ខ្អើយ, ដាក់ខ្អោះ, មួយខ្អាប់, មនុស្សខ្អានខ្អាប់, ខ្អាយ, ខ្អោសកោសដូង, ខ្អើត, ខ្អើយគោប... ។ល។

ក្ហ (មាន៤មាត់) គឺក្ហេងក្ហាង, កូនក្ហួយ, ម្ដាយក្ហេក ។

ខ្ហ (ក្រៅពីបួនមាត់ខាងលើនេះសុទ្ធតែខ្ហទាំងអស់) គឺ: ខ្ហងក្រើ, រត់ខ្ហាញ់, ខ្ហានធ្ង, ខ្ហាន់ប្រកេស, កេខ្ហាស,

ខ្មែរ , ខ្មៅ , ខ្មោច ... ។ល។

ក្វ= ( មាន ៣២ម៉ាត់ ) ដូច ឧទាហរណ៍: ក្វងប្រាក់ , កើត

ក្វន , ប៉ាំងក្វស់, ក្វាក់ប៉ារ៍, ក្វាហាន, ក្វិង, ក្វិនក្រអូប,

ក្វើខ្វុំ, ក្វែងខ្វូន, យកក្ដីបអំពិលមកក្វែម ... ។ល។ ...

ខ្វ= ( តិចជាង ក្វ ទេ មានតែ ២១ម៉ាត់ ): ស្ទឹកត្រាបៀកខ្វប

ខ្វារខ្វិន, ខ្វាចខ្វោច, ខ្វាញ់ត្រី, ខ្វើ, ខ្វឹមចិត្ត,

ផ្ដុំខ្វុយ, ខ្វះក្រប៉ី, ត្រឡាបខ្វូត, សត្វខ្វែង, ប៉ាយខ្វោច,

មនុស្សខ្វៅ ... ។ល។

ក្ស=( មាន១២ម៉ាត់ ) គឺៈ ក្សណ, មហាក្សត្រឬក្សត្រិយ៍ ,

ក្ស័យជីវិត, ក្សាន្តចិត្ត, ក្សិណនោះ, ក្សីណក្ស័យ,

ក្រសួងក្សេត្រាធិការ ... ។ល។

ខ្ស=( មាន២៩ម៉ាត់ ) គឺៈ ផ្លូវខ្សត, ខ្សត់ទ្រព្យ, ខ្សាច់,

សមុទ្រខ្សាច់, ស្រូវខ្សាយ, និយាយខ្សាវៗ, យំ

ខ្សឹកខ្សួល, ខ្សឹតសំពោរ, ថើបមួយខ្សឺត, ចៀមខ្សៀ ...

ក្ទ= (មានតែមួយម៉ាត់គត់) គឺ ក្ទម=ដើមក្ទម, ផ្លែក្ទម

ខ្ទ= (ក្រៅពីនេះសុទ្ធតែ «ខ្ទ» ទាំងអស់ គឺ: ខ្ទម, ពុខ្ទ័រ, សូរខ្ទរខ្ទារ, ខ្ទះដួង, ដំណើរខ្ទីត, មេមខ្ទឹម, សត្វខ្ទួយ

ក្ជ= (មានតែមួយម៉ាត់គត់) គឺ ក្ជែន (ប្រសប់, ស្ទាត់, ជំនាញ មនុស្សក្ជែន ) ។

ខ្ជ= (ក្រៅពីនេះសុទ្ធតែ ខ្ជ ទាំងអស់): ខ្ជល់ខ្ជាយក្នុងការងារ, ខ្ជាត់ខ្ជែង, ផ្ចៃខ្ជិត, ដើរខ្ជិល, មនុស្សខ្ជិន, ខ្ជែកគ្រោក, ខ្ជែងគំនិត ... ។ល។

-អក្សរ «ប្ប» ១តួនេះផ្ញើជើងចំពោះតែអក្សរ "ក" ទេ មិនមានផ្ញើជើងទីង "ខ" ឡើយ ដូចពាក្យថា =នៅលើក្បាលមានសក់, ត្រីក្បក, ចានក្បាន, ក្បាលក្រពើរទេះ, ប្រាសាទនគរវត្តមានក្បាច់ដ៏វិចិត្រ, ក្បិតសក់, បងក្បិន, សក្បុស ... ។ល។ ...

-អក្សរ «យ្យ» ១តួនេះក៏ផ្ញើជើងបានតែតួ "ខ" ដែរ ឥតមាន

នឹងតួ "ក" ទេ ដូចជា៖ ខ្យង, ខ្យល់បក់, ខ្យល់ចាប់, ខ្យល់គ, ខ្យាដំរីទេច ។

## ត នឹង ប

អក្សរ "ប្ប, ន្ន, ម្ម, ល្ល" នេះប្ចូរប្រយ័ត្នផ្ញើជើងនឹងតួអក្សរ "ត-ប" ៗ ជើង "ប្ប" ត្រូវនៅក្រោម "ត" ជាដរាប មិនត្រូវនៅក្រោម "ប" ទេ ដូចជាពាក្យ៖ ត្បាញសំពត់, ត្បិត (ដ្បិត), ត្បារកាចម៉ត្របៀក, ទិសខាងត្បូង, ត្បូងពេជ្រ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង. ត្បុគ្រី, តៀ្បតត្រី, ត្បាល់កៀ្រង, ត្បូកក្បាល ...ៗលៗ...

ជើង "ន្ន" នេះផ្ញើជើងនឹងតួអក្សរ ត មានតែមួយម៉ាត់គត់ "ត្នោត"=ដើមត្នោត, ទំពាំងទឹកត្នោត ។ ក្រៅពីនេះជើង "ន្ន" ផ្ញើជើងនឹងតួអក្សរ ប ទាំងអស់ដូចជា៖ ប្នក់សំពត់, ប្នក់ផ្លូវ, ប្នងដងត្រី, ប្នាក់ប្នម, ខ្ញុំផ្ញើកាប្នក, ថ្ងៃប្នី ...ៗលៗ..

– ត្ម (មានតែ៦ម៉ាត់)គឺ: អាត្មាភាព, សត្វត្មាត, ផ្លូលត្មិល, ពយខឹងត្មាន, ផ្លូលត្មោល, ត្មះតិះដៀល ។

–ថ្ម (មានតែ១១ម៉ាត់) គឺ: ថ្មបាយក្រៀម, ជូនជូវថ្មក្រ-នវគ្គី, ថ្មរនេះ, ថ្មតម្បូ, (បត់ម្បូ), ម្បូថ្មត, ថ្មើរម៉ានហើយ ? អ្នកថ្មើរជើង, អ្នកថ្មើរព្រៃ, សម្ពន់ថ្មី, ទើបនឹងការថ្មីថ្មោង, ចំណីថ្មោង... ។

– ជើង «ល» ផ្ញើជើងនឹងតួអក្សរ "ត" មានតិចម៉ាត់ដែរទេ៖ កាលត្លឹង, ត្លុករប៉ាំ, ក្របត្លុង, មូលត្លុំ, សត្វត្លុម, ស្រឡះត្លៃ, លៀនត្លៃ, ក្រហមត្លួត, ក្អែកត្លាត ។

ក្រៅពីនេះសុទ្ធតែផ្ញើជើងនឹងតួអក្សរថ ទាំងអស់ដូចជា៖ ថ្លស់ធ្លោយ, កូនថ្លោស, ពស់ថ្លាន់, ថ្លុកត្រពាំង, ថ្លឹងមាស, ថ្លាងធំ, សត្វថ្លែន, ថ្លង់ណាស់, ថ្លើមធំ, ថ្លៃថ្លា...

– អក្សរ "អ" ផ្ញើជើងតែនឹងតួអក្សរ ត ឥតមាននឹង "ថ" ទេ ដូចជាពាក្យថា៖ ត្អូញត្អែរ, ក្មេងត្អើក, រងត្អឹង, ត្អួរ...

## ប និង ផ

— អក្សរ « ដ » ១តួនេះផ្ញើជើងនឹងតួអក្សរ « ប និង ផ » បានដូចគ្នា, តែ « ប្ដ » មានតែបួនម៉ាត់តែគត់ៈ មានប្ដី, កុំប្ដឹង, ប្ដល់ទឹកគ្នា, ត្រូវបូជាជីវិតចំពោះមាតុភូមិ, ខ្ញុំប្ដេជ្ញា... តែប៉ុណ្ណោះ ។

ក្រៅពីនេះសុទ្ធតែ « ផ្ដ » ទាំងអស់គឺៈ កំផ្ដួលគេ, លផ្ដាច់, លេងផ្ដាច់ព្រ័ត្រ, និយាយតែផ្ដាស, ខ្ញុំផ្ដាសាយ, ក្រដាសផ្ដិត, ជុំផ្ដុស, ផ្ដួចផ្ដើម, កុំផ្ដៀងផ្ដងឲ្យគេ!, ស្រឡាញ់ផ្ដេក-ផ្ដិត, ខ្ញុំផ្ដេកចិត្តនឹងកិរិយាខ្ញុំ, កុំធ្វើផ្ដេសផ្ដាស, ផ្ដែផ្ដាំ, ផ្គរផ្ដាំតាមខ្យល់, ប្រៀងផ្ដោះផ្ដង...។ល។

អក្សរ « ល » ផ្ញើជើងនឹងតួអក្សរ « ប និង ផ » បានដូចគ្នា ហើយមានច្រើនជាបរិបូណ៌ដូចគ្នាដូច្នេះត្រូវស្ដាប់សំនៀងខ្យល់ឲ្យមែនទែនទើបសរសេរបានត្រឹមត្រូវ ដូចពាក្យថាៈ ដើរទៅប្លុកទេ, គោផ្លាង, ពោះប្លុន, ផ្លែក្រពាក់រុយព្រួសប្លុំប្លុំ,

ថ្លមបូលស៊ិ, របស់ថ្លម, ផ្លាស់សំពត់, ខ្ញុំផ្លាស់ពីខេត្តស្វាយ-រៀង មកធ្វើការនៅខេត្តបាត់ដំបងវិញ, ផ្លិតស្លាបសត្វ, ផ្លិត-មុខព្រហ្ម, ចាប់ដុំដីពេលបានផ្លាតទៅត្រូវឯពាងទឹក, ត្រីប្លាធ្លូ, ខ្ញុំមានអាយុ២០ឆ្លាយ, ពោត១ផ្លូន, ផ្លួតដៃ, ផ្លួតជើង, និយាយចំផ្លើស, រហ័សប្លិចដល់ភ្លាម, បាត់មុខយូរណាស់ ហើយ ហោតែលេចផ្លឹមមក. ចូលចុកក្នុងបន្ទប់, ផ្លុកបង្ហារ, ផ្លុះផ្លោះ. ប្លុងសំបុត្រ, ប្លន់ផ្លាន, បេះផ្លែក, ផ្លែងខ្លួន, ផ្លែនសារ, ផ្លុំស័ង្ខ, ពេលហ្លាងទៅលើ..។ល។..

- អក្សរ “ ស្បឹនអ្ន ” ផ្ញើជើងទឹង “ ប្ធ ” ជាជាប មិនផែលនៅក្រោម “ ឬ ” ទេ ដូចជាពាក្យថា ៖ ខ្ញុំផ្សេនតាម កសនា, ដំបៅឈើផ្ស, ផ្សាយដំណឹងផ្សេងៗ, ម្ដាយខ្ញុំ ទៅផ្សារ, ប្រពន្ធខ្ញុំផ្ទួលគេផ្សារឆ្នាំង, សត្វផ្សោតដើបព្រួសទឹក ផែតៗ, ផ្សំផ្គុំកូនប្រុស-ស្រី, និយាយផ្សិស៊ី, មេឃុំផ្សះ ផ្សព្វគតិ, ផ្អក, ផ្អៀងផ្អង, ញ័រពោះផ្អុកៗ, ទឹកផ្អូបៗ, ជុំផ្អូម,

លេបថាយផ្អូសៗ, ត្រូវពោលពាក្យផ្អែមជាដកប... ។ល។

## ព្យួរ និង ភ្ជួរ

ព និង ភ. — ជើង «យ្យ» ផ្ញើជើងនឹងអក្សរ ព ឥតមាន នឹង «ភ» ទេ ដូចជា ព្យាយាម, ព្យាធិ, ព្យាបាល, ខ្យល់ព្យុះ, -ជើង «ជ្ជ» ផ្ញើនឹងអក្សរ «ភ» ឥតមាន «ព្ជ» ទេ ដូច ជា ភ្ជុំភ្ជួរ, ភ្ជ័រ, ភ្ជាប់... ។ល។

ឯពាក្យ ព្យួរនិងភ្ជួរ អ្នកប្រើច្រើនយកទៅប្រើច្រឡំគ្នាដូចជាពាក្យថា ខ្ញុំព្យួរកសិដ, ខ្ញុំភ្ជួរអាវ, ចង់ភ្ជួរ ប្រើដូច្នេះពុំត្រូវ ឡើយ ត្រូវប្រើ «ខ្ញុំភ្ជួរស្រែចំការ, ខ្ញុំព្យួរអាវនឹងទាក-ខណ្ឌ, ចង់ព្យួរ យ៉ាងនេះវិញទើបត្រូវ»

## ពិ និង ពី

ត្រូវចំណាំពាក្យពីរម៉ាត់នេះ «ពិ និង ពី» ដែលសរសេរច្រើនច្រឡំជាញឹកញយ ហើយនឹកស្មានថាឥតខុសទៀតផង ។

ពាក្យដែលមាន ពី នៅពីមុខ នោះមានចំនួនតិចជាង ពិ ដែលនៅពីខាងមុខ ដូចជាពាក្យថា៖

ពិ = ពិការ, ពិគ្រោះ, ពិឃាត, ពិនិត្យពិច័យ, ពិចារណា, ពិចិត្រ, ពិន័យ, ក្លិនពិដោរ, ពិតាន, ពិបាក, ពិសាខ ពិធី, ពិសោធន៍, ពិសេស...។ល។

ពី = (សំពី, ខាង, ឯ) = មកពីណា? — រួចពីដៃ, ចេញពីមាត់, ពីព្រោះ, ពីគេ, ពីសីថ្មពីសី, ពិសាថ្មពីសា ។

ពាក្យដែលមាន ពី នៅខាងមុខមានតែប៉ុណ្ណេះ ។

ចប់



# សារបាន


| | ទំព័រ |
|---|---|
| យ៉ាងណាដែលហៅថាភាសាខ្មែរ | ១ |
| លក្ខណៈនៃភាសា | ១១ |
| វិធីតាងអក្សរខ្មែរ | ១៣ |
| វេយ្យាករណ៍ខ្មែរ | ២៨ |
| អក្ខរៈ | ៣០ |
| ស្រៈ | ៣២ |
| ព្យញ្ជនៈ | ៣៩ |
| ឋានកើតនៃព្យញ្ជនៈ | ៤១ |
| វគ្គ និង អវគ្គ | ៤៣ |
| ឃោសៈនិងអឃោសៈ | ៤៤ |
| សិថិលនិងធនិត | ៤៦ |
| និគ្គហិត | ៥០ |
| គរុនិងលហុ | ៥៣ |

ទំព័រ


| | |
|---|---|
| តួព្យញ្ជនៈបន្ថែម | ៥៥ |
| មុខងារនៃអក្សរ | ៥៩ |
| ស្វរសព្ទឃោសៈនិងអឃោសៈ | ៦១ |
| ព្យញ្ជនាទេសៈ | ៦២ |
| តួនៃអក្សរ | ៧០ |
| វណ្ណយុត្តិ | ៧៦ |
| នាម | ១០៩ |
| នាមសព្ទ | ១០៩ |
| នាមនាម | ១១១ |
| សាធារណនាម | ១១៤ |
| អសាធារណនាម | ១២១ |
| លិង្គរបស់នាម | ១២២ |
| វចនៈរបស់នាម | ១២៦ |
| សម្ពន្ធនិងមុខងាររបស់នាម | ១២៨ |

ទំព័រ


| | |
|---|---|
| គុណនាម | ១៣៣ |
| លិង្គនិងវចនៈរបស់គុណនាម | ១៣៦ |
| សម្ពន្ធនិងមុខងាររបស់គុណនាម | ១៣៧ |
| សំខ្យាសព្ទ | ១៣៨ |
| សព្វនាម | ១៤៧ |
| សម្ពន្ធសព្វនាម | ១៥៣ |
| កិរិយាសព្ទ-ប្រធាន-កម្ម | ១៥៥ |
| សម្ពន្ធកិរិយាសព្ទ | ១៦៥ |
| កិរិយាវិសេសន៍ | ១៦៦ |
| ព្យាង្គ | ១៦៨ |
| ព្យាង្គគម្រូ | ១៧០ |
| គាយតនិបាត | ១៨១ |
| គាលបទៈ | ១៩១ |
| និបាតសព្ទ | ១៩២ |

ទំព័រ


ឧតានសព្ទ ១៩៩
បរិវារសព្ទ ១៩៩
នាមក្រិត · កិរិយាក្រិត ២០១
កិរិយាក្រិត ២០២
ការក ២០៤
សន្ទាន ២០៥
សមាស ២០៦
សមូហនាម ២០៧
ឧបសគ្គ ២០៨
វេវចនៈ ២១៤
សទិសសព្ទ ២១៤
សទិសនាម ២១៥
អញ្ញត្រសព្ទ ២១៦
ការន្តសព្ទ ២១៧

ទំព័រ


| | |
|---|---|
| សន្ទានពាក្យ | ២១៧ |
| ធាតុ | ២១៧ |
| បុព្វបទ | ២១៨ |
| វិបត្តិនៃស្រៈ | ២២២ |
| អព្ភាសៈ | ២២៧ |
| វិធីអព្ភាសៈ | ២២៩ |
| ពាក្យដែលត្រូវប្រើជាមួយនឹង «ដោយ» | ២៣៩ |
| រៀនពាក្យ | ២៤១ |

13-9-57

តម្លៃ៣៥ រៀល